

# ប្រព័ន្ធអេកូឡូស៊ី
# ការស្រាវជ្រាវ
# កម្ពុជា

UNITED NATIONS
ESCAP
Economic and Social Commission for Asia and the Pacific



តំបន់ពណ៌ប្រផេះនៃផែនទីនេះបង្ហាញពីសមាជិក និងសមាជិករងរបស់គណៈកម្មការសេដ្ឋកិច្ចនិងសង្គម
ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP) *

គណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP) គឺជាវេទិកាអន្តររដ្ឋាភិបាលដែលប្រកបដោយបរិយាប័ន្នបំផុតនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ គណៈកម្មការនេះមានតួនាទីលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមសមាជិកចំនួន ៥៣ ប្រទេស និងសមាជិករងចំនួន ៩ ប្រទេស សំដៅជួយស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានានៅក្នុងការអភិវឌ្ឍប្រកបដោយចីរភាព។ ESCAP គឺជាគណៈកម្មការមួយក្នុងចំណោមគណៈកម្មការទាំង ៥ ប្រចាំតំបន់របស់អង្គការសហប្រជាជាតិ។

លេខាធិការដ្ឋាន ESCAP គាំទ្រដល់ការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន មានភាពធន់ និងមានចីរភាពនៅក្នុងតំបន់ តាមរយៈការបង្កើតចំណេះដឹងដែលផ្ដោតលើសកម្មភាព និងតាមរយៈការផ្ដល់ជាជំនួយបច្ចេកទេស និងសេវាកម្មកសាងសមត្ថភាព សំដៅជួយទ្រទ្រង់ដល់គោលដៅអភិវឌ្ឍន៍ជាតិ កិច្ចព្រមព្រៀងក្នុងតំបន់ និងការអនុវត្តរបៀបវារៈការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០។

** ការរចនាប្លង់ដែលប្រើ និងការបង្ហាញនានានៅក្នុងផែនទីនេះ មិនមែនជាការបញ្ចេញទស្សនៈអ្វីមួយដោយលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ទាក់ទងនឹងស្ថានភាពផ្នែកច្បាប់ប្រទេស ដែនដី ទីក្រុងឬតំបន់ណាមួយ ឬអាជ្ញាធររបស់ប្រទេស ឬសមត្ថកិច្ចទាក់ទងនឹងការកំណត់ព្រំដែននៃទីកន្លែងនោះទេ។*

# ប្រព័ន្ធអេកូឡូស៊ីការស្រាវជ្រាវកម្ពុជា

UNITED NATIONS ESCAP
Economic and Social Commission for Asia and the Pacific

MINISTRY OF INDUSTRY, SCIENCE, TECHNOLOGY & INNOVATION

ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ
រក្សាសិទ្ធិ © អង្គការសហប្រជាជាតិឆ្នាំ២០២២
រក្សាសិទ្ធិគ្រប់យ៉ាង
បោះពុម្ពនៅបាងកក
ST/ESCAP/3033

សញ្ញាសម្គាល់ប្រាក់ដុល្លារ ($) សំដៅលើប្រាក់ដុល្លាររបស់សហរដ្ឋអាមេរិក លើកលែងតែមានការបញ្ជាក់ផ្សេងទៀត។

ការរចនាប្លង់ដែលប្រើ និងការបង្ហាញនានានៅក្នុងឯកសារនេះ មិនមែនជាការបញ្ចេញទស្សនៈអ្វីមួយដោយលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ទាក់ទងនឹងស្ថានភាពផ្នែកច្បាប់ប្រទេស ដែនដី ទីក្រុងឬតំបន់ណាមួយ ឬអាជ្ញាធររបស់ប្រទេស ឬសមត្ថកិច្ចទាក់ទងនឹងការកំណត់ព្រំដែននៃទីកន្លែងនោះទេ។

នៅពេលដែលមានការរចនាឈ្មោះ "ប្រទេស ឬតំបន់" នោះគឺគ្របដណ្តប់លើប្រទេស ដែនដី ទីក្រុងឬតំបន់ទាំងនោះ។

ឯកសារគន្ថនិទ្ទេស និងឯកសារយោងផ្សេងទៀតត្រូវបានធ្វើការផ្ទៀងផ្ទាត់។ អង្គការសហប្រជាជាតិមិនទទួលខុសត្រូវចំពោះសុពលភាព ឬដំណើរការនៃ URLs ទេ។

ទស្សនៈដែលបានលើកឡើងនៅក្នុងការបោះពុម្ពផ្សាយនេះគឺជាទស្សនៈរបស់អ្នករៀបរៀង ឬអ្នកចូលរួមចំណែក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការសហប្រជាជាតិទេ។

ទស្សនៈ តួលេខ និងការប៉ាន់ស្មាននានាដែលបានលើកឡើងនៅក្នុងការបោះពុម្ពផ្សាយនេះគឺជាទំនួលខុសត្រូវរបស់អ្នករៀបរៀងនិងអ្នកចូលរួមចំណែក និងមិនត្រូវចាត់ទុកថាជាការឆ្លុះបញ្ចាំងពីទស្សនៈ ឬមានការឯកភាពពីអង្គការសហប្រជាជាតិឡើយ។ រាល់កំហុសឆ្គងណាមួយដែលមាន គឺជាទំនួលខុសត្រូវរបស់អ្នករៀបរៀង។

សេចក្តីយោងអំពីឈ្មោះក្រុមហ៊ុន និងផលិតផលពាណិជ្ជកម្ម ពុំបញ្ជាក់ថា អង្គការសហប្រជាជាតិឯកភាពតាមសេចក្តីយោងទាំងនោះទេ ហើយការដែលមិនបានបញ្ចេញឈ្មោះសហគ្រាស ផលិតផលពាណិជ្ជកម្ម ឬដំណើរការណាមួយ ក៏ពុំមែនជាសញ្ញានៃការមិនយល់ព្រមដែរ។

ការប្រើប្រាស់ការបោះពុម្ពផ្សាយសម្រាប់គោលបំណងពាណិជ្ជកម្មណាមួយត្រូវបានហាមឃាត់ លើកលែងតែមានការអនុញ្ញាតជាមុនពីលេខាធិការក្រុមប្រឹក្សាបោះពុម្ពផ្សាយ នៃអង្គការសហប្រជាជាតិ ប្រចាំនៅទីក្រុងញូវយ៉ក។ ការស្នើសុំការអនុញ្ញាតបោះពុម្ពផ្សាយត្រូវបញ្ជាក់ពីគោលបំណង និងទំហំនៃការបោះពុម្ពផ្សាយនោះ។

# អារម្ភកថា

ប្រព័ន្ធនវានុវត្តន៍ជាតិដែលមានមូលដ្ឋានស្រាវជ្រាវដ៏រឹងមាំពិតជាមានសារៈសំខាន់ណាស់ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាព ព្រមទាំងបង្កើតភាពធន់ដល់ប្រទេសជាតិឱ្យមានសមត្ថភាពក្នុងការពុះពារឧបសគ្គ និងចាប់យកកាលានុវត្តភាពផ្សេងៗនៃបដិវត្តន៍ឧស្សាហកម្មទី៤។ រាជរដ្ឋាភិបាលកម្ពុជាយល់ច្បាស់ថា ការចង់ដឹងចង់ឃើញ និងការតាំងចិត្តរបស់អ្នកស្រាវជ្រាវ នវានុវត្តជន និងសហគ្រិន ជាទ្រព្យសកម្មដ៏សំខាន់ក្នុងការស្តារសេដ្ឋកិច្ចដែលប៉ះពាល់ដោយវិបត្តិជំងឺរាតត្បាតកូវីដ-១៩ និងការដោះស្រាយបញ្ហាប្រឈមក្នុងសង្គមនាពេលអនាគត។

គណៈកម្មការសេដ្ឋកិច្ចនិងសង្គម ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ប្តេជ្ញាចិត្តក្នុងការជំរុញការស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន។ បេសកកម្មរបស់គណៈកម្មការ គឺកសាងទំនាក់ទំនងភាពជាដៃគូជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីគាំទ្រដល់ការផលិតរបាយការណ៍ការសិក្សាពីប្រព័ន្ធអេកូឡូស៊ី និងកសាងគោលនយោបាយផ្អែកលើទឡ្ហីករណ៍ ដែលអាចបង្កើតសក្តានុពលដល់ប្រជាជនកម្ពុជា និងដឹកនាំប្រទេសឆ្ពោះទៅសម្រេចបាន ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

របាយការណ៍ប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវកម្ពុជានេះ គឺជាសមិទ្ធផល និងជាផ្លែផ្កានៃភាពជាដៃគូទ្វេភាគីនេះ។ ការសិក្សានេះ បានវិភាគ ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង នៃការស្រាវជ្រាវរបស់ប្រទេសកម្ពុជា ដោយបានផ្តល់នូវអនុសាសន៍ជាយុទ្ធសាស្ត្រលើ ប្រធានបទស្រាវជ្រាវជាអាទិភាពនិងយន្តការគោលនយោបាយស្របតាមបរិបទជាតិ។ របាយការណ៍នេះក៏ត្រូវបានផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការវិភាគក្នុងការរៀបចំរបៀបវារៈស្រាវជ្រាវជាតិកម្ពុជា ឆ្នាំ២០២៥ ដែលជាសកម្មភាពគន្លឹះ ដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា ២០៣០ ដើម្បីលើកកម្ពស់ និងដឹកនាំនូវកិច្ចខិតខំប្រឹងប្រែងលើការងារស្រាវជ្រាវនៅកម្ពុជា។

លើសពីនេះទៅទៀត របាយការណ៍នេះក៏ជាសក្ខីភាពរវាង គណៈកម្មការសេដ្ឋកិច្ចនិងសង្គម ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក និងរាជរដ្ឋាភិបាលកម្ពុជា ចំពោះការប្តេជ្ញាចិត្តរួមគ្នាក្នុងការបម្រើផលប្រយោជន៍ជូនជនរួមជាតិកម្ពុជាប្រកបដោយបរិយាបន្ន។ ក្នុងអំឡុងពេលដែលកម្ពុជាទើបតែងើបចេញពីវិបត្តិនៃជំងឺរាតត្បាត យើងសង្ឃឹមថារបាយការណ៍នេះនឹងមានគុណតម្លៃដ៏វិសេសសម្រាប់អភិវឌ្ឍគោលនយោបាយឱ្យមានប្រសិទ្ធភាព និងបង្កើនសមត្ថភាពស្រាវជ្រាវជាតិជាអតិបរិមានិងនាំមកនូវឧត្តមភាពសម្រាប់កម្ពុជា។

**អគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិ និង**
**លេខាធិការប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ច**
**និងសង្គម ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក**

**Armida Salsiah Alisjahbana**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**
**និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានរៀបចំឡើងក្រោមការគាំទ្រពីផ្នែកពាណិជ្ជកម្ម វិនិយោគ និងនវានុវត្តន៍នៃគណៈកម្មការសេដ្ឋកិច្ចនិងសង្គម ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។ របាយការណ៍នេះត្រូវបានរៀបរៀងឡើងដោយ លោកស្រី Francie Sadeski, អ្នកគ្រប់គ្រងភាពជាដៃគូនៃក្រុមហ៊ុន Technopolis ប្រចាំតំបន់ប្រទេសអាហ្វ្រិក លោកស្រី Laura Rennie ទីប្រឹក្សាបច្ចេកទេសរបស់ក្រុមហ៊ុន Technopolis ប្រចាំប្រទេសបារាំង និងលោក Matthieu Lacave នាយកគ្រប់គ្រងក្រុមហ៊ុន Technopolis និង ក្រោមការដឹកនាំ និងត្រួតពិនិត្យដោយ លោកស្រី Marta Pérez Cusó មន្ត្រីផ្នែកកិច្ចការសេដ្ឋកិច្ចរបស់គណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិង ប៉ាស៊ីហ្វិក លោក Rafael Torquato Cruz អ្នកសម្របសម្រួលគម្រោង និងលោក Jastyn Alain Limon បុគ្គលិកហាត់ការ ផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍ នៃគណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។ ឯកឧត្តមបណ្ឌិត ហ៊ុល សៀងហេង អគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ និងលោកបណ្ឌិត ស្រ៊ុន បញ្ញារិទ្ធិ ប្រធាននាយកដ្ឋានគោលនយោបាយវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នៃប្រទេសកម្ពុជា បានរួមចំណែកផ្តល់អនុសាសន៍ជាទិសដៅរួមក្នុងការរៀបរៀងរបាយការណ៍នេះផងដែរ។

របាយការណ៍នេះត្រូវបានរៀបរៀងឡើងនៅក្នុងឆ្នាំ ២០២១ ដើម្បីផ្តល់នូវព័ត៌មានសាវតារជាធាតុចូលសម្រាប់ការរៀបចំបង្កើតរបៀបវារៈស្រាវជ្រាវជាតិ ឆ្នាំ២០២៥។ ការវិភាគក្នុងរបាយការណ៍នេះបានបញ្ចូលនូវទស្សនាទាន បណ្តុំចំណេះដឹង ទិន្នន័យ និងការយល់ឃើញនានាដែលប្រមូលបានតាមរយៈការចែករំលែកពីអ្នកជំនាញ អ្នកស្រាវជ្រាវ អ្នកសិក្សា និងមន្ត្រីរបស់រាជរដ្ឋាភិបាលក្នុងអំឡុងពេលដំណើរការរៀបចំបង្កើតរបៀបវារៈស្រាវជ្រាវជាតិ។

ដើម្បីចងក្រងនូវរបាយការណ៍នេះ ការស្ទង់មតិត្រូវបានផ្ញើទៅកាន់អ្នកចូលរួមចំនួន៣៦នាក់ មកពីបណ្តាក្រុមអ្នកពាក់ព័ន្ធចំនួនបីក្រុមផ្សេងគ្នា ដូចជា គ្រឹះស្ថានសិក្សា វិស័យឯកជន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។ អ្នកចូលរួមនីមួយៗបានផ្តល់ចម្លើយតបនឹងការស្ទង់មតិទាក់ទងនឹងស្ថាប័នរបស់ពួកគេ។ ចម្លើយសរុបដែលទទួលបានពីអ្នកចូលរួមមាន ចំនួន២៧ ដែលស្មើនឹង៧៥%។ ការស្ទង់មតិទាក់ទងនឹងសមាសភាពសំខាន់ៗនៃប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវត្រូវបានធ្វើឡើងតាមប្រព័ន្ធអនឡាញ ដែលមានទាំងសំណួរបើក និងសំណួរបិទ។ លើសពីនេះទៀត ការសម្ភាសស៊ីជម្រៅជាមួយបណ្តាអ្នកពាន់ព័ន្ធក្នុងជួររាជរដ្ឋាភិបាល ក៏បានបំពេញបន្ថែមទៅលើលទ្ធផលនៃការស្ទង់មតិពីអ្នកពាក់ព័ន្ធ។ ឧបសម្ព័ន្ធ ២ បង្ហាញអំពីបញ្ជីពេញលេញនៃអ្នកចូលរួមក្នុងការស្ទង់មតិ និងអ្នកចូលរួមក្នុងកិច្ចសម្ភាសន៍។

# និយមន័យ

**ការស្រាវជ្រាវ** រួមមានការងារប្រកបដោយភាពច្នៃប្រឌិតនិងមានលក្ខណៈជាប្រព័ន្ធ ដើម្បីបង្កើននូវបណ្តុំចំណេះដឹង ដែលរួមមានចំណេះដឹងបម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម មនុស្សជាតិ វប្បធម៌និងសង្គម និងបង្កើតនូវកម្មវិធីចំណេះដឹងថ្មីៗ។

**អ្នកស្រាវជ្រាវ** គឺជាអ្នកជំនាញដែលចូលរួមក្នុងការបង្កើតគំនិត និងចំណេះដឹងថ្មី ឬនវានុវត្តន៍។ អ្នកស្រាវជ្រាវ ធ្វើការ ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងកែលម្អឬអភិវឌ្ឍគំនិត ទ្រឹស្តី គំរូម៉ូដែល ឧបករណ៍បច្ចេកទេស សូហ្វវែរ ឬវិធីសាស្ត្រសម្រាប់ប្រតិបត្តិការ។

**ចំណេះដឹង** រួមបញ្ចូលការរកឃើញការពិត ទស្សនៈ គំនិត និងទ្រឹស្តីផ្សេងៗអំពីទិដ្ឋភាពជាក់ស្តែងក្នុងពិភពលោក។ ជាធម្មតា ចំណេះដឹងរួមបញ្ចូលទាំងទ្រឹស្តីនៃទស្សនៈនិងគំនិត ព្រមទាំងការយល់ដឹងពីការអនុវត្តជាក់ស្តែង ដោយផ្អែកលើ ការស្រាវជ្រាវ ការពិសោធវិទ្យាសាស្ត្រ និងបទពិសោធន៍នៃការអនុវត្តការងារជាក់លាក់។ ចំណេះដឹងមុខវិជ្ជា រាប់បញ្ចូលទាំងគោលគំនិតជាក់លាក់លើមុខវិជ្ជា និងខ្លឹមសារលម្អិត ដូចជាអ្វីដែលបានសិក្សាក្នុងគណិតវិទ្យានិងភាសា ជាដើម។ ចំណេះដឹងមុខវិជ្ជាចម្រុះ គឺទទួលបានពីអន្តរទំនាក់ទំនងរវាងទស្សនៈ និងមាតិកានៃប្រធានបទ/ឯកទេសមួយ ទៅនឹងទស្សនៈ និងមាតិកានៃប្រធានបទ/ឯកទេសផ្សេងៗទៀត។ ចំណេះដឹងផ្នែកទ្រឹស្តី គឺជា  ការយល់ដឹងពីរបៀបដែលអ្នកអនុវត្តជំនាញធ្វើការ និងគិត។ ចំណេះដឹងនេះជួយដល់និស្សិតយល់ដឹងពីគោលបំណងនៃការសិក្សា ស្វែងយល់ពីការអនុវត្តពីការរៀន និងពង្រីកចំណេះដឹងជំនាញឯកទេសរបស់ពួកគេ។ ចំណេះដឹងផ្នែកបែបបទនីតិវិធី គឺជាការយល់ដឹងអំពីរបៀបដែលកិច្ចការអ្វីមួយត្រូវបានធ្វើឬសម្រេចតាមដំណាក់កាល ឬសកម្មភាពនានាដែលធ្វើឡើងដើម្បីសម្រេចគោលដៅអ្វីមួយ។ ចំណេះដឹងផ្នែកបែបបទនីតិវិធីខ្លះ មានដែនជាក់លាក់ និងខ្លះទៀតធ្វើការផ្ទេរឆ្លងកាត់ដែនបាន។

**នវានុវត្តន៍** យោងតាមសៀវភៅ "Oslo Manual ២០១៨" បានឱ្យនិយមន័យនវានុវត្តន៍ថាជាផលិតផល ឬដំណើរការ ដែលបង្កើតថ្មី ឬធ្វើឱ្យប្រសើរឡើង (ឬ រួមបញ្ចូលគ្នា) ដែលមានលក្ខណៈខុសគ្នាខ្លាំងពីផលិតផលឬដំណើរការដើមរបស់អង្គភាពមួយ[1] ហើយដែលត្រូវបានបង្កើតសម្រាប់អ្នកប្រើប្រាស់(ផលិតផល) ឬត្រូវបាននាំយកទៅប្រើដោយស្ថាប័ន (ដំណើរការ)។ ដូច្នេះហើយ ការបង្កើតចំណេះដឹងចេញពីការស្រាវជ្រាវ សម្រាប់បម្រើដល់ទីផ្សារ ឬការផ្លាស់ប្តូរដំណើរការក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម គឺជាមូលដ្ឋានគ្រឹះនៃនវានុវត្តន៍។ នវានុវត្តន៍ត្រូវបានធ្វើឡើងដោយអ្នកប្រើប្រាស់ អ្នកផ្គត់ផ្គង់ និងអតិថិជននៅគ្រប់ទីកន្លែង ពោលគឺទាំងនៅក្នុងរដ្ឋាភិបាល អាជីវកម្ម អង្គការមិនស្វែងរកប្រាក់ចំណេញនិងក្នុងវិស័យផ្សេងៗ និងស្ថាប័នដទៃនានា។ សៀវភៅខាងលើនេះ កំណត់នូវប្រភេទសកម្មភាពចម្បងៗចំនួន៨ ដែលអាចត្រូវបានអនុវត្តនិងបង្កើតនវានុវត្តន៍ ៖ (១) សកម្មភាពការស្រាវជ្រាវ និងអភិវឌ្ឍន៍ (២) វិស្វកម្ម ការរចនា និងសកម្មភាពការងារច្នៃប្រឌិតផ្សេងទៀត (៣)

[1] អង្គភាពអាចជាក្រុមហ៊ុន អង្គភាពរដ្ឋាភិបាល ស្ថាប័នមិនរកប្រាក់ចំណេញ ឬជាគ្រួសារ

សកម្មភាពធ្វើទីផ្សារ និងឃីហោ(៤) សកម្មភាពទាក់ទងនឹងកម្មសិទ្ធិបញ្ញា (៥) សកម្មភាពបណ្តុះបណ្តាលបុគ្គលិក(៦) សកម្មភាពអភិវឌ្ឍមូលទិន្នន័យ និងសូហ្វវែរ (៧) សកម្មភាពទាក់ទងនឹងលទ្ធកម្ម ឬជួលចលនទ្រព្យ និង (៨) សកម្មភាពលើការគ្រប់គ្រងនវានុវត្តន៍។

# សេចក្តីសង្ខេបប្រតិបត្តិ

ការស្រាវជ្រាវមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជា។ ម្យ៉ាងទៀតការស្រាវជ្រាវអនុញ្ញាតឱ្យមានការប្រមូលផ្តុំឧស្សាហកម្ម និងមូលធនហិរញ្ញវត្ថុ និងការអភិវឌ្ឍមូលធនមនុស្ស ព្រមទាំងអនុញ្ញាតឱ្យអាជីវកម្ម ស្ថាប័ន និងប្រជាជាតិនានាមានលក្ខណៈប្រកួតប្រជែង។ សកម្មភាពនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ ក៏មានសារៈសំខាន់ផងដែរសម្រាប់ការបង្កើតចំណេះដឹង និងឧបករណ៍ថ្មីៗដែលចាំបាច់ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗក្នុងសង្គម ផ្តើមពីការឆ្លើយតបទៅនឹងបញ្ហាជំងឺកូវីដ-១៩ រហូតដល់ការកាត់បន្ថយ និង ការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ ការវិនិយោគរយៈពេលវែងលើសមត្ថភាពស្រាវជ្រាវនឹងផ្តល់ អត្ថប្រយោជន៍ដល់ក្រុមហ៊ុន ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងអាចសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជាឆ្នាំ២០៥០។

រាជរដ្ឋាភិបាលកម្ពុជាកំពុងជំរុញឱ្យមានការពង្រឹងប្រព័ន្ធអេកូឡូស៊ីនវានុវត្តន៍ជាតិ។ ជាក់ស្តែង នៅខែកក្កដាឆ្នាំ ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា ២០៣០ ដែលជាឯកសារយុទ្ធសាស្ត្រមួយដើម្បីផ្តល់ទិសដៅដល់ការអនុវត្តគោលនយោបាយជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០។ សកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវនេះ គឺការអនុម័តរបៀបវារៈស្រាវជ្រាវជាតិដើម្បីពង្រឹងសមត្ថភាព និងគុណភាពស្រាវជ្រាវ និងកំណត់ទិសដៅជាយុទ្ធសាស្ត្រសម្រាប់សកម្មភាពស្រាវជ្រាវ។

របាយការណ៍នេះផ្តល់នូវភស្តុតាង និងក្របខណ្ឌវិភាគសម្រាប់ការបង្កើតរបៀបវារៈស្រាវជ្រាវជាតិ ដោយចង្អុលបង្ហាញនូវប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវបច្ចុប្បន្នរបស់កម្ពុជា និងអនុសាសន៍លើការពង្រឹងរបៀបវារៈស្រាវជ្រាវជាតិនេះ។

ការវិភាគលើប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវត្រូវបានធ្វើឡើងដោយផ្អែកលើជាតុផ្សំចំនួន ៩។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃការរកឃើញសំខាន់ៗ។

**ស្ថាប័នស្រាវជ្រាវ៖** រាជបណ្ឌិត្យសភាកម្ពុជា វិទ្យាស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ និងគ្រឹះស្ថានឧត្តមសិក្សា អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និង ធនាគារខួក្បាល(think Tanks) គឺជាអង្គភាព សំខាន់ៗក្នុងការធ្វើការស្រាវជ្រាវនៅកម្ពុជា។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងផ្នែកគោលនយោបាយជាក់លាក់ក៏ដោយ គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាទទួលបានស្វ័យភាពតិចជាងសមភាគីរបស់ពួកគេនៅក្នុងប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ាន។ ម្យ៉ាងទៀត គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាបានចាត់ទុកការស្រាវជ្រាវមិនមែនជាការចាំបាច់ ដោយសារគ្រឹះស្ថានទាំងនេះភាគច្រើនផ្តោតសំខាន់តែលើការបង្រៀនជាងការស្រាវជ្រាវជាពិសេសនៅក្នុងគ្រឹះស្ថានឯកជន។ ជាងនេះទៅទៀត ហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ (មន្ទីរពិសោធន៍ ឧបករណ៍

ពិសោធន៍ កុំព្យូទ័រ បណ្ណាល័យ ការទទួលបានកាលិកបត្រ និងមូលទិន្នន័យ) ចាំបាច់ត្រូវអភិវឌ្ឍបន្ថែមទៀតដើម្បីបំពេញតម្រូវការអ្នកស្រាវជ្រាវ។

**ប្រធានបទស្រាវជ្រាវ៖** មានភាពមិនស៊ីចង្វាក់គ្នារវាង ប្រធានបទស្រាវជ្រាវជាយុទ្ធសាស្ត្រ ដែលទាក់ទងនឹងការអភិវឌ្ឍជាតិ និងអ្វីដែលកំពុងបង្រៀន និងស្រាវជ្រាវនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា។ ការតម្រង់ទិសដៅបន្ថែមមានភាពចាំបាច់ដើម្បីគាំទ្រដល់ការវិនិយោគក្នុងការស្រាវជ្រាវឱ្យកាន់តែប្រសើរឡើងសម្រាប់ការសម្រេចបាននូវគោលដៅអភិវឌ្ឍជាតិ។

**អ្នកស្រាវជ្រាវ៖** ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានចំនួនអ្នកស្រាវជ្រាវក្នុងចំណោមប្រជាជនមួយលាននាក់ តិចបំផុតនៅក្នុងបណ្តាប្រទេសអាស៊ាន។ ប្រទេសកម្ពុជាមានអ្នកស្រាវជ្រាវចំនួន ៣០ នាក់ក្នុងចំណោម ប្រជាជន ១ លាននាក់ ឬអ្នកស្រាវជ្រាវសរុបមានត្រឹមតែ ៥០០ នាក់ប៉ុណ្ណោះ។ ជាងនេះទៅទៀត ភាគរយនៃ គ្រូបង្រៀនកម្រិតឧត្តមសិក្សាដែលមានសញ្ញាបត្របណ្ឌិតមានតែ ៣% ប៉ុណ្ណោះ ហើយស្ត្រីគឺមានតិចតួចបំផុត។ ការងារនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាកំពុងក្លាយជាបញ្ហាប្រឈមសម្រាប់គ្រូបង្រៀនដោយសារមហាវិទ្យាល័យមានលទ្ធភាពក្នុងការផ្តល់ប្រាក់ខែនូវកម្រិតមួយទាប និងការងារបង្រៀនច្រើន ដែលធ្វើឱ្យគ្រូមានពេលតិចតួចសម្រាប់ការស្រាវជ្រាវ។ ចំនួននិស្សិតបណ្ឌិតមានកម្រិតទាប (ទោះបីជាមានការកើនឡើងក៏ដោយ) និងសមត្ថភាពក្នុង ការបណ្តុះបណ្តាលដល់ពួកគេនៅតែមិនគ្រប់គ្រាន់។

**មូលនិធិស្រាវជ្រាវ៖** ការចំណាយក្នុងស្រុកសរុបលើការស្រាវជ្រាវនៅកម្ពុជាមានចំនួន ០,១២% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស., ក្នុងឆ្នាំ ២០១៥) ដែលជាកម្រិតមួយទាបបំផុតទីពីរនៅក្នុងតំបន់អាស៊ាន។ ម្យ៉ាងទៀត ៣៥% នៃមូលនិធិនេះបានមកពីដៃគូបរទេស និងអង្គការអន្តរជាតិ ដែលមានឥទ្ធិពលលើប្រធានបទស្រាវជ្រាវ និងពេលវេលានៃគម្រោង (ជាញឹកញាប់គម្រោងមានក្នុងរយៈពេលខ្លី)។

**គុណភាពស្រាវជ្រាវ និងសមិទ្ធកម្ម៖** លទ្ធផលស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាកំពុងមាននិន្នាការកើនឡើងចាប់តាំងពីឆ្នាំ២០០០ ជាមួយនឹងការបង្កើនកិច្ចសហការអន្តរជាតិ។ ទោះជាយ៉ាងណាក៏ដោយ គុណភាពស្រាវជ្រាវរបស់កម្ពុជាមិនទាន់មានសង្គតិភាពតាមគោលការណ៍ណែនាំរបស់ក្រមសីលធម៌ គុណភាពនៃទិន្នន័យនៅមានកម្រិត និងឧបសគ្គផ្នែកភាសា។

**ចល័តភាពរបស់អ្នកស្រាវជ្រាវ និងកិច្ចសហការអន្តរជាតិ៖** អាស៊ានបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនកិច្ចសហប្រតិបត្តិអន្តរជាតិលើការស្រាវជ្រាវរបស់កម្ពុជាតាមរយៈកម្មវិធីការផ្លាស់ប្តូរនិស្សិត និងកម្មវិធីសិក្សាសហសាកលវិទ្យាល័យទ្វេភាគី។ តែទោះជាយ៉ាងណា នៅមានឧបសគ្គមួយចំនួនចំពោះការពង្រីកចល័តភាពសម្រាប់អ្នកស្រាវជ្រាវកម្ពុជា (ជាពិសេសនៅក្រៅក្របខណ្ឌអាស៊ាន) ដូចជា កង្វះចំណេះក្នុងការចាប់យកឱកាស និងពេលវេលាក្នុងការដាក់ពាក្យសុំរបស់ពួកគេ របាំងភាសា និងភាពខុសគ្នានៃលក្ខខណ្ឌការងារនៅទូទាំងប្រទេស។

**កិច្ចសហការគ្រឹះស្ថានសិក្សា-ឧស្សាហកម្ម៖** សកម្មភាពសហគ្រិននៅក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាកំពុងមានការរីកចម្រើន។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ មជ្ឈមណ្ឌលបណ្តុះធុរកិច្ច ធុរកិច្ចថ្មី និងការិយាល័យភ្ជាប់ទំនាក់

ទំនងសាកលវិទ្យាល័យនិងឧស្សាហកម្មត្រូវបានបង្កើតឡើង ដើម្បីបង្កើនកិច្ចសហការគ្រឹះស្ថានសិក្សា-ឧស្សាហកម្ម។ ទោះជាយ៉ាងណាក៏ដោយ អ្នកស្រាវជ្រាវមួយចំនួននៅតែខ្វះការលើកទឹកចិត្តដើម្បីបង្កើតការសហការជាមួយឧស្សាហកម្ម។

**ការផ្តល់ធាតុចូលរបស់គ្រឹះស្ថានសិក្សាសម្រាប់ការអភិវឌ្ឍគោលនយោបាយ៖** ការរួមចំណែកនៃការសិក្សាស្រាវជ្រាវ សម្រាប់ការបង្កើតគោលនយោបាយរបស់រដ្ឋាភិបាលអាចត្រូវបានកែលម្អ។ ជាទូទៅ ការស្រាវជ្រាវដែលបានផលិតដោយអង្គការមិនមែនរដ្ឋាភិបាល មានឥទ្ធិពលលើគោលនយោបាយច្រើនជាងការស្រាវជ្រាវដែល ផលិតដោយសាកលវិទ្យាល័យ និងគ្រឹះស្ថានស្រាវជ្រាវ (ដោយសារអង្គការមិនមែនរដ្ឋាភិបាល មានពេលវេលា និងថវិកាច្រើនសម្រាប់ធ្វើការស្រាវជ្រាវ និងផ្សព្វផ្សាយការស្រាវជ្រាវប្រកបដោយគុណភាព)។

**គោលនយោបាយស្រាវជ្រាវ និងក្របខណ្ឌបទប្បញ្ញត្តិ៖** ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ គ្របដណ្តប់កំណែទម្រង់យុទ្ធសាស្ត្រចំនួន ៩ ចំនុចទាក់ទងនឹងការអប់រំឧត្តមសិក្សា។ មួយក្នុងចំណោមយុទ្ធសាស្ត្រទាំងនោះគឺ "ការលើកកម្ពស់គុណភាពការស្រាវជ្រាវ" ដោយមានការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា និងបង្កើតមូលនិធិជាតិសម្រាប់ការស្រាវជ្រាវនៅក្នុងកម្រិតឧត្តមសិក្សា។ នីតិវិធីប្រកបដោយប្រសិទ្ធភាពសម្រាប់ការចុះបញ្ជី និងការអនុវត្តកម្មសិទ្ធិបញ្ញាបានកំពុងដាក់ឱ្យអនុវត្ត ហើយច្បាប់កម្មសិទ្ធិបញ្ញារបស់កម្ពុជាមានភាពជឿនលឿនបើប្រៀបធៀបទៅនឹងប្រទេសផ្សេងៗក្នុងតំបន់អាស៊ាន។

ផ្អែកលើការវិភាគនេះ អនុសាសន៍ខាងក្រោមត្រូវបានស្នើឡើង៖

- **បន្សុីប្រធានបទស្រាវជ្រាវទៅនឹងតម្រូវការនៃការអភិវឌ្ឍជាតិ៖** កំណត់ការស្រាវជ្រាវបែបតម្រង់ទិសតាមបេសកកម្ម ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃការអភិវឌ្ឍរបស់ប្រទេសកម្ពុជា និងធានាថាការស្រាវជ្រាវដែលមានផលជះជាវិជ្ជមានត្រូវបានធ្វើឡើង។
- **បង្កើតកញ្ចប់មូលនិធិស្រាវជ្រាវដើម្បីផ្តល់ហិរញ្ញប្បទានដល់របៀបវារៈស្រាវជ្រាវជាតិ៖** កញ្ចប់មូលនិធិស្រាវជ្រាវនេះត្រូវគ្រប់គ្រងដោយគណៈកម្មាធិការមូលនិធិស្រាវជ្រាវ និងផ្តល់នូវនីតិវិធីប្រកបដោយភាពច្បាស់លាស់និងមានភាពងាយស្រួលសម្រាប់អ្នកស្រាវជ្រាវ។
- **កំណត់តួនាទី អាណត្តិ មធ្យោបាយ គោលបំណង និងថវិការបស់ស្ថាប័នស្រាវជ្រាវរដ្ឋាភិបាល៖** បង្កើនសមាមាត្រនៃមូលនិធិសម្រាប់ការស្រាវជ្រាវបែបអនុវត្តន៍(៧០% សម្រាប់ការស្រាវជ្រាវបែបអនុវត្តន៍)។ ស្ថាប័នស្រាវជ្រាវ និងស្ថាប័នបណ្តុះបណ្តាលដែលទទួលបានមូលនិធិសាធារណៈគួរជួយគាំទ្រដល់ ការប្រើប្រាស់លទ្ធផលស្រាវជ្រាវដែលអាចអនុវត្តជាក់ស្តែងបាននៅក្នុងវិស័យឧស្សាហកម្ម ។
- **ជ្រើសរើសស្ថាប័នស្រាវជ្រាវ និង ស្ថាប័នបណ្តុះបណ្តាលដែលទទួលបានមូលនិធិសាធារណៈមួយចំនួនដើម្បីប្រែក្លាយជាមជ្ឈមណ្ឌលឧត្តមភាព** តាមរយៈការផ្តល់ឱ្យពួកគេនូវមូលនិធិគ្រប់គ្រាន់ ឧបករណ៍ទំនើប និងការធានាក្នុងការជ្រើសរើសអ្នកស្រាវជ្រាវដែលមានគុណវុឌ្ឍិ និងមានសមភាពយេនឌ័រ។

- **ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធមុខរបរស្រាវជ្រាវដែលមានភាពទាក់ទាញ និងការលើកទឹកចិត្តសម្រាប់អ្នកស្រាវជ្រាវ** ដូចជា ការផ្តល់មូលនិធិថ្នាក់បណ្ឌិត ជំនួយហិរញ្ញវត្ថុ និងកម្មវិធីផ្តល់រង្វាន់ដើម្បីលើកកម្ពស់គុណតម្លៃអាជីពស្រាវជ្រាវ។
- **លើកទឹកចិត្តដល់វិស័យឯកជន ឱ្យធ្វើការស្រាវជ្រាវដោយសហការជាមួយគ្រឹះស្ថានសិក្សា** តាមរយៈការលើកកម្ពស់យន្តការការពារកម្មសិទ្ធិបញ្ញា ការផ្តល់គម្រោងជំនួយសម្រាប់ការស្រាវជ្រាវដែលមានកិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម និងបង្កើតថ្នាលអនឡាញសម្រាប់អ្នកស្រាវជ្រាវ មន្ត្រីរាជរដ្ឋាភិបាល និងវិស័យឯកជនដើម្បីសហការ និងផ្គូផ្គងតម្រូវការទៅនឹងជំនាញ។
- **បង្កើតបណ្តាញសាកលវិទ្យាល័យអន្តរជាតិដ៏រឹងមាំ** និងផ្តល់ភាពអំណោយផលដល់ចល័តភាពរបស់អ្នកស្រាវជ្រាវ ដើម្បីលើកកម្ពស់កិច្ចសហការស្រាវជ្រាវអន្តរជាតិបន្ថែមទៀត។
- **បង្កើតបរិយាកាសដើម្បីគាំទ្រអ្នកស្រាវជ្រាវដែលធ្វើដំណើរមកធ្វើការនៅប្រទេសកម្ពុជា**តាមរយៈការសម្របសម្រួលលិខិតអនុញ្ញាតការងារ។
- **ជូនដំណឹង និងបណ្តុះបណ្តាលអ្នកបង្កើតគោលនយោបាយ ដើម្បីធ្វើសមាហរណកម្មការស្រាវជ្រាវទៅក្នុងការបង្កើតគោលនយោបាយ** តាមរយៈការកំណត់តម្រូវការស្រាវជ្រាវសម្រាប់គោលនយោបាយ ការផ្តល់មូលនិធិសម្រាប់ការបកប្រែលទ្ធផលនៃការស្រាវជ្រាវសម្រាប់ការអនុវត្ត ការបង្កើតបណ្តាញទំនាក់ទំនងអចិន្ត្រៃយ៍រវាងអ្នកស្រាវជ្រាវ និងអ្នកបង្កើតគោលនយោបាយ និងការបង្កើតគណៈកម្មាធិការក្រមសីលធម៌ស្រាវជ្រាវ។

# មាតិការ


អារម្ភកថា ............ v

សេចក្តីថ្លែងអំណរគុណ ............ vi

និយមន័យ ............ vii

សេចក្តីសង្ខេបប្រតិបត្តិ ............ ix

មាតិការ ............ xiii

បញ្ជីរូបភាព ............ xvii

បញ្ជីតារាង ............ xviii

បញ្ជីអក្សរកាត់ និងពាក្យគន្លឹះ ............ xix

១. បរិការណ៍នៃប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវរបស់កម្ពុជា ............ ១

១.១. ហេតុអ្វីបានជាការស្រាវជ្រាវ និងអភិវឌ្ឍន៍មានសារៈសំខាន់ ? ............ ១

១.២. សាវតារនៃប្រវត្តិសាស្ត្រ នយោបាយ សេដ្ឋកិច្ច និងវប្បធម៌ ............ ២

១.៣. ការចូលរួមថ្នាក់ជាតិនាពេលបច្ចុប្បន្ន សម្រាប់ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ ............ ៣

១.៣.១. ការចូលរួមយ៉ាងទូលំទូលាយ ............ ៣

១.៣.២. វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ............ ៥

១.៣.៣. ការអប់រំ និងឧត្តមសិក្សា ............ ៧

១.៣.៤. បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ............ ៨

១.៣.៥. ឧស្សាហកម្ម ............ ១០

១.៣.៦. កសិកម្ម ............ ១១

១.៣.៧. ការប្រែប្រួលអាកាសធាតុ ............ ១១

១.៣.៨. សុខាភិបាល ............ ១២

១.៤. បញ្ហាប្រឈមនៃការអភិវឌ្ឍដែលកម្ពុជាបានកំពុងជួបប្រទះបច្ចុប្បន្ន ............ ១២

១.៤.១. សេដ្ឋកិច្ច (វិស័យឧស្សាហកម្ម និងសេវាកម្ម) ............ ១៣

១.៤.២. ការអប់រំ និងជំនាញ ..... ១៤
១.៤.៣. សុខាភិបាល ..... ១៥
១.៤.៤. អាហារ ទឹក កសិកម្ម និងដី ..... ១៦
១.៤.៥. បរិស្ថាន និងចីរភាព ..... ១៦

២. ការវិភាគលើប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ ..... ១៨

២.១. ស្ថាប័នស្រាវជ្រាវ ..... ១៩
២.១.១. ស្ថាប័នស្រាវជ្រាវសំខាន់ៗនៅកម្ពុជា ..... ១៩

២.២. ប្រធានបទស្រាវជ្រាវ ..... ២០
២.២.១. បញ្ហាប្រឈមនៃការអភិវឌ្ឍដែលត្រូវដោះស្រាយដោយការស្រាវជ្រាវ ..... ២០
២.២.២. ប្រធានបទស្រាវជ្រាវ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍ ..... ២១
២.២.៣. ប្រធានបទកំពុងបង្រៀនតាមគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ..... ២៣

២.៣. អ្នកស្រាវជ្រាវ ..... ២៩
២.៣.១. អ្នកស្រាវជ្រាវ ..... ២៩
២.៣.២. និស្សិតថ្នាក់បណ្ឌិត ..... ៣២

២.៤. មូលនិធិស្រាវជ្រាវ ..... ៣៣
២.៤.១. មូលនិធិស្រាវជ្រាវសម្រាប់សាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវ ..... ៣៣
២.៤.២. ការចំណាយពីវិស័យឯកជនលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ ..... ៣៧

២.៥. គុណភាពស្រាវជ្រាវ និងការអនុវត្ត ..... ៣៨
២.៥.១. លទ្ធផលស្រាវជ្រាវ ..... ៣៨
២.៥.២. គុណភាពស្រាវជ្រាវ ..... ៤១
២.៥.៣. ការវាយតម្លៃអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ ..... ៤១

២.៦. ចល័តភាពរបស់អ្នកស្រាវជ្រាវ និងកិច្ចសហការអន្តរជាតិ ..... ៤២
២.៦.១. ចល័តភាពរបស់អ្នកស្រាវជ្រាវ និងកិច្ចសហការអន្តរជាតិដែលមានស្រាប់ ..... ៤២
២.៦.២. ឧបសគ្គចំពោះចល័តភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ..... ៤៣
២.៦.៣. ដំណោះស្រាយដែលមានសក្តានុពល ..... ៤៤

២.៧. កិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម ..... ៤៤
២.៧.១. វិសាលភាពនៃកិច្ចសហការ ..... ៤៤
២.៧.២. ក្របខណ្ឌបច្ចុប្បន្ន ..... ៤៥
២.៧.៣. តម្រូវការការអភិវឌ្ឍបន្ថែមទៀត ..... ៤៦

២.៨. ធាតុចូលពីគ្រឹះស្ថានសិក្សាសម្រាប់គោលនយោបាយស្រាវជ្រាវ ..... ៤៧
២.៩. គោលនយោបាយស្រាវជ្រាវ និងក្របខណ្ឌច្បាប់ ..... ៤៩

៣. ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង (SWOT) ..... ៥២

៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ..... ៥៥

ឧបសម្ព័ន្ធ "ក" ការកំណត់ទិសដៅប្រធានបទនៃគោលនយោបាយជាតិ ..... ៥៧

ឧបសម្ព័ន្ធ "ខ" ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ..... ៧៥
២.១. ការស្ទង់មតិអ្នកពាក់ព័ន្ធ ..... ៧៥
២.២. ការសម្ភាសអ្នកពាក់ព័ន្ធ ..... ៧៦

ឧបសម្ព័ន្ធ "គ" ការឆ្លើយតបការស្ទង់មតិប្រព័ន្ធ អេកូឡូស៊ីស្រាវជ្រាវ ..... ៧៧
៣.១. អង្គភាពស្រាវជ្រាវ ..... ៧៧
៣.១.១. តើការស្រាវជ្រាវមានសារៈសំខាន់យ៉ាងណាចំពោះបេសកកម្មរបស់សាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវ? ..... ៧៧
៣.១.២. តើមានបុគ្គលិកស្រាវជ្រាវ និងនិស្សិតបណ្ឌិតប៉ុន្មាននាក់នៅក្នុងសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវទាំងនេះ? ..... ៧៩
៣.១.៣. តើស្ថានភាពនៃឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវមានលក្ខណៈដូចម្តេច? ..... ៨០
៣.១.៤. តើឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធនេះអាចប្រៀបធៀបទៅនឹងស្ថាប័នដែលធ្វើការស្រាវជ្រាវក្នុង វិស័យឯកជនយ៉ាងដូចម្តេច? ..... ៨០

៣.២. ប្រធានបទស្រាវជ្រាវ ..... ៨១
៣.២.១. តើប្រធានបទស្រាវជ្រាវសំខាន់ៗ អ្វីខ្លះគួរត្រូវបានផ្តោតការយកចិត្តទុកដាក់សម្រាប់សាកល វិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ និងវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ពួកគេ? ..... ៨១
៣.២.២. តើកម្ពុជានឹងប្រឈមនឹងបញ្ហាអ្វីខ្លះនាពេលអនាគត ហើយតើអ្នកស្រាវជ្រាវរបស់ប្រទេសកម្ពុជាគួរផ្តោតលើប្រធានបទអ្វីខ្លះ ដើម្បីដោះស្រាយបញ្ហាទាំងនោះ? ..... ៨១

៣.៣. មូលនិធិស្រាវជ្រាវ ..... ៨៥
៣.៣.១. តើការស្រាវជ្រាវត្រូវបានផ្តល់មូលនិធិយ៉ាងដូចម្តេច? ..... ៨៥

៣.៤. ការបំពេញកាតព្វកិច្ច និងគុណភាពនៃការស្រាវជ្រាវ ..... ៩១

៣.៤.១. តើអ្វីជាលទ្ធផលនៃការស្រាវជ្រាវរបស់សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវនៅក្នុង ប្រទេសកម្ពុជា ? ........ ៩១
៣.៤.៣. តើអ្នកស្រាវជ្រាវក្នុងវិស័យឯកជនត្រូវបានវាយតម្លៃដោយរបៀបណា ហើយតើការវាយតម្លៃ នេះអាចធ្វើឱ្យប្រសើរឡើងយ៉ាងដូចម្តេច ? ........ ៩៤
៣.៤.៤. តើក្រសួងវាយតម្លៃអ្នកស្រាវជ្រាវដោយរបៀបណា ហើយតើការវាយតម្លៃនេះអាចធ្វើឱ្យ ប្រសើរឡើងយ៉ាងដូចម្តេច ? ........ ៩៤

៣.៥. ចល័តភាពអ្នកស្រាវជ្រាវ និងកិច្ចសហការអន្តរជាតិ ........ ៩៦
៣.៥.១. តើចល័តភាពអ្នកស្រាវជ្រាវ និងកិច្ចសហការអន្តរជាតិនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ស្ថិតក្នុងកម្រិតណា ? ........ ៩៦

៣.៦. កិច្ចសហការរវាងគ្រឹះស្ថានសិក្សាស្រាវជ្រាវ និងវិស័យឧស្សាហកម្ម ........ ៩៧
៣.៦.១. ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន តើស្ថាប័នស្រាវជ្រាវ និងវិស័យឯកជនមានកិច្ច សហការគ្នាក្នុងកម្រិតណា ? ........ ៩៧

៣.៧. ធាតុចូលរបស់គ្រឹះស្ថានសិក្សាសម្រាប់ការធ្វើគោលនយោបាយ ........ ១០១
៣.៧.១. តើការស្រាវជ្រាវសិក្សា ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការធ្វើគោលនយោបាយ ក្នុងកម្រិតណា ? ........ ១០១

៣.៨. ក្របខណ្ឌបទប្បញ្ញត្តិ និងគោលនយោបាយការស្រាវជ្រាវ ........ ១០៣
៣.៨.១. តើក្របខណ្ឌបទប្បញ្ញត្តិ និងគោលនយោបាយការស្រាវជ្រាវមានអ្វីខ្លះ ? តើក្របខណ្ឌ បទប្បញ្ញត្តិ និងគោលនយោបាយការស្រាវជ្រាវអាចត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង ដោយវិធីណា ? ........ ១០៣

# បញ្ជីរូបភាព


**រូបភាព ២. ១៖** ប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ ........ ១៨

**រូបភាព ២. ២៖** ប្រធានបទស្រាវជ្រាវភាគច្រើននាពេលបច្ចុប្បន្ននៅកម្ពុជា និងប្រធានបទស្រាវជ្រាវដែលគួរតែជាអាទិភាពនៃរបៀបវារៈស្រាវជ្រាវជាតិឆ្នាំ២០២៥ យោងទៅតាមសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវ ........ ២២

**រូបភាព ២. ៣៖** ប្រធានបទស្រាវជ្រាវភាគច្រើននាពេលបច្ចុប្បន្ននៅកម្ពុជា និងប្រធានបទស្រាវជ្រាវដែលគួរតែជាអាទិភាព ........ ២៣

**រូបភាព ២. ៤៖** ការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍តាមប្រភពនៃកម្ពុជា ........ ៣៤

**រូបភាព ២. ៥៖** ការបោះពុម្ពផ្សាយបែបវិទ្យាសាស្ត្រ (អត្ថបទ, ជំពូកសៀវភៅ) របស់អ្នកនិពន្ធ ឬសហអ្នកនិពន្ធដែលមានសម្ព័ន្ធភាពកម្ពុជា ឆ្នាំ ១៩៦២ ដល់បច្ចុប្បន្ន ........ ៣៩

**រូបភាព ២. ៦៖** វិទ្យាស្ថានស្រាវជ្រាវដែលមានផលិតភាពបំផុតទាំង១០ ដែលមានសម្ព័ន្ធភាពនៅកម្ពុជា ឆ្នាំ២០០០ ដល់ ២០២០ ........ ៤០

**រូបភាព ២. ៧៖** វិស័យស្រាវជ្រាវដែលមានផលិតភាពបំផុតទាំង១០ នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០០០-២០២០ ........ ៤០

**រូបភាព គ. ១៖** ប្រធានបទស្រាវជ្រាវភាគច្រើននាពេលបច្ចុប្បន្ននៅកម្ពុជា និងប្រធានបទស្រាវជ្រាវដែលគួរតែជា អាទិភាពសម្រាប់របៀបវារៈស្រាវជ្រាវជាតិឆ្នាំ ២០២៥ យោងទៅតាមសាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ និង វិស័យឯកជន ........ ៨២

**រូបភាព គ. ២៖** ប្រធានបទស្រាវជ្រាវភាគច្រើននាពេលបច្ចុប្បន្ននៅកម្ពុជា និងប្រធានបទស្រាវជ្រាវដែលគួរតែជាអាទិភាពនៃរបៀបវារៈស្រាវជ្រាវជាតិ ២០២៥ យោងតាមក្រសួងនានា ........ ៨៤

**រូបភាព គ. ៣៖** លក្ខខណ្ឌវិនិច្ឆ័យរបស់ក្រសួងដែលត្រូវបានប្រើប្រាស់ដើម្បីសម្រេចថាគម្រោងមួយណាគួរទទួលបានមូលនិធិ ........ ៨៩

**រូបភាព គ. ៤៖** អត្ថបទស្រាវជ្រាវដែលមានឈ្មោះអ្នកនិពន្ធជាបុគ្គលិក/និស្សិតនៅតាមគ្រឹះស្ថាននីមួយៗដែលបានបោះពុម្ពផ្សាយនៅក្នុងកាលិកបត្រអន្តរជាតិត្រួតពិនិត្យដោយសហវិនិច្ឆ័យករក្នុងឆ្នាំ២០២០ ........ ៩១

# បញ្ជីតារាង


តារាង ២. ១៖ គ្រឹះស្ថានឧត្តមសិក្សា(សាធារណៈ និងឯកជន) និងក្រសួងដែលត្រួតពិនិត្យពួកគេ (ឆ្នាំសិក្សា ២០១៨-២០១៩) ..... ១៩

តារាង ២. ២៖ យុទ្ធសាស្ត្រជាតិដែលបានកំណត់អាទិភាព ស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ..... ២៥

តារាង ២. ៣៖ ចំនួនអ្នកស្រាវជ្រាវក្នុងមួយលាននាក់នៅក្នុងបណ្តាប្រទេសអាស៊ាន ..... ២៩

តារាង ២. ៤៖ គ្រូបង្រៀនកម្រិតឧត្តមសិក្សាដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិតនៅប្រទេសអាស៊ាន (ទិន្នន័យចុងក្រោយបំផុត) ..... ៣០

តារាង ២. ៥៖ ការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងស្រុកសរុប ( GERD ) (ឆ្នាំចុងក្រោយនៅក្នុងប្រទេសអាស៊ាន) ..... ៣៣

តារាង ២. ៦៖ ការផ្តល់មូលនិធិពីប្រភពសាធារណៈ និងឯកជន នៃអង្គការស្រាវជ្រាវដែលបានពិគ្រោះយោបល់នៅក្នុងការស្ទង់មតិ ESCAP ឆ្នាំ ២០២០ (គិតជា លានរៀល) ..... ៣៥

តារាង ២. ៧៖ ការបោះពុម្ពផ្សាយបែបវិទ្យាសាស្ត្រ នៃប្រទេសអាស៊ាន ឆ្នាំ២០១៩ ..... ៣៨

តារាង ២. ៨៖ ឧទាហរណ៍អំពីធាតុចូលបានពីការស្រាវជ្រាវដែលបញ្ចូលទៅក្នុងគោលនយោបាយប្រទេសកម្ពុជា ..... ៤៨

តារាង ក. ១ ៖ ភាពស៊ីចង្វាក់គ្នារវាងប្រធានស្រាវជ្រាវ និងគោលនយោបាយជាតិ ..... ៥៧

តារាង គ. ១៖ គ្រឹះស្ថានសិក្សានិងយុទ្ធសាស្ត្រស្រាវជ្រាវដែលបានកំណត់ជាលាយលក្ខណ៍អក្សរ ..... ៧៨

តារាង គ. ២៖ ចំនួនមូលនិធិដែលទទួលបានពីស្ថាប័នមូលនិធិសាធារណៈ និងឯកជនក្នុងឆ្នាំ ២០២០ ..... ៨៣

តារាង គ. ៣៖ មូនិធិទទួលបានពីប្រភពសាធារណៈ និងឯកជន និងប្រភពមូនិធិពាក់ព័ន្ធដែលទទួលបានពីស្ថាប័នរបស់វិស័យឯកជន ក្នុងឆ្នាំ២០២០ ..... ៨៨

តារាង គ. ៤៖ លក្ខខណ្ឌវិនិច្ឆ័យសំខាន់ៗសម្រាប់វាយតម្លៃការបំពេញកាតព្វកិច្ចរបស់អ្នកស្រាវជ្រាវដោយស្ថាប័ន និងការវាយតម្លៃពីប្រសិទ្ធភាព និងភាពត្រឹមត្រូវរបស់ស្ថាប័ន ..... ៩២

តារាង គ. ៥៖ កិច្ចសហការជាមួយវិស័យឯកជន ដោយគ្រឹះស្ថានសិក្សា ..... ៩៣

តារាង គ. ៦៖ ឥទ្ធិពលនៃគ្រឹះស្ថានសិក្សាស្រាវជ្រាវជាមូលដ្ឋានសម្រាប់ការបង្កើតគោលនយោបាយ ..... ១០១

# បញ្ជីអក្សរកាត់ និងពាក្យគន្លឹះ

| | |
|---|---|
| ARC | ក្រុមហ៊ុនអេមរ៉ាយស៍(ខេមបូឌា) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| AVI | វិទ្យាស្ថានចក្ខុវិស័យអាស៊ី |
| CCC | សភាពាណិជ្ជកម្មកម្ពុជា |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CSDG | គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (អ.ច.ក.) |
| ERW | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| ESCAP | គណៈកម្មការសេដ្ឋកិច្ចនិងសង្គម ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (អង្គការសហប្រជាជាតិ) |
| GDP | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) |
| GERD | ការចំណាយក្នុងស្រុកសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ |
| HEI | គ្រឹះស្ថានឧត្តមសិក្សា |
| ICT | បច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន |
| IP | កម្មសិទ្ធិបញ្ញា |
| ITC | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MFAIC | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| MISTI | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MME | ក្រសួងរ៉ែ និងថាមពល |
| MOC | ក្រសួងពាណិជ្ជកម្ម |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MOH | ក្រសួងសុខាភិបាល |
| MOI | ក្រសួងមហាផ្ទៃ |
| MOP | ក្រសួងផែនការ |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MPTC | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MRG | ក្រុមហ៊ុនម៉ុងឫទ្ធីគ្រុប ខូល អិល ធី ឌី |

| | |
|---|---|
| MSME | មីក្រូសហគ្រាស សហគ្រាសធុនតូចនិងមធ្យម |
| NIPTICT(CADT) | វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (បណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា) |
| NPIC | វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា |
| OECD | អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| PAI | គ្រឹះស្ថានសាធារណៈរដ្ឋបាល |
| R&D | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| RS-IV | យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ |
| RUA | សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| SDG | គោលដៅអភិវឌ្ឍប្រកបដោយចីរភាព |
| SME Bank | ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា |
| SMEs | សហគ្រាសធុនតូច និងមធ្យម |
| STEM | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) |
| STI | វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន) |
| TVET | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ធីវេត) |
| UHS | សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| UICC | មជ្ឈមណ្ឌលសហប្រតិបត្តិការរវាងសាកលវិទ្យាល័យនិងឧស្សាហកម្ម |
| UNESCO | អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (យូណេស្កូ) |
| VAT | អាករលើតម្លៃបន្ថែម |

# ជំពូកទី ១

# បរិការណ៍នៃប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវរបស់កម្ពុជា

## ១.១. ហេតុអ្វីបានជាការស្រាវជ្រាវ និងអភិវឌ្ឍន៍មានសារៈសំខាន់?

ការស្រាវជ្រាវនិងអភិវឌ្ឍន៍ នវានុវត្តន៍ ផលិតភាព កំណើន និងប្រាក់ចំណូល មានលក្ខណៈផ្សេងគ្នា ប៉ុន្តែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធដែលគាំទ្រគ្នាទៅវិញទៅមក[2]។ ការស្រាវជ្រាវនិងអភិវឌ្ឍន៍ សំដៅលើសកម្មភាពជាប្រព័ន្ធ និងមានភាពច្នៃប្រឌិត ដើម្បីផលិតចំណេះដឹងថ្មី ឬការអនុវត្តថ្មីបន្ថែមលើចំណេះដឹងដែលមានស្រាប់[3]។ ជាធម្មតា ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវបានចាត់ថ្នាក់ទៅជាការស្រាវជ្រាវបឋម ការស្រាវជ្រាវអនុវត្តន៍ និងការអភិវឌ្ឍដោយពិសោធន៍។ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ អាចជាផ្នែកនៃសកម្មភាពនវានុវត្តន៍ ពីព្រោះសកម្មភាពដែលមានភាពនវានុវត្តន៍រួមបញ្ចូលកិច្ចខិតខំប្រឹងប្រែងដែលមិនទាក់ទងទៅនឹងការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដូចជា ការទិញឧបករណ៍ គ្រឿងម៉ាស៊ីន ការបណ្តុះបណ្តាល ការរចនា និងទីផ្សារជាដើម។

ការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍ គឺជាធាតុផ្សំសំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច និងសង្គមនាពេលបច្ចុប្បន្ន និងអនាគត[4]។ ការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍កាន់តែមានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈមដ៏ស្មុគស្មាញដែលទាមទារឱ្យមានការស្រាវជ្រាវដែលមានប្រធានបទចម្រុះ និងកិច្ចសហប្រតិបត្តិការឆ្លងប្រទេស[5]។ កិច្ចសហប្រតិបត្តិការពហុវិស័យ ពហុជំនាញ និងអន្តរជាតិ ជាជំហាននៃការរកឃើញ និងជំរុញកំណើននៃការផ្ទេរចំណេះដឹង។

ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសមួយកើតឡើងតាមរយៈយន្តការផ្សេងៗ រួមមាន ការធ្វើនវានុវត្តន៍ ការប្រមូលផ្តុំមូលធនឧស្សាហកម្មនិងហិរញ្ញវត្ថុ និងការអភិវឌ្ឍមូលធនមនុស្ស[6]។ ការស្រាវជ្រាវ និងអភិវឌ្ឍន៍មានសារៈសំខាន់សម្រាប់ដំណើរការនេះ ព្រោះការស្រាវជ្រាវ និងអភិវឌ្ឍន៍ អនុញ្ញាតឱ្យអាជីវកម្ម ស្ថាប័ន និងប្រទេស

[2] United Nations Educational, Scientific and Cultural Organization Institute of Statistics. Higher Education in Asia:
Expanding out, expanding up. The rise of graduate education and university research. 2014. pp. 49.

[3] Organization for Economic Co-operation and Development. The Measurement of Scientific, Technological and Innovation Activities Oslo Manual. 2018.

[4] Organization for Economic Co-operation and Development. Assessing the Socioeconomic Impacts of Public R&D.
Paris, 2008.

[5] European Union. Research and innovation: Leading Innovation through EU Research.

[6] Gur, Betul. The Impact of R&D Expenditures on Development: A Case of Turkey. International Journal of Humanities and Social Science Invention, vol. 6, No. 4. 2020.

នានាមានភាពប្រកួតប្រជែង[7]។ លើសពីនេះទៅទៀត ការវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ផ្តល់អត្ថប្រយោជន៍ផ្សេងទៀត ដែលរួមចំណែកដោយផ្ទាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដូចជាការអភិវឌ្ឍជំនាញ និងការបង្កើតចំណេះដឹង វិធីសាស្ត្រ ឧបករណ៍ និងអាជីវកម្មថ្មីៗ[8]។ ការវិនិយោគទាំងនេះក៏មានសក្តានុពលផ្សេងផងដែរតាមរយៈការជំរុញឱ្យមាននិន្នាការនៃលំហូរអត្ថប្រយោជន៍ទៅកាន់បណ្តាក្រុមហ៊ុន អ្នកផ្គត់ផ្គង់ និងអតិថិជនផ្សេងទៀត[9]។

## ១.២. សាវតារនៃប្រវត្តិសាស្ត្រ នយោបាយ សេដ្ឋកិច្ច និងវប្បធម៌

ដំណើរការនៃប្រព័ន្ធឧត្តមសិក្សាទំនើបរបស់ប្រទេសកម្ពុជាបានចាប់ផ្តើមសារជាថ្មីឡើងវិញនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០។ ក្នុងអំឡុងពេលនោះ សាកលវិទ្យាល័យចំនួនប្រាំបីត្រូវបានបង្កើតឡើង ដែលមានអត្រានៃការចុះឈ្មោះសិស្សចន្លោះពី ៥៣០០នាក់ ទៅ ១៤៥៦០ នាក់នៅចុងទសវត្សរ៍[10]។ ទោះយ៉ាងណាក៏ដោយប្រព័ន្ធអប់រំត្រូវបានផ្លាស់ប្តូរនៅពេលដែលរបបខ្មែរក្រហមបានគ្រប់គ្រងប្រទេសនៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ក្នុងអំឡុងពេលនោះ ការអប់រំលើសពីកម្រិតបឋមសិក្សា និងជំនាញបច្ចេកទេសត្រូវបានហាមឃាត់ដោយរបបខ្មែរក្រហម ហើយការអប់រំកម្រិតឧត្តមសិក្សាត្រូវបានគាបសង្កត់យ៉ាងខ្លាំង[11]។ ម្យ៉ាងទៀត បន្ទាប់ពីការគ្រប់គ្រងដោយរបបខ្មែរក្រហមត្រូវបានបញ្ចប់ និងការបង្កើតសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ការដាក់ទណ្ឌកម្មបន្តបន្ទាប់បានរារាំងជំនួយផ្ទាល់ដល់ប្រទេសកម្ពុជារវាងឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨៩ លើកលែងតែការគាំទ្រពីប្លុកសូវៀត[12]។

ជំនួយដ៏ច្រើនពីប្រទេសផ្សេងៗបានមកដល់ប្រទេសកម្ពុជា បន្ទាប់ពីការដាក់ទណ្ឌកម្មត្រូវបានដកចេញ និងការបង្កើតព្រះរាជាណាចក្រកម្ពុជាឡើងវិញបានធ្វើឱ្យប្រព័ន្ធអប់រំមានភាពរស់រវើកសារជាថ្មី។ បន្ទាប់ពីឆ្នាំ ១៩៩៧ ការផ្លាស់ប្តូរគោលនយោបាយចម្បងចំនួនពីរបាននាំឱ្យមានការពង្រីកយ៉ាងឆាប់រហ័សនៃប្រព័ន្ធអប់រំឧត្តមសិក្សារបស់កម្ពុជា។ គោលនយោបាយទីមួយ គឺរដ្ឋាភិបាលបានអនុញ្ញាតឱ្យសាកលវិទ្យាល័យសាធារណៈទទួលយកនិស្សិតដែលបង់ថ្លៃសិក្សា (បន្ថែមលើនិស្សិតដែលទទួលបានការគាំទ្រពីរដ្ឋាភិបាល)។ គោល

[7] Organization for Economic Co-operation and Development. Frascati Manual 2015: Guidelines for Collecting and
Reporting Data on Research and Experimental Development, The Measurement of Scientific, Technological and
Innovation Activities, OECD Publishing, Paris, 2015.

[8] Salter, A.J. and Martin, B.R. The Economic Benefits of Publicly Funded Basic Research: A Critical Review. Research
Policy, vol. 30, No. 3. 2001.

[9] Clayton & Ngoy. Cambodia. Asian higher education: An international handbook and reference guide (pp. 21-36).
Westport, Conn.: Greenwood Press. 1997.

[10] Ibid.

[11] Vickery, Michael. Cambodia 1975 – 1982. Chiang Mai, Thailand: Silkworm Books. 1999. pp. 185.

[12] Clayton, Thomas. Cambodians and the occupation: Responses to and Perceptions of the Vietnamese Occupation,
1979-89. Southeast Asia Research, vol. 7, No. 3. 1999.

នយោបាយទីពីរ គឺ រដ្ឋាភិបាលបានបើកទីផ្សារដែលអនុញ្ញាតឱ្យស្ថាប័នឯកជនអាចបង្កើតគ្រឹះស្ថានអប់រំបាន។ ការផ្លាស់ប្តូរទាំងនេះគឺជាផ្នែកមួយនៃចលនាដ៏ទូលំទូលាយដើម្បីលើកកម្ពស់សេដ្ឋកិច្ចផ្អែកលើទីផ្សារនៅក្នុងប្រទេសកម្ពុជា។ ចាប់ពីទសវត្សរ៍ឆ្នាំ ១៩៩០ ដល់ដើមទសវត្សរ៍ឆ្នាំ ២០០០ គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ត្រូវបានពឹងផ្អែកជាពិសេសលើជំនួយពីប្រទេសអភិវឌ្ឍន៍។ ដូច្នេះហើយ ឥទ្ធិពលបរទេសលើការអប់រំកម្រិតឧត្តមសិក្សាបានកើនឡើងនូវការប្រកួតប្រជែងរវាងសាកលវិទ្យាល័យនៅបរទេស ក្រុមសាសនាដែលមានមូលដ្ឋាននៅបរទេស វិនិយោគិនឯកជន និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ។ ឥទ្ធិពលបរទេសនេះ បានផ្តល់ផលជះលើប្រធានបទស្រាវជ្រាវដែលទទួលបានកញ្ចប់មូលនិធិ។ ជាលទ្ធផល ការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិលើប្រធានបទស្រាវជ្រាវ អាចមិនស្របនឹងតម្រូវការរយៈពេលវែងរបស់ប្រទេស និងជារឿយៗការផ្តល់កញ្ចប់មូលនិធិស្រាវជ្រាវនេះមានរយៈពេលខ្លី។ ជាការពិតណាស់ គម្រោងស្រាវជ្រាវដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយអន្តរជាតិ ត្រូវបានអះអាងថាភាគច្រើនផ្តោតលើការចង់បានរបស់ម្ចាស់ជំនួយ ជាជាងការផ្តោតសំខាន់និងសំណួររបស់អ្នកស្រាវជ្រាវ[13]។

## ១.៣. ការចូលរួមថ្នាក់ជាតិនាពេលបច្ចុប្បន្ន សម្រាប់ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ

ផ្នែកនេះបង្ហាញពីយុទ្ធសាស្ត្រជាតិសំខាន់ៗទាក់ទងនឹងការស្រាវជ្រាវ។ គោលដៅសំខាន់នៃយុទ្ធសាស្ត្រនីមួយៗត្រូវបានកំណត់ដូចខាងក្រោម ហើយការអនុវត្តយុទ្ធសាស្ត្រនឹងត្រូវបានវិភាគនៅផ្នែកបន្ទាប់។

### ១.៣.១. ការចូលរួមយ៉ាងទូលំទូលាយ

រាជរដ្ឋាភិបាលកម្ពុជា គាំទ្រដល់ការអភិវឌ្ឍជាតិ តាមរយៈការបង្កើត និងអនុវត្តយុទ្ធសាស្ត្រចម្រុះយ៉ាងទូលំទូលាយនៅថ្នាក់ជាតិ។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានគាំទ្រចក្ខុវិស័យកម្ពុជាដើម្បីក្លាយខ្លួនជាប្រទេសដែលប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ និងប្រទេសដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៥០។ ម្យ៉ាងទៀត គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាគឺជាឯកសារយុទ្ធសាស្ត្រគន្លឹះសម្រាប់ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ។

- **យុទ្ធសាស្ត្រចតុកោណសម្រាប់កំណើនការងារប្រកបដោយសមធម៌ និងប្រសិទ្ធភាព (ដំណាក់កាលទី៤)**

យុទ្ធសាស្ត្រចតុកោណសម្រាប់កំណើនការងារប្រកបដោយសមធម៌ និងប្រសិទ្ធភាព (ដំណាក់កាលទី៤) គឺជាគោលនយោបាយស្នូលមួយដែលដឹកនាំកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់ប្រទេសកម្ពុជាឆ្នាំ២០៣០ និងឆ្នាំ២០៥០[14]។ យុទ្ធសាស្ត្រចតុកោណត្រូវបានបង្កើតឡើងជុំវិញមុំសំខាន់ៗចំនួនបួនគឺ (១) ការអភិវឌ្ឍធនធានមនុស្ស (២) ការធ្វើពិពិធកម្មសេដ្ឋកិច្ច (៣) ការលើកស្ទួយវិស័យឯកជន និង ការងារ និង (៤) ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន។ យុទ្ធសាស្ត្រចតុកោណមានគោលបំណង

[13] Cambodian Institute for Cooperation and Peace. Doing Research in Cambodia: Making Models that Build Capacity. 2016.

[14] Government of the Kingdom of Cambodia. Rectangular Strategy for Growth, Employment, Equity and Efficiency:
Building the Foundation Toward Realizing the Cambodia Vision 2050. 2018.

ដើម្បីសម្រេចឱ្យបាននូវគោលដៅយុទ្ធសាស្ត្រចំនួនបួន៖ (១) កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំចំនួន ៧% និងការលើកកម្ពស់ការប្រកួតប្រជែង (២) ការលើកកម្ពស់គុណភាព និងបរិមាណការងារ ជាពិសេសសម្រាប់យុវជន (៣) កាត់បន្ថយភាពក្រីក្រក្រោមកម្រិត ១០% និង (៤) ពង្រឹងអភិបាលកិច្ច និងសមត្ថភាពរបស់ស្ថាប័នសាធារណៈ។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក៏បានកំណត់យន្តការដើម្បីជំរុញការស្រាវជ្រាវផងដែរ។ នៅក្រោមមុំធនធានមនុស្ស យុទ្ធសាស្ត្រនេះស្វែងរកការកែលម្អការស្រាវជ្រាវលើវិធីសាស្ត្របង្រៀន ជំរុញការកសាងសមត្ថភាពស្រាវជ្រាវ និងមូលនិធិស្រាវជ្រាវក្នុងកម្រិតឧត្តមសិក្សា និងការលើកកម្ពស់ការស្រាវជ្រាវផ្នែកសុខាភិបាលដោយ ផ្តោតលើជំងឺ។ ក្រោមមុំការអភិវឌ្ឍប្រកបដោយចីរភាព ផែនការយុទ្ធសាស្ត្រគឺ ស្វែងរកការលើកកម្ពស់ការស្រាវជ្រាវក្នុងវិស័យកសិកម្ម បង្កើនសក្តានុពលជីកសិកម្ម និងអភិរក្សបេតិកភណ្ឌវប្បធម៌របស់កម្ពុជា។

- **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣**

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ត្រូវបានរៀបចំឡើងដើម្បីចូលរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណសម្រាប់កំណើនការងារប្រកបដោយសមធម៌ និងប្រសិទ្ធភាព (ដំណាក់កាលទី៤) និងសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។ យុទ្ធសាស្ត្រអាទិភាពរួមមាន (១) ការបង្កើនល្បឿនកំណែទម្រង់នៃអភិបាលកិច្ចល្អ៖ ស្នូលនៃយុទ្ធសាស្ត្រចតុកោណ (២) បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល (៣) ការអភិវឌ្ឍធនធានមនុស្ស (៤) ការធ្វើពិពិធកម្មសេដ្ឋកិច្ច (៥) ការអភិវឌ្ឍវិស័យឯកជន និងការងារ និង (៦) ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន។

សកម្មភាពសំខាន់មួយក្នុងចំណោមសកម្មភាពផ្សេងទៀតរបស់យុទ្ធសាស្ត្រគឺជំរុញឱ្យមានការស្រាវជ្រាវនៅថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ យុទ្ធសាស្ត្រនេះរួមមានបទប្បញ្ញត្តិដើម្បីលើកកម្ពស់ការស្រាវជ្រាវ ការផ្ទេរបច្ចេកវិទ្យាពីបរទេស និងការបង្កើតមូលនិធិស្រាវជ្រាវ។ ជាងនេះទៅទៀត យុទ្ធសាស្ត្រនេះប្រមើលមើលពីការពង្រឹងស្ថាប័នស្រាវជ្រាវ ការអនុវត្តកម្មវិធីស្រាវជ្រាវ និងការធ្វើពាណិជ្ជកម្មលទ្ធផលស្រាវជ្រាវ។

- **ក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ ២០១៦-២០៣០**[15]

ក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជាឆ្នាំ ២០១៦-២០៣០ រួមជាមួយនឹង យុទ្ធសាស្ត្រចតុកោណ គឺជាមូលដ្ឋានគ្រឹះរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣។ ក្របខណ្ឌនេះ បង្កើតឡើងពីគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជាចំនួន១៨ (ដោយបន្ថែមគោលដៅមួយទៀតទាក់ទងនឹងសកម្មភាពដោះមីន និងសំណល់ជាតិផ្ទុះផ្សេងទៀតនៃសង្គ្រាមបន្ថែមលើគោលដៅសកលទាំង១៧) ដែលរួមមាន ១០៥ គោលដៅ ក្នុងនោះ ២ គោលដៅ ជាសមាសធាតុស្រាវជ្រាវ។ គោលដៅមួយក្នុងចំណោមគោល

[15] Government of the Kingdom of Cambodia. Cambodian Sustainable Development Goals Framework (2016-2030).
2018.

ដៅទាំងអស់ គឺមានគោលបំណងបង្កើនការវិនិយោគក្នុងការស្រាវជ្រាវលើវិស័យកសិកម្មដើម្បី "បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព" (គោលដៅទី ២)។ គោលដៅទី២នេះ លើកកម្ពស់ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បង្កើនចំនួនអ្នកស្រាវជ្រាវ និងជំរុញការស្រាវជ្រាវសាធារណៈ និងឯកជន ដើម្បីសម្រេចឱ្យបាននូវគោលដៅទី៩ "កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងការប្រែប្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាព និងបរិយាបន្ននិងលើកកម្ពស់នវានុវត្តន៍"។

បន្ថែមពីលើយុទ្ធសាស្ត្រជាតិដែលមានលក្ខណៈទូលំទូលាយ យុទ្ធសាស្ត្រតាមវិស័យជាច្រើនក៏មានជាប់ពាក់ព័ន្ធសម្រាប់ការកសាងសមត្ថភាពស្រាវជ្រាវជាតិផងដែរ ដែលនឹងលម្អិតក្នុងផ្នែកបន្ទាប់។

## ១.៣.២. វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៏

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អនុវត្តនៅថ្នាក់ជាតិ ដើម្បីលើកកម្ពស់វិស័យ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងដឹកនាំដើម្បី ការផ្លាស់ប្តូរក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ស្ថាប័នទាំងពីរនេះផ្តល់ការណែនាំដើម្បីកំណត់ចក្ខុវិស័យ និងគោលបំណងច្បាស់លាស់សម្រាប់ជាយុទ្ធសាស្ត្រសម្រាប់វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលអាចជួយឱ្យប្រទេសឈានទៅដល់ការសម្រេចបាននូវគោលដៅសម្រាប់ឆ្នាំ ២០៣០ និងឆ្នាំ ២០៥០។ បច្ចុប្បន្ននេះ ឯកសារសំខាន់ៗចំនួនពីរបាននឹងកំពុងជំរុញការផ្លាស់ប្តូរវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍នៅកម្រិតថ្នាក់ជាតិ៖

- **គោលនយោបាយជាតិ ស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០**

គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០១៩ មានគោលបំណងពង្រឹងសមត្ថភាពថ្នាក់ជាតិលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងស្ថាប័ន និងធនធានមនុស្ស និងធ្វើឱ្យប្រព័ន្ធអេកូឡូស៊ីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ប្រសើរឡើង[16]។ យុទ្ធសាស្ត្រដែលបានបង្កើតឡើងក្នុងក្របខណ្ឌគោលនយោបាយនេះ មានគោលបំណងដើម្បី៖

- អភិវឌ្ឍធនធានមនុស្សលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទាក់ទងនឹងបរិមាណ គុណភាព និងសមាសភាព ដោយការពិចារណាលើគណនេយ្យសម្រាប់ក្រមសីលធម៌ និងសមភាពយេនឌ័រ
- បង្កើតបរិយាកាសសម្រាប់វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីបង្កើនសក្តានុពលធនធានមនុស្ស

[16] Government of the Kingdom of Cambodia. National Policy on Science, Technology and Innovation 2020-2030.
2019

- លើកកម្ពស់សមិទ្ធផល និងប្រសិទ្ធភាពនៃការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដោយការបន្សាំការប្រើប្រាស់បច្ចេកវិទ្យាទៅនឹងតម្រូវការរបស់កម្ពុជា តាមរយៈការរៀនពីបច្ចេកវិទ្យាដែលកំពុងត្រូវបានអភិវឌ្ឍនៅបរទេស
- អភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនវានុវត្តន៍ប្រកបដោយថាមវន្ត និងភាពរឹងមាំដែលអាចសំយោគបច្ចេកវិទ្យា និងវិស្វកម្មនៅក្នុងឧស្សាហកម្មអាទិភាព អនុញ្ញាតឱ្យអាជីវកម្មចូលរួមក្នុងទីផ្សារអន្តរជាតិ និងបង្កើនផលិតភាព
- បង្កើតវប្បធម៌លើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីបង្កើនទំនុកចិត្តលើការប្រើប្រាស់បច្ចេកវិទ្យាជាតិ។

- **ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា ២០៣០**

ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា ២០៣០ ដែលបានបង្កើតឡើងដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងទទួលបានការអនុម័តនៅឆ្នាំ ២០២១ មានគោលបំណងគាំទ្រដល់ការអនុវត្តគោលនយោបាយជាតិ ស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ ២០២០-២០៣០ [17]។ ផែនទីបង្ហាញផ្លូវនេះមានសសរស្តម្ភចំនួនប្រាំ ដែលសសរស្តម្ភមួយរបស់ផែនទីបង្ហាញផ្លូវផ្តោតជាពិសេសលើការស្រាវជ្រាវ។ សសរស្តម្ភទាំងប្រាំនោះ រួមមាន៖

- ពង្រឹងអភិបាលកិច្ចរបស់ប្រព័ន្ធ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- កសាងធនធានមូលធននៅក្នុងវិស័យ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ពង្រឹងសមត្ថភាពស្រាវជ្រាវ និងគុណភាពនៃការស្រាវជ្រាវ
- បង្កើតកិច្ចសហការ និងបង្កើតបណ្តាញរវាងតួអង្គពាក់ព័ន្ធ
- ជំរុញឱ្យមានប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់ការកសាងសមត្ថភាពស្រូបយកនៅក្នុងក្រុមហ៊ុន និងទាក់ទាញការវិនិយោគនៅក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ជាងនេះទៅទៀត ផែនទីបង្ហាញផ្លូវនេះមានការអភិវឌ្ឍរបៀបវារៈស្រាវជ្រាវជាតិ ដែលជាផ្នែកមួយនៃគោលបំណង និងអាទិភាពលើវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទាំងប្រាំរបស់ផែនទីបង្ហាញផ្លូវ។ គោលបំណង និងអាទិភាពទាំងនេះ រួមមាន៖

- ការបង្កើនទិន្នផលកសិកម្ម ការធ្វើពិពិត្តកម្ម និងការកែច្នៃកសិផល
- ការជំរុញការផលិតកម្ម និងវិស្វកម្មទំនើប
- ការលើកកម្ពស់វិស័យសុខាភិបាល និងជីវឱសថ
- ការលើកកម្ពស់ផ្នែកវិទ្យាសាស្ត្ររូបធាតុ និងវិស្វកម្ម

---

[17] Government of the Kingdom of Cambodia. Cambodia's Science Technology and Innovation Roadmap 2020-2030.
2021

- ការផ្តោតលើវិស័យសេវាកម្ម និងសេដ្ឋកិច្ចឌីជីថល ដោយផ្តោតលើបញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យាអវកាស និងលំហ។

### ១.៣.៣. ការអប់រំ និងឧត្តមសិក្សា

- **ផែនការមេសម្រាប់ការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំឆ្នាំ ២០១១-២០១៥**

គោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំត្រូវបានអនុម័តក្នុងឆ្នាំ២០១០ ក្នុងគោលបំណងបង្កើតទំនាក់ទំនងកាន់តែរឹងមាំរវាងការអប់រំ និងការស្រាវជ្រាវ សំដៅបង្កើនការរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើនទៅមុខ។ គោលនយោបាយនេះ បានលើកកម្ពស់វប្បធម៌ស្រាវជ្រាវ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការជាមួយបណ្តាញអន្តរជាតិ ពង្រីកសកម្មភាពនវានុវត្តន៍ និងពង្រឹងគុណភាពរបស់ឧត្តមសិក្សា។ នៅឆ្នាំ ២០១១ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តផែនការមេសម្រាប់ការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំសម្រាប់ឆ្នាំ ២០១១-២០១៥។ ផែនការនេះ មានគោលបំណងលើកកម្ពស់ការស្រាវជ្រាវ ការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ និងក្រមសីលធម៌ស្រាវជ្រាវ។

ក្នុងរយៈពេលដូចគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តគម្រោងលើកកម្ពស់គុណភាព និង សមត្ថភាពឧត្តមសិក្សាក្រោមមូលនិធិរបស់ធនាគារពិភពលោក។ តាមរយៈការគាំទ្រគ្រឹះស្ថានឧត្តមសិក្សានៅទូទាំងប្រទេស រាជរដ្ឋាភិបាលបានកំណត់គោលដៅដើម្បីបង្កើនគុណភាពបង្រៀននិងការស្រាវជ្រាវ លទ្ធភាពទទួលបានការអប់រំខ្ពស់ ព្រមទាំងការរក្សាអត្រាការបន្តសិក្សា។

- **ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៩-២០២៣**[18]

ក្រសួងអប់រំ យុវជន និងកីឡា កំពុងអនុវត្តផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៩-២០២៣ ដែលបានមកពីការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រឆ្នាំ ២០១៤-២០១៨ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រជាតិគន្លឹះទាំងបី រួមមាន ផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយ ចីរភាពកម្ពុជា។ ទាក់ទងនឹងការស្រាវជ្រាវ គោលបំណងរួមនៃផែនការនេះ បង្កើនគុណភាពនៃការស្រាវជ្រាវ ជំរុញការស្រាវជ្រាវក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា ជំរុញការអភិវឌ្ឍតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិនីយកម្ម និងការបណ្តុះបណ្តាល ព្រមទាំងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុតាមរយៈមូលនិធិមួយចំនួន ដូចជា មូលនិធិសម្រាប់ការស្រាវជ្រាវ អាហារូបករណ៍ និងការបណ្តុះបណ្តាល។

ផែនការយុទ្ធសាស្ត្រនេះមានគោលបំណងជាក់លាក់សម្រាប់អនុវិស័យនៃការអប់រំនីមួយៗ រួមមានៈ ការអប់រំសម្រាប់កុមារតូច បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការអភិវឌ្ឍយុវជន ការ

[18] Cambodia, Ministry of Education, Youth and Sport. *The Education Strategic Plan 2019-2023*. Phnom Penh, 2019.

អប់រំកាយ និងកីឡា។ គោលនយោបាយនេះ មានគោលបំណងលើកកម្ពស់លទ្ធភាពទទួលបានការអប់រំសម្រាប់យុវជនកម្ពុជា និងគុណភាពនៃសេវាកម្មអប់រំ។

ផែនការនេះពង្រឹងការស្រាវជ្រាវក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា ដោយគាំទ្រការស្រាវជ្រាវលើវិធីសាស្ត្របង្រៀន និងការអភិវឌ្ឍគោលនយោបាយផ្អែកលើការស្រាវជ្រាវ។ រាជរដ្ឋាភិបាលក៏មានគោលបំណងបង្កើតមូលនិធិស្រាវជ្រាវសម្រាប់ឧត្តមសិក្សា និងអភិវឌ្ឍភាពជាដៃគូដើម្បីបង្កើនសមត្ថភាពស្រាវជ្រាវ។ ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ គឺជាយន្តការមួយក្នុងការកែទម្រង់ការគ្រប់គ្រងការសិក្សា។ យន្តការនេះណែនាំការស្រាវជ្រាវលើការអនុវត្តក្នុងវិស័យអប់រំ និងគាំទ្រដល់អ្នកបង្កើតគោលនយោបាយក្នុងការរៀបចំគោលនយោបាយ និងស្ថាប័នស្រាវជ្រាវក្នុងការធ្វើការស្រាវជ្រាវ។ ផែនការខាងលើ ក៏បានលើកឡើងពីតួនាទីរបស់សាស្ត្រាចារ្យក្នុងកិច្ចការស្រាវជ្រាវអំពីការធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្របង្រៀន ដែលអាចលើកកម្ពស់គុណភាពនៃការងាររបស់ពួកគេ។

- **គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សាឆ្នាំ ២០៣០**[19]

គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សាឆ្នាំ ២០៣០ បានកំណត់ពីគោលបំណងរយៈពេលវែងក្នុងការលើកកម្ពស់គុណភាពនៅថ្នាក់ឧត្តមសិក្សា តាមរយៈអភិបាលកិច្ច និងយន្តការល្អដែលធានាបាននូវលទ្ធភាពទទួលបានការអប់រំឧត្តមសិក្សាប្រកបដោយគុណភាព។ លទ្ធភាពទទួលបានកាន់តែទូលំទូលាយនឹងបំពេញតម្រូវការទីផ្សារការងារកម្ពុជា និងឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាទាក់ទងទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ក្រសួងអប់រំ យុវជន និងកីឡា ក៏មានគោលបំណងបង្កើតកម្មវិធីមួយដើម្បីលើកកម្ពស់សមធម៌នូវលទ្ធភាពទទួលបានការអប់រំខ្ពស់ ការអភិវឌ្ឍជំនាញ និងឧត្តមភាពចំណេះដឹង។ ជាងនេះទៅទៀតនោះ គោលនយោបាយនេះ មានគោលបំណងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការលើកម្ពស់ការរៀន ការបង្រៀន និងគុណភាពនៃប្រព័ន្ធស្រាវជ្រាវ ព្រមទាំងកសាងប្រព័ន្ធអភិបាលកិច្ចមួយដែលអាចធ្វើឱ្យការគ្រប់គ្រងរបស់ស្ថាប័នពាក់ព័ន្ធកាន់តែមានភាពប្រសើរឡើង។ ទាក់ទងនឹងការស្រាវជ្រាវ គោលនយោបាយនេះបានកំណត់គោលបំណងដើម្បីបង្កើនគុណភាពនៃការស្រាវជ្រាវ លើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យបរទេស ជំរុញការចូលរួមរបស់បុគ្គលិក និងនិស្សិតក្នុងការអភិវឌ្ឍវប្បធម៌ស្រាវជ្រាវជាតិ និងពង្រឹងសមត្ថភាពស្រាវជ្រាវ និងនវានុវត្តន៍។

## ១.៣.៤. បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង

- **ផែនការមេបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍កម្ពុជាឆ្នាំ ២០២០**

ផែនការមេបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍កម្ពុជាឆ្នាំ ២០២០ មានគោលបំណងធ្វើឱ្យប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសកំពូលៗក្នុងតំបន់អាស៊ីអាគ្នេយ៍លើសន្ទស្សន៍វេទិកាសេដ្ឋកិច្ចពិភពលោកទាក់ទងនឹង

[19] Cambodia, Ministry of Education, Youth and Sport. Policy on Higher Education Vision 2030. Phnom Penh, 2014.

បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍កម្ពុជា។ ផែនការនេះចែកចេញជាបួនផ្នែកសំខាន់ៗ រួមមាន ការផ្តល់សិទ្ធិអំណាចដល់ប្រជាជន ការជានាការតភ្ជាប់ ការពង្រឹងសមត្ថភាព និងការពង្រឹងសេវាកម្មអេឡិចត្រូនិច។

អភិបាលកិច្ចការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវបានធ្វើសមាហរណកម្មទៅក្នុងផ្នែកពង្រឹងសមត្ថភាពនៃផែនការមេនេះ។ ផែនការមេនេះ បានសង្កត់ធ្ងន់លើតម្រូវការក្នុងការអភិវឌ្ឍឧស្សាហកម្មបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ព្រមទាំងបានលើកឡើងថា បណ្តាញស្រាវជ្រាវគឺជាគន្លឹះសម្រាប់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ជាតិដែលទាមទាឱ្យមានការអភិវឌ្ឍបន្ថែមទៀត។ ជាងនេះទៅទៀត ផែនការមេនេះណែនាំឱ្យបង្កើតបណ្តាញស្រាវជ្រាវសាកល្បងនៅក្នុងទីក្រុងធំៗ។ ផែនការមេនេះ ក៏កត់សម្គាល់ផងដែរពីបញ្ហាប្រឈមទាក់ទងនឹងស្ថានភាពការស្រាវជ្រាវ និងអភិវឌ្ឍន៍ផងដែរ ដែលរួមមាន បញ្ហាកង្វះវប្បធម៌ស្រាវជ្រាវ កន្លែងស្រាវជ្រាវនិងអភិវឌ្ឍន៍ មូលនិធិ ឧបករណ៍ និងធនធានមនុស្ស។

- **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលឆ្នាំ ២០២១-២០៣៥**

ថ្មីៗនេះ រាជរដ្ឋាភិបាលបានបង្កើតគោលនយោបាយឌីជីថល ដើម្បីដោះស្រាយបញ្ហាប្រឈម និងចាប់យកឱកាសពីបដិវត្តន៍ឧស្សាហកម្មទីបួន និងវិបត្តិនានាដែលក្នុងនោះរួមមានជំងឺរាតត្បាតកូវីដ-១៩[20]។ ក្របខណ្ឌគោលនយោបាយនេះ ផ្តោតលើបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គម។ ក្របខណ្ឌគោលនយោបាយនេះគូសបញ្ជាក់ពីបញ្ហាប្រឈមទាក់ទងនឹងភាពធន់នាពេលអនាគត ដែលអាចត្រូវបានដោះស្រាយតាមរយៈយុទ្ធសាស្ត្រឌីជីថល។ ទន្ទឹមនឹងគ្នានេះដែរ ក្របខណ្ឌគោលនយោបាយក៏បានចង្អុលបង្ហាញពីការព្រួយបារម្ភទាក់ទងនឹងការអភិវឌ្ឍមូលដ្ឋានទិន្នន័យ និងថ្នាលឌីជីថល។ ដើម្បីប្រែក្លាយប្រទេសទៅជាសេដ្ឋកិច្ចនិងសង្គមឌីជីថល ប្រទេសកម្ពុជា ត្រូវមានបរិយាកាសសមស្របនៃហេដ្ឋារចនាសម្ព័ន្ធ ភាពជឿជាក់និងទំនុកចិត្តលើប្រព័ន្ធឌីជីថល ប្រជាពលរដ្ឋរដ្ឋាភិបាល និងអាជីវកម្ម។

ខាងក្រោមនេះជាសកម្មភាពនៃក្របខណ្ឌគោលនយោបាយដែលផ្តោតលើការស្រាវជ្រាវ៖

- ចូលរួមក្នុងកិច្ចសហប្រតិបត្តិការ និងគំនិតផ្តួចផ្តើមស្រាវជ្រាវឌីជីថលអន្តរជាតិ
- បង្កើតមូលនិធិកសាងសមត្ថភាពការស្រាវជ្រាវនិងអភិវឌ្ឍន៍ នៅក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍
- កសាងសមត្ថភាពរបស់តួអង្គពាក់ព័ន្ធលើការប្រើប្រាស់ប្រព័ន្ធ និងបរិវត្តកម្មឌីជីថល តាមរយៈការស្រាវជ្រាវ និងបច្ចេកវិទ្យាឌីជីថល
- ជំរុញការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថលនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលស្រាវជ្រាវ

[20] Cambodia, Supreme National Economic Council. Cambodia Digital Economy and Society Policy Framework 2021-
2035. 2021.

- ជំរុញការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងនវានុវត្តន៍តាមរយៈភាពជាដៃគូជាមួយអាជីវកម្មដែលនឹងជំរុញឱ្យមានការផ្លាស់ប្តូរទិន្នន័យ និងចំណេះដឹង តាមរយៈការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល និងការគាំទ្រផ្នែកមូលនិធិក
- ពង្រឹងឌីជីថលូបនីយកម្មនៃឯកសារជាភាសាខ្មែរ ដើម្បីកំណត់អត្តសញ្ញាណភាសាក្នុងការស្វែងរក និងសម្រួលដល់ការវិភាគទិន្នន័យ
- បង្កើតយុទ្ធសាស្ត្រជាតិដោយលើកកម្ពស់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងនវានុវត្តន៍
- ធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃមជ្ឈមណ្ឌលស្រាវជ្រាវសាធារណៈលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ឌីជីថល បង្កើតមូលនិធិនវានុវត្តន៍ឌីជីថលដើម្បីបង្កើនការវិនិយោគរបស់អាជីវកម្មក្នុងវិស័យនេះ និងពង្រឹងការអនុវត្តគោលនយោបាយលើវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដើម្បីលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងនវានុវត្តន៍។

## ១.៣.៥. ឧស្សាហកម្ម

- **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥**

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ គឺជាឯកសារគោលនយោបាយចម្បង ដែលផ្តោតលើអនាគតនៃឧស្សាហកម្មជាតិរបស់កម្ពុជា[21]។ គោលនយោបាយនេះមានគោលបំណងផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្មតាមរយៈការពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្ម ការបង្កើនបរិមាណនៃការនាំចេញ ការធ្វើពិពិធកម្មទំនិញនាំចេញ និងការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម។ រាជរដ្ឋាភិបាលបានកំណត់វិស័យអាទិភាពចំនួន ៥ រួមមាន៖

១- ឧស្សាហកម្មថ្មី ឬការបណ្តាក់ទុនផលិតជាមួយនឹងផលិតផលមានតម្លៃបន្ថែមខ្ពស់ ដែលរាប់បញ្ចូលទាំងផលិតផលប្រើប្រាស់ ក៏ដូចជាគ្រឿងម៉ាស៊ីន មេកានិក គ្រឿងអេឡិចត្រូនិក អគ្គិសនី និងការដឹកជញ្ជូន និងការកែច្នៃធនធានធម្មជាតិ

២- សហគ្រាសធុនតូច និងមធ្យមលើគ្រប់វិស័យ ជាពិសេសផ្នែកឱសថ និងបរិក្ខារពេទ្យ សំណង់ ការវេចខ្ចប់ ការផលិតគ្រឿងសង្ហារឹម និងឧបករណ៍ឧស្សាហកម្ម

៣- ផលិតកម្មកសិឧស្សាហកម្មសម្រាប់ការនាំចេញ និងទីផ្សារក្នុងស្រុក

៤- ការគាំទ្រដល់ឧស្សាហកម្មកសិកម្ម ទេសចរណ៍ វាយនភណ្ឌ ខ្សែសង្វាក់ផលិតកម្មក្នុងតំបន់ ដែលភ្ជាប់ទៅនឹងការផ្គត់ផ្គង់វត្ថុធាតុដើម ជាពិសេសសម្រាប់វិស័យកាត់ដេរ និងការផលិតគ្រឿងបន្លាស់ និងផលិតផលពាក់កណ្តាលសម្រេច។

[21] Government of the Kingdom of Cambodia. Cambodia Industrial Development Policy 2015-2025. 2015. pp. 17.

៥- ឧស្សាហកម្មដែលគាំទ្រខ្សែផលិតកម្មក្នុងតំបន់នៃបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ថាមពល ឧស្សាហកម្មធុនធ្ងន់ សិប្បកម្មវប្បធម៌និងប្រពៃណី និងបច្ចេកវិទ្យាបៃតង។

ចំពោះការស្រាវជ្រាវ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ជំរុញការវិនិយោគក្នុងគម្រោងស្រាវជ្រាវ និងស្នើឱ្យមានការបង្កើតមូលនិធិស្រាវជ្រាវ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនេះ។ គោលនយោបាយនេះក៏មានគោលបំណងពង្រឹងសមត្ថភាពស្រាវជ្រាវស្របតាមតម្រូវការនៃបច្ចេកវិទ្យាឧស្សាហកម្មផងដែរ។ គោលនយោបាយនេះបានលើកឡើងពីការស្វែងរកដំណោះស្រាយសម្រាប់ជម្លោះឧស្សាហកម្មដើម្បីកែលម្អទំនាក់ទំនងឧស្សាហកម្ម ។ ទាក់ទងនឹងការស្រាវជ្រាវនៅគ្រឹះស្ថានឧត្តមសិក្សា គោលនយោបាយនេះលើកឡើងពីតម្រូវការក្នុងការបង្កើនគុណភាពការស្រាវជ្រាវនិងអភិវឌ្ឍន៍ ដោយការធ្វើឱ្យប្រសើរឡើងនូវគុណភាព និង លទ្ធភាពប្រើប្រាស់ឧបករណ៍។ ជាចុងក្រោយ គោលនយោបាយនេះស្នើឱ្យបង្កើតសួនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងវិទ្យាស្ថានស្រាវជ្រាវសាធារណៈមួយ។

## ១.៣.៦. កសិកម្ម

- **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣**

ផែនការយុទ្ធសាស្ត្រនេះផ្តោតលើកត្តាផ្សេងៗដើម្បីកែលម្អវិស័យកសិកម្មនាពេលអនាគត[22]។ គោលបំណងរបស់ផែនការយុទ្ធសាស្ត្រមានទំនាក់ទំនងទៅនឹងការលើកកម្ពស់ផលិតភាព ការធ្វើពាណិជ្ជកម្ម និងការធ្វើពិពិធកម្មកសិកម្ម សុខភាពសត្វនិងផលិតកម្ម ការអភិវឌ្ឍនិងការគ្រប់គ្រងវារីវប្បកម្មនិងជលផល ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយចីរភាព និងធនធានមនុស្សនិងសេវាកម្មការគាំទ្រអភិវឌ្ឍន៍ និងការគ្រប់គ្រង។

## ១.៣.៧. ការប្រែប្រួលអាកាសធាតុ

- **ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុរបស់កម្ពុជាឆ្នាំ ២០១៤-២០២៣**

ខណៈពេលដែលភាគីពាក់ព័ន្ធជាតិចាប់អារម្មណ៍កាន់តែខ្លាំងឡើងចំពោះការអភិវឌ្ឍប្រកបដោយចីរភាព ភាគីពាក់ព័ន្ធទាំងនេះទទួលស្គាល់ពីគម្លាតនៃចំណេះដឹង សមត្ថភាព និងការសម្រេចចិត្តផ្អែកលើវិទ្យាសាស្ត្រក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ផែនការយុទ្ធសាស្ត្រនេះ មានគោលបំណងបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធី និងក្របខណ្ឌជាតិដែលមានស្រាប់ ហើយបំពេញចន្លោះប្រហោងនៃគោលនយោបាយ ដោយសម្របជាមួយនឹងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យផ្សេងៗដែលត្រូវបានបង្កើតឡើងដោយក្រសួង និងទីភ្នាក់ងារជាតិផ្សេងទៀត ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងបង្កើនការចូលរួមរបស់សាធារណៈក្នុងការឈានឆ្ពោះទៅរកអភិវឌ្ឍន៍ថាមពលកាបូនទាប។ ផែនការនេះ ត្រូវបាន

---

[22] Royal Government of Cambodia. Agricultural Sector Strategic Development Plan 2019-2023. 2020.

រៀបចំជាបីដំណាក់កាល៖ រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ការស្រាវជ្រាវគឺជាស្នូលនៃដំណាក់កាលទីបី (ឆ្នាំ ២០១៩-២០២៣)[23]។

### ១.៣.៨. សុខាភិបាល

- **ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០[24]**

ក្រសួងសុខាភិបាល បានបង្កើតផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទី៣ ២០១៦-២០២០ ជាឧបករណ៍គ្រប់គ្រងយុទ្ធសាស្ត្រ ដើម្បីណែនាំស្ថាប័នសុខាភិបាលក្នុងការគ្រប់គ្រងធនធាន និងការអនុវត្តយុទ្ធសាស្ត្រសុខភាព។ការស្រាវជ្រាវគឺជាគោលបំណងយុទ្ធសាស្ត្រមួយដែលបានពិពណ៌នានៅក្នុងផែនការយុទ្ធសាស្ត្រ។ ជាក់ស្តែង ផែនការយុទ្ធសាស្ត្រនេះស្វែងរកការលើកកម្ពស់ការស្រាវជ្រាវក្នុងវិស័យសុខាភិបាល បង្កើនសមត្ថភាពស្រាវជ្រាវ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដែលមានស្រាប់សម្រាប់ការស្រាវជ្រាវ។

### ១.៣.៩. ហិរញ្ញវត្ថុ

- **ច្បាប់ស្តីពីការវិនិយោគ**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការវិនិយោគថ្មីនៅខែកុម្ភៈ ឆ្នាំ២០២១ និងត្រូវបានប្រកាសដាក់ឱ្យប្រើនៅខែតុលាឆ្នាំ២០២១[25]។ ច្បាប់នេះមានគោលបំណងបង្កើតនូវក្របខណ្ឌគតិយុត្តដើម្បីលើកកម្ពស់ដល់ការវិនិយោគក្នុងស្រុក និងបរទេសដោយផ្អែកលើគោលការណ៍បើកចំហ មានតម្លាភាពណព អាចប៉ាន់ប្រមាណទុកជាមុនបាន និងប្រកបដោយដោយអំណោយផល។ ច្បាប់នេះលើកទឹកចិត្តដល់ការវិនិយោគក្នុងវិស័យជាក់លាក់មួយចំនួន រួមមាន វិស័យឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់ដែលបង្កើតឱ្យមាននូវសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍ និងនវានុវត្តន៍។ ស្របតាមច្បាប់នេះសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍ និងនវានុវត្តន៍ ទទួលបានការលើកទឹកចិត្តផ្សេងៗពីការវិនិយោគ។

## ១.៤. បញ្ហាប្រឈមនៃការអភិវឌ្ឍដែលកម្ពុជាបានកំពុងជួបប្រទះបច្ចុប្បន្ន

ស្របតាមរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ ២០១៩ របស់ប្រទេសកម្ពុជា ស្តីពីវឌ្ឍនភាពលើការអនុវត្តរបៀបវារៈសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ រដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅអាទិភាពចំនួនប្រាំមួយ រួមមាន ការអប់រំ ការងារនិងកំណើនសមរម្យ ការកាត់បន្ថយវិសមភាព ការចាត់វិធានការលើបញ្ហាអាកាសធាតុ សន្តិភាពនិងស្ថាប័ន និងភាពជាដៃគូសម្រាប់គោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ យ៉ាងណាវិញការវាយតម្លៃលើវឌ្ឍនភាពលើការអនុវត្តអាចត្រូវបានចាត់ទុកថាជាការសន្និដ្ឋានរួមបានទេ ដោយសារតែកង្វះទិន្នន័យ។ ជាក់ស្តែង ៣៨,៧ ភាគរយនៃការអនុវត្តន៍លើគោលដៅ

---

[23] Royal Government of Cambodia. Cambodia Climate Change Strategic Plan 2014-2023. 2013.

[24] Department of Planning & Health Information. The Third Health Strategic Plan 2016-2020. 2016.

[25] Council for the Development of Cambodia. Draft Law on Investment of the Kingdom of Cambodia. 2021.

អាទិភាពគ្មានទិន្នន័យដើម្បីធ្វើការវិនិច្ឆ័យថាតើគោលដៅកំពុងត្រូវបានធ្វើឱ្យសម្រេច ខណៈពេលដែល ៤៥,៦ ភាគរយ សម្រាប់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពដែលនៅសល់[26]។

របាយការណ៍ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពរបស់សាកលវិទ្យាល័យខេមប្រ៊ីជ ឆ្នាំ២០២១ បានបង្ហាញពីការវាយតម្លៃលើវឌ្ឍនភាពរបស់ប្រទេសកម្ពុជាក្នុងការសម្រេចបាននូវគោលដៅនីមួយៗ[27]។ របាយការណ៍នេះបានបង្ហាញថា អំឡុងពេលកំពុងអនុវត្តនូវគោលដៅទាំងនោះ ប្រទេសកម្ពុជាជួបប្រទះបញ្ហាប្រឈមផ្សេងៗ លើកលែងតែគោលដៅការប្រើប្រាស់ និងផលិតកម្មប្រកបដោយការទទួលខុសត្រូវ(គោលដៅទី១២) និងសកម្មភាពលើអាកាសធាតុ (គោលដៅទី១៣) ដែលប្រទេសកម្ពុជាបានសម្រេចរួចហើយ។

ប្រទេសកម្ពុជាបានទទួលនូវកំណើនយ៉ាងច្រើនក្នុងរយៈពេល ៣០ឆ្នាំចុងក្រោយនេះទៅលើសន្ទស្សន៍[28] នៃការអភិវឌ្ឍធនធានមនុស្សរបស់ខ្លួន ដោយកើនឡើងពី ០,៣៦៨ ក្នុងឆ្នាំ១៩៩០ ទៅ ០,៥៩៤ ក្នុងឆ្នាំ២០១៩។ ចន្លោះពីឆ្នាំ១៩៩០ ទៅឆ្នាំ២០១៩ អាយុកាលសង្ឃឹមរស់ពីកំណើតរបស់កម្ពុជា កើនឡើងបន្ថែមចំនួន១៦,២ឆ្នាំមានន័យថាជាមធ្យមឆ្នាំសិក្សាកើនឡើងបន្ថែមចំនួន២.៣ឆ្នាំ,ហើយឆ្នាំដែលរំពឹងទុកនៃការសិក្សាបានកើនឡើងបន្ថែមចំនួន៤,៨ ឆ្នាំ ហើយប្រាក់ចំណូលជាតិសរុបសម្រាប់ មនុស្សម្នាក់ៗបានកើនឡើងប្រហែល ៣២១,៤ ភាគរយ។ យ៉ាងណាមិញប្រទេសកម្ពុជានៅតែស្ថិតក្នុង ចំណាត់ថ្នាក់ទី ១៤៤ ក្នុងចំណោម ១៨៩ប្រទេស[29]។

### ១.៤.១. សេដ្ឋកិច្ច (វិស័យឧស្សាហកម្ម និងសេវាកម្ម)

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ តាមរយៈការរក្សាបាននូវអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ៧,៧ភាគរយ នៅចន្លោះឆ្នាំ១៩៩៨ ដល់ ឆ្នាំ២០១៩ ដែលធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមួយដែលមានសេដ្ឋកិច្ចលូតលាស់លឿនបំផុតនៅលើពិភពលោក[30]។ ដើម្បីរក្សាកំណើននេះ និងអភិវឌ្ឍសេដ្ឋកិច្ចបន្ថែមទៀត រាជរដ្ឋាភិបាលកំពុងប្រកាន់យកនូវគោលនយោបាយសេដ្ឋកិច្ចចម្រុះដែលចាក់ឫសក្នុងកំណើនអតិបរមានិងការផ្លាស់ប្តូររចនាសម្ព័ន្ធ ព្រមជាមួយនឹងការលើកកម្ពស់និរន្តរភាព និង បរិយាបន្នផងដែរ។ ទាក់ទងនឹងភាពធន់ និងភាពគ្រប់គ្រាន់ដោយខ្លួនឯង៖

"ប្រទេសកម្ពុជាមានគោលបំណងក្នុងរយៈពេលមធ្យមដើម្បីក្លាយជាប្រទេសដែលមានភាពគ្រប់គ្រាន់ដោយខ្លួនឯងភាគច្រើននិងពឹងអស្រ័យតិចតួចលើការផ្តល់មូលនិធិ និងជំនួយ ដោយសារសេដ្ឋកិច្ចជាតិមានសមត្ថភាពក្នុងការបង្កើតការងារ មានភាពចម្រុងចម្រើននិងសុខុមាលភាពសង្គម និងផ្តល់នូវស្ថាន

---

[26] Government of the Kingdom of Cambodia. Cambodia’s Voluntary National Review 2019 on the Implementation of the 2030 Agenda for Sustainable Development. 2019. pp. 20-38

[27] Sachs et al., Sustainable Development Report 2021. Cambridge University Press. 2021. pp. 33

[28] សន្ទស្សន៍អភិវឌ្ឍន៍មនុស្សគឺជាពិន្ទុរួមដែលរួមបញ្ចូលសូចនាករស្តីពីអាយុសង្ឃឹមរស់ ការសិក្សា និងប្រាក់ចំណូល (The Human Developent Index is a composite score incorporating indicators on life expectancy, schooling and income.)

[29] United Nations Development Programme. Human Development Report, 2019.

[30] The World Bank. The World Bank in Cambodia. 2022.

ភាពអំណោយផលសម្រាប់ការអភិវឌ្ឍ។ គោលដៅនេះពឹងផ្អែកលើការអភិវឌ្ឍវិស័យឧស្សាហកម្ម ប្រកបដោយប្រសិទ្ធភាពនិងសកម្មភាពនៃការតម្លៃបន្ថែមថ្មីៗ”[31]។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា គូសបញ្ជាក់ពីសារៈសំខាន់នៃវិស័យឧស្សាហកម្ម និងសេវាកម្មដើម្បីធ្វើពិពិធកម្ម និងបង្កើនតម្លៃបន្ថែមក្នុងស្រុក[32]។ ទោះយ៉ាងណាក៏ដោយ កត្តាជាច្រើនបានកម្រិតលើការធ្វើពិពិធកម្មនេះ។ ការអភិវឌ្ឍនៃឧស្សាហកម្ម បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ត្រូវបានកម្រិតដោយសារបញ្ហាកង្វះវប្បធម៌សម្រាប់ការស្រាវជ្រាវផ្នែកបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ កង្វះមូលនិធិ កង្វះឧបករណ៍និងកង្វះធនធានមនុស្សដែលមានជំនាញ[33]។ កំណើនអាជីវកម្មត្រូវបានកម្រិតដោយកត្តាសំខាន់ពីរ គឺអាជីវកម្មក្រៅផ្លូវការនិងមិនបានចុះបញ្ជីមានចំនួនច្រើន និងធនធានមនុស្សដែលមានជំនាញមានដែនកំណត់[34]។ កត្តាផ្សេងទៀតដែលជះឥទ្ធិពលដល់កំណើនទាំងមូល រួមមាន ការសន្សំក្នុងស្រុកទាប បំណុលគ្រួសារខ្ពស់ និងសម្ពាធថ្លៃដើមខ្ពស់ ដោយសារការកើនឡើងនូវកម្រិតប្រាក់ឈ្នួល អត្រាការប្រាក់ខ្ពស់ និងថ្លៃដើមសម្រាប់ភស្តុភារការដឹកជញ្ជូន និងអគ្គិសនីមានតម្លៃខ្ពស់។

## ១.៤.២. ការអប់រំ និងជំនាញ

ការអប់រំនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះជាមួយនឹងការកើនឡើងនៃអត្រាបញ្ចប់ការសិក្សាសម្រាប់សិស្សថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ចាប់តាំងពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨។ ជាមួយគ្នានេះដែរ សមភាពយេនឌ័រក្នុងវិស័យអប់រំទាំងបឋមសិក្សាទុតិយភូមិនិងមធ្យមសិក្សាទុតិយភូមិក៏សម្រេចបានក្នុងឆ្នាំ២០១៨ ជាមួយនឹងការចុះឈ្មោះចូលរៀនមានចំនួនកុមារីច្រើន[35]។

ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីអភិវឌ្ឍធនធានមនុស្សដែលចាំបាច់សម្រាប់តម្រូវការសេដ្ឋកិច្ចបច្ចុប្បន្ន និងអនាគត ការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌និងបរិយាបន្នមានសារៈសំខាន់ណាស់សម្រាប់ការអប់រំកុមារ ការកាត់បន្ថយអត្រាបោះបង់ការសិក្សានៅពេលកុមារផ្លាស់ប្តូរកម្រិតថ្នាក់សិក្សា ការលើកកម្ពស់គុណភាពនៃការអប់រំគ្រប់កម្រិត និងការផ្តល់ឱកាសកាន់តែច្រើនសម្រាប់ការរៀនសូត្រពេញមួយជីវិត។

បញ្ហាសំខាន់ៗនៅតែមាននៅកម្រិតវិទ្យាល័យ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដែលជាស្ថាប័នបណ្តុះបណ្តាលសំខាន់សម្រាប់ការអភិវឌ្ឍឧស្សាហកម្មនិងនវានុវត្តន៍[36]។ ស្ថាប័នអប់រំនិងបណ្តុះបណ្តាល

---

31 Government of Cambodia. Cambodia’s Voluntary National Review 2019 of the Implementation of the 2030 Agenda for Sustainable Development. 2019.

32 Government of Cambodia, Rectangular Strategy for Growth, Employment, Equity and Efficiency: Building the Foundation Toward Realizing the Cambodia Vision 2050. 2018.

33 Royal University of Phnom Penh. Information and Communication Technology Policy 2017-2020. 2017.

34 Government of Cambodia. Cambodia’s Voluntary National Review 2019 on the Implementation of the 2030 Agenda for Sustainable Development. 2019.

35 Ibid.

36 Government of Cambodia. Rectangular Strategy for Growth, Employment, Equity and Efficiency: Building the Foundation Toward Realizing the Cambodia Vision 2050. 2018.

បច្ចេកទេសនិងវិជ្ជាជីវៈ (ជីវេត) ប្រឈមមុខនឹងបញ្ហាទាក់ទងនឹងតម្រូវការ (ជីវេតមានការអំពាវនាវតិចតួចដល់ប្រជាជនទូទៅបើធៀបនឹងឧត្តមសិក្សា) និងបញ្ហាទាក់ទងនឹងការផ្គត់ផ្គង់ (គុណភាពរបស់ជីវេតមិនទាន់គ្រប់គ្រាន់នៅឡើយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្ម ហើយមានទំនាក់ទំនងតិចតួចជាមួយស្ថាប័នអប់រំដទៃទៀត)[37]។ លើសពីនេះ កម្ពុជាមានអត្រាអក្ខរកម្មមនុស្សពេញវ័យទាបបំផុតក្នុងប្រទេសអាស៊ាន (៨២,៥ ភាគរយ ក្នុងឆ្នាំ ២០១៧)[38]។

### ១.៤.៣. សុខាភិបាល

ប្រទេសកម្ពុជាមានភាពជឿនលឿនក្នុងការផ្តល់សេវាសុខភាព តាមរយៈការពង្រីកចំនួនបរិក្ខារពេទ្យ និងការគ្របដណ្តប់ប្រព័ន្ធសេវាគាំពារសុខភាពសង្គម។ អាយុរំពឹងរស់បានកើនពី៦១.០ឆ្នាំ នៅឆ្នាំ២០០៥ ដល់ ៧០.៦ឆ្នាំក្នុងឆ្នាំ២០១៨។ ទោះបីយ៉ាងណាក៏ដោយ កម្ពុជានៅតែស្ថិតក្នុងចំណាត់ថ្នាក់ទាបបំផុតទី៣ ក្នុងចំណោមប្រទេសសមាជិកអាស៊ាន។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាតម្រូវឱ្យមានការធ្វើឱ្យប្រសើរឡើងនូវសូចនាករសុខភាពសាធារណៈសំខាន់ៗជាច្រើន ដូចជា ការចាក់ថ្នាំបង្ការសម្រាប់កុមារ និងការទទួលបានទឹកបរិភោគដែលមានសុវត្ថិភាព ដោយសារ ចំនួនប្រជាជនសរុបដែលទទួលបានទឹកស្អាតប្រើប្រាស់មានត្រឹមតែ៦៥% ប៉ុណ្ណោះក្នុងឆ្នាំ ២០១៨[39]។

យោងតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ គុណភាពនៃប្រព័ន្ធសុខាភិបាលនៅកម្ពុជានៅមានបញ្ហាប្រឈមជាច្រើន ដូចជា ប្រព័ន្ធសេវាថែទាំសុខាភិបាលជាតិមិនទាន់មានប្រសិទ្ធភាពពេញលេញក្នុងការផ្តល់សេវាកម្ម ហិរញ្ញវត្ថុ និងការគ្របដណ្តប់ដល់ប្រជាជននៅឡើយ។ ខណៈពេលតម្រូវការផ្នែកសុខាភិបាលកំពុងមានការផ្លាស់ប្តូរ ប៉ុន្តែការស្រាវជ្រាវ ធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធមិនទាន់បានឆ្លើយតបពេញលេញទៅនឹងតម្រូវការ។ ប្រជាជនកម្ពុជានៅតែរងគ្រោះដោយជំងឺ ដោយសារការស្រាវជ្រាវមិនទាន់មានប្រសិទ្ធភាព។ ដូច្នេះការវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលរួមទាំងបច្ចេកវិទ្យា និងប្រព័ន្ធព័ត៌មានគឺជាតម្រូវការចាំបាច់[40]។

ជំងឺកូវីដ-១៩ បានលាតត្រដាងសមត្ថភាពការថែទាំសុខភាពទូទាំងពិភពលោកតាមរបៀបដែលមិនធ្លាប់មានពីមុនមក ហើយកម្ពុជាបានអនុវត្តក្របខណ្ឌអ្នកជំងឺថ្នាក់ជាតិដោយមានរួមបញ្ចូលការព្យាបាលថែទាំតាមផ្ទះ ដើម្បីជួយកាត់បន្ថយហានិភ័យនៃមេរោគ។ ក្របខណ្ឌនេះត្រូវបានណែនាំឱ្យមានការកំណត់គោលបំណងនៃការរៀបចំហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាពឡើងវិញ ដោយផ្អែកលើភាពធ្ងន់ធ្ងរនៃករណី និងការបន្ថែម

[37] United Nations Educational, Scientific and Cultural Organization. TVET country profile: Cambodia. 2020.
[38] Association of Southeast Asian Nations ASEAN key figures. 2019.
[39] Ibid.
[40] Government of the Kingdom of Cambodia. Cambodia’s Voluntary National Review 2019 on the Implementation of the 2030 Agenda for Sustainable Development. 2019.

សម្ភារៈបរិក្ខារវេជ្ជសាស្ត្របណ្តោះអាសន្នដើម្បីជួយធ្វើឱ្យមានតុល្យភាពក្នុងការឆ្លើយតបទៅនឹងការកើនឡើងនៃករណី[41]។

### ១.៤.៤. អាហារ ទឹក កសិកម្ម និងដី

កំណើនប្រជាជន នគរូបនីយកម្ម និងការធ្វើចំណាកស្រុក គឺជាគុណវិបត្តិចម្បងដែលរារាំងដល់ប្រទេសកម្ពុជាពីវឌ្ឍនភាពកាន់តែលឿនចំពោះគោលដៅអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់ផ្នែកអាហារ និងទឹក។ ពីរភាគបីនៃ ប្រជាជនកម្ពុជារស់នៅក្នុងតំបន់ជនបទ ហើយវិស័យកសិកម្មនៅតែជាវិស័យមួយដែលដើរតួនាទីសំខាន់នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) របស់ជាតិ (ប្រហែលមួយភាគបួននៃផ.ស.ស.)។ ទោះជាយ៉ាងណាក៏ដោយ ដីប្រកបដោយផលិតភាពត្រូវបានប្រើប្រាស់ជាចម្បងសម្រាប់ការផលិតស្រូវ ខណៈដែលបន្លែនិងផ្លែឈើជាច្រើនត្រូវបាននាំចូល[42]។ គុណភាពរបបអាហាររបស់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ៥ ឆ្នាំនៅតែមិនគ្រប់គ្រាន់ ហើយអត្រាក្រិសក្រិនរបស់កុមារនៅមានកម្រិតខ្ពស់។ ក្នុងឆ្នាំ ២០១៤ កុមារកម្ពុជាអាយុក្រោម ៥ឆ្នាំ មានចំនួន ៣២% បានក្រិសក្រិន ហើយនៅតាមតំបន់ជនបទមានអាត្រាក្រិសក្រិនខ្ពស់ជាងនៅតាមទីប្រជុំជន។ ទិន្នន័យបង្ហាញថា ប្រទេសកម្ពុជាបានទទួលជោគជ័យសម្រាប់ការបង្កើនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធជនបទ ការស្រាវជ្រាវផ្នែកកសិកម្ម និងការពង្រីកសេវាកម្មបន្ថែមស្របតាមទិសដៅក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា។ ប៉ុន្តែ បញ្ហាការខ្វះខាតទិន្នន័យបានរារាំងដល់ការតាមដានវឌ្ឍនភាពរបស់កម្ពុជាក្នុងវិស័យផ្សេងទៀតដែលទាក់ទងនឹងអាហារ ដូចជា អត្រាកង្វះអាហារូបត្ថម្ភ ផលិតភាពកសិកម្មរបស់អ្នកផលិតអាហារខ្នាតតូច និងផលិតកម្មអាហារប្រកបដោយចីរភាព។ ការកែលម្អ និងវិនិយោគក្នុងវិស័យកសិកម្មនឹងធ្វើឱ្យមានការងារកាន់តែច្រើន ការធានាសន្តិសុខស្បៀងកាន់តែខ្ពស់ និងការកាត់បន្ថយគម្លាតប្រាក់ចំណូលរវាងតំបន់ជនបទ និង ទីក្រុង។

### ១.៤.៥. បរិស្ថាន និងចីរភាព

បញ្ហាប្រឈមផ្នែកបរិស្ថានដ៏សំខាន់មួយសម្រាប់ប្រទេសកម្ពុជា គឺភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ។ កម្ពុជាស្ថិតក្នុងចំណោមប្រទេសងាយរងគ្រោះបំផុតក្នុងពិភពលោកដែលរងផលប៉ះពាល់ដោយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតដែលមិនអាចទាយទុកមុនបាន[43]។ រាជរដ្ឋាភិបាលបាននិងកំពុងដើរលើមាគ៌ាស្របតាមគោលដៅរបស់ខ្លួនសម្រាប់ការបង្កើនការចំណាយសាធារណៈលើការប្រែប្រួលអាកាសធាតុជាមធ្យម ១% ក្នុងមួយឆ្នាំ (គោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា ១៣.២.២) នៅក្នុងផ្នែកនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣[44]។ ជាងនេះទៅទៀត វិធានការកំពុងត្រូវបានអនុវត្តដើម្បីបង្កើន ការដាំកូនឈើឡើងវិញដើម្បីទប់ទល់នឹងផលប៉ះពាល់អវិជ្ជមានយ៉ាងឆាប់រហ័សនៃ

---

[41] World Health Organization. 2021 Annual Report WHO’s Response to COVID-19. Geneva. 2022.

[42] Government of the Kingdom of Cambodia. Cambodia’s Voluntary National Review 2019 on the Implementation of the 2030 Agenda for Sustainable Development. 2019.

[43] United Nations Development Programme. Cambodia adapts to climate change. 2019.

[44] Government of Cambodia. Cambodia’s Voluntary National Review 2019 on the Implementation of the 2030 Agenda for Sustainable Development. 2019.

ឧស្សាហូបនីយកម្ម និង នគរូបនីយកម្មមកលើធនធានធម្មជាតិរបស់ប្រទេស។ ទោះជាយ៉ាងណាក៏ដោយ គំនិតផ្តួចផ្តើមផ្សេងទៀតទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន នឹងត្រូវបានទាមទារឱ្យមានដើម្បីធ្វើឱ្យប្រសើរឡើងនូវចីរភាព[45]។

[45] Government of Cambodia. Rectangular Strategy for Growth, Employment, Equity and Efficiency: Building the Foundation Toward Realizing the Cambodia Vision 2050. 2018.

# ជំពូកទី ២

# ការវិភាគលើប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ

ប្រព័ន្ធស្រាវជ្រាវរបស់កម្ពុជាបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលរៀបចំរបាយការណ៍ ហើយរបាយការណ៍នេះគឺជាការព្យាយាមដំបូងមួយក្នុងការកំណត់ជាប្រព័ន្ធនូវផែនទីនៃស្ថាប័នដែលមានស្រាប់និងមានលក្ខណៈគ្រប់គ្រាន់សម្រាប់អាណត្តិ គោលបំណង និងសកម្មភាពរបស់ពួកគេ[46]។ ប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវកម្ពុជាអាចត្រូវបានបង្ហាញជាផ្នែកចំនួនប្រាំបួន (មើលរូបភាពទី ២.១)៖

រូបភាព ២. ១៖ ប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវ




ផ្នែកបន្ទាប់ខាងក្រោម ជាការវិភាគធាតុផ្សំនីមួយៗ ដើម្បីផ្តល់នូវរូបភាពលម្អិតនៃប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវនៅកម្ពុជា។

[46] For another comprehensive study of research in Cambodia see: Cambodian Institute for Cooperation and Peace.
(2016). Doing Research in Cambodia: Making Models that Build Capacity. Available at https://cicp.org.kh/publications/doing-research-in-cambodia-making-models-that-build-capacity/

## ២.១. ស្ថាប័នស្រាវជ្រាវ

### ២.១.១. ស្ថាប័នស្រាវជ្រាវសំខាន់ៗនៅកម្ពុជា

នៅកម្ពុជា មានប្រភេទស្ថាប័នផ្សេងៗជាច្រើនកំពុងផលិតការស្រាវជ្រាវ។ ទោះជាយ៉ាងណាក៏ដោយ ពុំមានការចាត់ថ្នាក់តាមស្តង់ដារ ឬឯកសារយុទ្ធសាស្ត្រដែលបង្ហាញពីប្រភេទផ្សេងៗនៃស្ថាប័នស្រាវជ្រាវនោះទេ។ ខាងក្រោមនេះជាស្ថាប័នសំខាន់ៗដែលធ្វើការស្រាវជ្រាវនៅកម្ពុជា៖

**សាកលវិទ្យាល័យ និងគ្រឹះស្ថានឧត្តមសិក្សា (HEIs) ផ្សេងៗ៖** គិតត្រឹមឆ្នាំ២០១៨ នៅក្នុងប្រទេសកម្ពុជា មានគ្រឹះស្ថានឧត្តមសិក្សាចំនួន ១២៥ ដែលចំនួន៤៨ ជាគ្រឹះស្ថានសាធារណៈ និងចំនួន៧៧ ជាគ្រឹះស្ថានឯកជន[47]។ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ជាធម្មតាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងនានាដែលពាក់ព័ន្ធតាមមុខជំនាញ ដូចបង្ហាញក្នុងតារាងទី ២.១។

**តារាង ២. ១៖** គ្រឹះស្ថានឧត្តមសិក្សា( សាធារណៈ និងឯកជន ) និងក្រសួងដែលត្រួតពិនិត្យពួកគេ ( ឆ្នាំសិក្សា ២០១៨-២០១៩ )

| ក្រសួង ឬស្ថាប័នសាធារណៈ | ចំនួនគ្រឹះស្ថានឧត្តមសិក្សាសាធារណៈដែលខ្លួនគ្រប់គ្រង | ចំនួនគ្រឹះស្ថានអប់រំឧត្តមសិក្សាឯកជនដែលខ្លួនគ្រប់គ្រង |
|---|---|---|
| ក្រសួងអប់រំ យុវជន និងកីឡា | ១៣ | ៦៣ |
| ក្រសួងសុខាភិបាល | ២ | 0 |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១ | 0 |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣ | 0 |
| ក្រសួងធម្មការ និងសាសនា | ៣ | 0 |
| ក្រសួងការពារជាតិ | ៥ | 0 |
| ក្រសួងមហាផ្ទៃ | ១ | 0 |
| ទីស្តីការគណៈរដ្ឋមន្ត្រី | ១ | 0 |
| ក្រសួងសាធារណការ និងដឹកជញ្ជូន | ១ | 0 |
| ធនាគារជាតិនៃកម្ពុជា | ១ | 0 |
| ក្រសួងរ៉ែ និងថាមពល | ១ | 0 |

[47] Ministry of Education, Youth and Sport. Education Congress 2018-2019. The education, youth and sport performance in the academic year 2017-2018 and goals for the academic year 2018-2019. 2019.

| ក្រសួង ឬស្ថាប័នសាធារណៈ | ចំនួនគ្រឹះស្ថានឧត្តមសិក្សាសាធារណៈដែលខ្លួនគ្រប់គ្រង | ចំនួនគ្រឹះស្ថានអប់រំឧត្តមសិក្សាឯកជនដែលខ្លួនគ្រប់គ្រង |
|---|---|---|
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១២ | ១៤ |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១ | ០ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ | ០ |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១ | ០ |

**ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា (២០១៦)**

សាកលវិទ្យាល័យក្នុងប្រទេសកម្ពុជា មានភាពខុសប្លែកពីគ្រឹះស្ថានឧត្តមសិក្សាដទៃទៀត ដោយសារការផ្តល់មុខវិជ្ជាពហុជំនាញនៃការសិក្សាចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅមានធនធានបង្រៀនអប្បបរមា (បុគ្គលិកបង្រៀន និងហេដ្ឋារចនាសម្ព័ន្ធ) និងមានមហាវិទ្យាល័យចាំបាច់ចំនួនបីគឺ (១) សិល្បៈ មនុស្សសាស្ត្រ និងភាសា (២) គណិតវិទ្យា និងវិទ្យាសាស្ត្រ (៣) វិទ្យាសាស្ត្រសង្គម និងយ៉ាងហោចណាស់មានមហាវិទ្យាល័យផ្សេងទៀតចំនួនពីរ។

## ២.២. ប្រធានបទស្រាវជ្រាវ

### ២.២.១. បញ្ហាប្រឈមនៃការអភិវឌ្ឍដែលត្រូវដោះស្រាយដោយការស្រាវជ្រាវ

ទិសដៅសម្រាប់ការស្រាវជ្រាវ សំដៅលើការកំណត់នៃការផ្តោតសំខាន់ឆ្ពោះទៅរកប្រធានបទ ឬផលប្រយោជន៍ជាក់លាក់ដែលជាតម្រូវការសង្គម ឬជាតិ ហើយតម្រង់ឆ្ពោះទៅរកបញ្ហាប្រឈមក្នុងសង្គម[48]។ ការណ៍នេះធានាថាធនធានដែលបានបម្រុងទុកសម្រាប់ការស្រាវជ្រាវត្រូវបានបំប្លែងជាអតិបរមាទៅជាផលជះសម្រាប់សង្គមពី ការវិនិយោគសាធារណៈ។ ដើម្បីសម្រេចបាននូវចំណុចនេះ អ្នកស្រាវជ្រាវគួរតែត្រូវបានលើកទឹកចិត្ត ឬតម្រង់ទិសទៅរកប្រធានបទស្រាវជ្រាវដែលស្របតាមផលប្រយោជន៍ជាតិ។ យុទ្ធសាស្ត្រមួយដើម្បីដឹកនាំការស្រាវជ្រាវនៅថ្នាក់ជាតិគឺការអភិវឌ្ឍបេសកកម្មស្រាវជ្រាវ។ បេសកកម្មគឺជាឧបករណ៍ដ៏មានអានុភាពដែលផ្តល់ជាមធ្យោបាយដើម្បីផ្តោតលើការស្រាវជ្រាវ នវានុវត្តន៍ និងការវិនិយោគលើការដោះស្រាយបញ្ហាសំខាន់ៗ។ ពួកគេអាចពង្រឹងសមត្ថភាពរបស់កម្ពុជាក្នុងការទាញយកថាមពលនៃការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីសម្រេចបាននូវគោលដៅសេដ្ឋកិច្ច និងសង្គមកាន់តែទូលំទូលាយ[49]។ នេះបង្ហាញពីទិដ្ឋភាពទូទៅនៃអាទិភាពត្រួតស៊ីគ្នានៃផលប្រយោជន៍ជាតិដោយផ្អែកលើក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា គោលនយោបាយ និងយុទ្ធសាស្ត្រជាតិសំខាន់ៗផ្សេងទៀត។ដោយផ្អែកលើតារាងទី ២ ការអប់រំ ឧស្សាហូបនីយកម្មប្រកបដោយចីរភាព

[48] United Nations Economic and Social Commission for Asia and the Pacific. Frontiers of Inclusive Innovation: Formulating Technology and Innovative Policies that Leave No One Behind. 2021.
[49] Mazzucato. Mission-oriented research and innovation in the European Union. 2018.

និងបរិយាបន្ន ការលើកកម្ពស់ នវានុវត្តន៍ សមភាពយេនឌ័រ ការគ្រប់គ្រងទឹកប្រកបដោយចីរភាព និងការទប់ស្កាត់ការប្រែប្រួលអាកាសធាតុគឺជាប្រធានបទដែលមានសារៈសំខាន់ជាយុទ្ធសាស្ត្រខ្ពស់សម្រាប់កម្ពុជា។

ជាងនេះទៅទៀត ការស្ទង់មតិរបស់ ESCAP ក៏បានសួរអ្នកពាក់ព័ន្ធអំពីបញ្ហាប្រឈមនៃការអភិវឌ្ឍដែលត្រូវដោះស្រាយជាបន្ទាន់ដោយការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាផងដែរ៖ ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមដែលលើកឡើងច្រើនជាងគេ បន្ទាប់មកគឺការស្តារសេដ្ឋកិច្ចឡើងវិញពីជំងឺកូវីដ-១៩។ ការពិចារណាបែបនេះគួរតែត្រូវបានធ្វើឡើងដើម្បីបង្កើតបេសកកម្មជាក់ស្តែងជាបន្តបន្ទាប់សម្រាប់ប្រទេសកម្ពុជាដែលនឹងតម្រង់ទិសអ្នកស្រាវជ្រាវក្នុងការជ្រើសរើសប្រធានបទស្រាវជ្រាវ។

### ២.២.២. ប្រធានបទស្រាវជ្រាវ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអភិវឌ្ឍ

យោងតាមចម្លើយនៃការស្ទង់មតិរបស់ ESCAP ប្រធានបទដែលកំពុងស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នបានឆ្លើយតបតែផ្នែកខ្លះប៉ុណ្ណោះចំពោះបញ្ហាដែលប្រទេសជាតិជួបប្រទះ។ ជាឧទាហរណ៍ ការស្រាវជ្រាវកសិកម្ម អាចដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ ដែលអនុញ្ញាតឱ្យមានផលិតផល និងការអនុវត្តប្រកបដោយនិរន្តរភាពជាងមុន។ ទោះជាយ៉ាងណាក៏ដោយ ការប្រែប្រួលអាកាសធាតុគឺជាបញ្ហាប្រឈមដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា ហើយអ្នកឆ្លើយសំណួរបានកត់សម្គាល់ថា ការស្រាវជ្រាវបន្ថែមទៀតនៅតែត្រូវការដើម្បីគាំទ្រផលិតផល និងការអនុវត្តដែលស្អាតជាង សុវត្ថិភាពជាង មាននិរន្តរភាព និងការប្រកួតប្រជែង។

ដូចដែលបានបង្ហាញក្នុងរូបភាពទី ២.២ ប្រធានបទស្រាវជ្រាវដែលត្រូវបានបោះឆ្នោតជ្រើសរើសច្រើនជាងគេក្នុងចំណោមអ្នកឆ្លើយសំណួររបស់ ESCAP គឺ "កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" "វិស្វកម្មអគ្គិសនី និងមេកានិច" "ការស្រាវជ្រាវវេជ្ជសាស្ត្រជាមូលដ្ឋាន" និង "វិស្វកម្មបរិស្ថាន" ។

**រូបភាព ២.២៖** ប្រធានបទស្រាវជ្រាវភាគច្រើននាពេលបច្ចុប្បន្ននៅកម្ពុជា និងប្រធានបទស្រាវជ្រាវដែលគួរតែជាអាទិភាពនៃរបៀបវារៈស្រាវជ្រាវជាតិឆ្នាំ២០២៥ យោងទៅតាមសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវ




**ប្រភព៖ ការស្ទង់មតិរបស់ ESCAP**

គួរកត់សម្គាល់ថា ប្រធានបទបច្ចុប្បន្នដែលលើកឡើងដោយមន្ត្រីរាជរដ្ឋាភិបាលមកពីក្រសួងនានា (រូបភាព ២.៣) ថាមានសារៈសំខាន់បំផុតសម្រាប់ពួកគេ គឺខុសពីប្រធានបទដែលស្រាវជ្រាវដោយសាកលវិទ្យាល័យ/វិទ្យាស្ថានស្រាវជ្រាវ និងវិស័យឯកជននាពេលបច្ចុប្បន្ន។ មន្ត្រីរាជរដ្ឋាភិបាលបានរាយការណ៍ថា ប្រធានបទសំខាន់បំផុតនៅក្នុងបេសកកម្មរបស់ពួកគេគឺ "សេដ្ឋកិច្ច និងធុរកិច្ច" បន្ទាប់មកគឺ "កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ"។ ទោះយ៉ាងណាក៏ដោយ ទាក់ទងនឹងបញ្ហាប្រឈមនាពេលអនាគតសម្រាប់ឆ្នាំ២០២៥ មានការយល់ស្របគ្នាមួយក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់គឺទៅលើ "កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ"។

**រូបភាព ២. ៣៖ ប្រធានបទស្រាវជ្រាវភាគច្រើននាពេលបច្ចុប្បន្ននៅកម្ពុជា និងប្រធានបទស្រាវជ្រាវដែលគួរតែជាអាទិភាព**




**ប្រភព៖ ការស្ទង់មតិរបស់ ESCAP**

### ២.២.៣. ប្រធានបទកំពុងបង្រៀនតាមគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា

កម្មវិធីសិក្សាថ្នាក់ឧត្តមសិក្សាត្រូវតែស្របតាមប្រធានបទស្រាវជ្រាវយុទ្ធសាស្ត្រ ដើម្បីធានាថាសមត្ថភាពស្រាវជ្រាវត្រូវបានបង្កើតឡើងក្នុងផ្នែកសំខាន់ៗសម្រាប់កម្ពុជា។ បច្ចុប្បន្ននេះ មានការលើកឡើងថា កម្មវិធីសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជាត្រូវបានជះឥទ្ធិពលហួសហេតុដោយផលប្រយោជន៍ពាណិជ្ជកម្មឯកជន និងអ្នកវិនិយោគអន្តរជាតិ[50] ជាជាងផលប្រយោជន៍ជាតិជាធំ ដូចជាការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការអភិវឌ្ឍនៃកម្លាំងពលកម្មជំនាញ។ មានភាពមិនស៊ីចង្វាក់គ្នារវាងជំនាញ និងចំណេះដឹងដែលបង្កើតឡើងដោយគ្រឹះស្ថានឧត្តមសិក្សា និងជំនាញដែលទាមទារដោយនិយោជក និងទីផ្សារជាទូទៅ[51]។ កម្ពុជាខ្វះអ្នកជំនាញដែលមានសមត្ថភាពលើមុខជំនាញដូចជា កសិកម្ម គណិតវិទ្យា និងវិទ្យាសាស្ត្រ។ ក្នុងឆ្នាំ ២០១៧-២០១៨ មាននិស្សិតថ្នាក់បរិញ្ញាបត្រតែ ៣ ភាគរយប៉ុណ្ណោះកំពុងសិក្សាផ្នែកកសិកម្ម ហើយ ២៧ ភាគរយកំពុងសិក្សា

[50] International Institute for Asian Studies. The politics of higher education in Cambodia. 2017
[51] Madhur. Cambodia’s skill gap: An anatomy of issues and policy options. 2014.

មុខវិជ្ជាស្នែម ខណៈដែល ៤២ ភាគរយកំពុងសិក្សាមុខវិជ្ជាធុរកិច្ច។ គួរកត់សម្គាល់ថាចំនួនសិស្សដែលបានចុះឈ្មោះក្នុងមុខវិជ្ជាស្នែម គឺស្ថិតក្នុងនិន្នាការកើនឡើង ពោលគឺកើនឡើងពី ១៨ ភាគរយក្នុងឆ្នាំ ២០១២-២០១៣។ ទោះជាយ៉ាងណាក៏ដោយ ចំនួននេះនៅតែទាបជាងតម្រូវការទីផ្សារ។[52]

[52] Ministry of Education, Youth and Sport. Education Congress. 2019.

តារាង ២.២៖ យុទ្ធសាស្ត្រជាតិដែលបានកំណត់អាទិភាព ស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា

| **គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា** | យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ | គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០ | គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ | ផែនការមេ ICT កម្ពុជាឆ្នាំ ២០២០ | ផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ ២០១៩-២០២៣ | ការអភិវឌ្ឍផែនការមេផលិតភាពជាតិសម្រាប់កម្ពុជាឆ្នាំ ២០២០-២០៣០ |
|---|---|---|---|---|---|---|---|
| គោលដៅទី១៖ បញ្ចប់ភាពក្រីក្រ គ្រប់ទម្រង់ នៅគ្រប់ទីកន្លែង | | X | | | | | |
| គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព | X | X | | | | | |
| គោលដៅទី៣៖ ធានាឱ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូប និងគ្រប់វ័យ | X | X | | | | | |
| គោលដៅទី៤៖ ធានាការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ និងលើក | X | X | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| កម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិត សម្រាប់ប្រជាជនគ្រប់រូប | | | | | | | |
| គោលដៅទី៥៖ សម្រេចឱ្យបានសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចរបស់ស្ត្រី និងកុមារីគ្រប់រូប | X | X | X | | | X | |
| គោលដៅទី៦៖ ធានាឱ្យមានទឹកនិងអនាម័យ និងការគ្រប់គ្រងទឹកនិងអនាម័យ ប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប | X | X | | X | | X | |
| គោលដៅទី៧៖ ធានាឱ្យទទួលបានថាមពលដែលមានលក្ខណៈបច្ចេកទេសទំនើប ប្រកបដោយចីរភាព អាចជឿជាក់បាន និងមានតម្លៃសមរម្យសម្រាប់ប្រជាជនគ្រប់រូប | X | X | | X | | | |
| គោលដៅទី៨៖ ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន មានមុខរបរពេញលេញ និងផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប | | X | | | | X | X |
| គោលដៅទី៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងបម្រែបម្រួលអាកាសធាតុ លើកកម្ពស់ | X | X | X | X | X | X | X |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឧស្សាហូបនីយកម្មប្រកបដោយចីរភាព និងបរិយាបន្ន និងលើកកម្ពស់នវានុវត្តន៍ | | | | | | | |
| គោលដៅទី១០៖ កាត់បន្ថយវិសមភាពនៅក្នុងប្រទេស និងក្នុងចំណោមបណ្ដាប្រទេសនានា | | | | | | | |
| គោលដៅទី១១៖ ធ្វើធ្វើឱ្យទីក្រុង និងទីកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈបរិយាបន្ន សុវត្ថិភាព ធន់នឹងបម្រែបម្រួលអាកាសធាតុនិងចីរភាព | | | | | | | |
| គោលដៅទី១២៖ ធានាឱ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់ និងផលិតកម្ម | | X | X | | X | | |
| គោលដៅទី១៣៖ ចាត់វិធានការជាបន្ទាន់ដើម្បីប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា | | X | X | X | X | | |
| គោលដៅទី១៤៖ អភិរក្ស និងប្រើប្រាស់ប្រកបដោយចីរភាពនូវមហាសមុទ្រ សមុទ្រ និងធនធានសមុទ្រសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព | | X | | | | | |
| គោលដៅទី១៥៖ ការពារ ស្ដារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូ | | X | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ស៊ីលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព  ប្រយុទ្ធប្រឆាំងនឹងឱនភាពដី បញ្ឈប់ និងបង្វែរទិសនៃការសឹករិចរឹលគុណភាពដី និងបញ្ឈប់កុំឱ្យបាត់បង់ជីជាតិដី និងជីវៈចម្រុះ | | | | | | | |
| គោលដៅទី១៦៖ លើកកម្ពស់សង្គមដែលមានសន្តិភាព ប្រកបដោយបរិយាបន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ននៅគ្រប់កម្រិត | | X | | | | | |
| គោលដៅទី១៧៖ ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាពរស់រវើក នូវភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព | | | | X | | | |
| គោលដៅទី១៨៖ បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ | | | | | | | |

**ប្រភព៖ យោងលើឯកសារគោលនយោបាយជាតិផ្សេងៗរបស់កម្ពុជា**

## ២.៣. អ្នកស្រាវជ្រាវ

### ២.៣.១. អ្នកស្រាវជ្រាវ

ក្នុងឆ្នាំ២០១៥ កម្ពុជាមានអ្នកស្រាវជ្រាវសមមូលពេញម៉ោងត្រឹមតែ៣០នាក់ប៉ុណ្ណោះក្នុងចំណោមប្រជាជនមួយលាននាក់ដែលធ្វើការផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ (តារាង ២.៣)[53]។ មានន័យថាអ្នកស្រាវជ្រាវសមមូលពេញម៉ោងមានចំនួនតិចជាង៥០០នាក់នៅក្នុងប្រទេស ដែលជាឧបសគ្គដល់ការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវជាតិ។

**តារាង ២. ៣៖** ចំនួនអ្នកស្រាវជ្រាវក្នុងមួយលាននាក់នៅក្នុងបណ្តាប្រទេសអាស៊ាន

| ប្រទេស | ឆ្នាំនៃទិន្នន័យថ្មីៗបំផុត | អ្នកស្រាវជ្រាវសមមូលពេញម៉ោងក្នុងមួយលាននាក់ |
|---|---|---|
| ប្រ៊ុយណេ | គ្មាន | គ្មានទិន្នន័យ |
| កម្ពុជា | ២០១៥ | ៣០ |
| ឥណ្ឌូណេស៊ី | ២០១៨ | ២១៦ |
| សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | គ្មាន | គ្មានទិន្នន័យ |
| ម៉ាឡេស៊ី | ២០១៦ | ២ ៣៩៧ |
| មីយ៉ាន់ម៉ា | ២០១៧ | ២៩ |
| ហ្វីលីពីន | ២០១៦ | ១០៦ |
| សិង្ហបុរី | ២០១៧ | ៦០៨៣ |
| ថៃ | ២០១៨ | ១ ៣៥០ |
| វៀតណាម | ២០១៨ | ៧០៨ |

**ប្រភព៖ របាយការណ៍វិទ្យាសាស្ត្រយូណេស្កូ**

ការងារក្នុងវិស័យអប់រំមិនត្រូវបានគេចាត់ទុកថាមានភាពទាក់ទាញនោះទេ ដោយសារតែបន្ទុកការងារខ្ពស់ ប្រាក់ឈ្នួលទាប កង្វះឱកាសអភិវឌ្ឍវិជ្ជាជីវៈ និងកង្វះការទទួលស្គាល់[54]។ ម្យ៉ាងវិញទៀត មុខតំណែងជាអ្នកស្រាវជ្រាវដែលមិនស្ថិតក្នុងវិស័យអប់រំមានតិចតួចប៉ុណ្ណោះ។ ក្នុងឆ្នាំ២០១៥ អ្នកស្រាវជ្រាវ ៤,៣% បានធ្វើ

[53] United Nations Educational, Scientific and Cultural Organization, UNESCO Institute for Statistics. 2021.

[54] Ros. V., Olksiyenko. A. Policy Misalignments and Development Challenges in the Cambodian Academic Profession : Insights from Public University Lecturers. 2018.

ការក្នុងវិស័យឯកជន ៤៩,៤% នៅក្នុងស្ថាប័នរដ្ឋ ៨,៥% នៅក្នុងអង្គការមិនរកប្រាក់ចំណេញឯកជន និង ៣៧,៧% នៅក្នុងគ្រឹះស្ថានឧត្តមសិក្សា[55]។

ភាគរយនៃគ្រូបង្រៀនតាមសាកលវិទ្យាល័យនៅកម្ពុជា ដែលមានសញ្ញាបត្របណ្ឌិតមានកម្រិតទាប។ តួលេខសម្រាប់ឆ្នាំសិក្សា ២០១៥-២០១៦ បង្ហាញថាគ្រូបង្រៀនដែលមានសញ្ញាបត្របណ្ឌិតមាន ៣% និង សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មាន ៥៩% (៤១% មានសញ្ញាបត្រក្នុងស្រុក និង ១៨% មានសញ្ញាបត្រក្រៅប្រទេស)[56]។ គ្រូបង្រៀនកម្រិតឧត្តមសិក្សានៅកម្ពុជាភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ គ្រូបង្រៀនដែលមានសញ្ញាបត្របណ្ឌិតមានតិចតួច បើប្រៀបធៀបជាមួយគ្រូបង្រៀនមកពីប្រទេសអាស៊ានដទៃទៀត ដូចមានក្នុងតារាង ២.៤។

**តារាង ២. ៤៖** គ្រូបង្រៀនកម្រិតឧត្តមសិក្សាដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬបណ្ឌិត នៅប្រទេសអាស៊ាន (ទិន្នន័យចុងក្រោយបំផុត)

| ប្រទេស | ឆ្នាំនៃទិន្នន័យថ្មីៗបំផុត | បណ្ឌិត | បរិញ្ញាបត្រជាន់ខ្ពស់ |
|---|---|---|---|
| កម្ពុជា | ២០១៦ | ៣ | ៥៩ |
| ហ្វីលីពីន | ២០១២ | ១៣ | ៤១ |
| វៀតណាម | ២០១២ | ១៤ | ៤៦ |

**ប្រភព៖ កម្ពុជា៖ ក្រសួងអប់រំ យុវជន និងកីឡា, ហ្វីលីពីន៖ គណៈកម្មការឧត្តមសិក្សា, វៀតណាម៖ ក្រសួងអប់រំ និងបណ្តុះបណ្តាល**

ស្ត្រីក៏មានតំណាងតិចដែរក្នុងចំណោមអ្នកស្រាវជ្រាវ។ ទិន្នន័យពីឆ្នាំ ២០១៥ បានបង្ហាញថាមានតែ ២៣,៧% នៃអ្នកស្រាវជ្រាវជាស្ត្រី ដែលស្មើនឹងប្រទេសក្នុងតំបន់[57]។ យោងតាមការស្ទង់មតិរបស់ ESCAP អ្នកឆ្លើយតបបានរាយការណ៍ថា តំណាងស្ត្រីនៅក្នុងក្រុមអ្នកស្រាវជ្រាវប្រែប្រួលពីចន្លោះ 0%(NPIC) ទៅ ៥0% (AVI និង CRDI)។

កង្វះអ្នកជំនាញដែលមានសញ្ញាបត្រកម្រិតខ្ពស់ គឺស្របនឹងលទ្ធផលនៃការស្ទង់មតិរបស់ ESCAP ហើយមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះគុណភាពនៃការស្រាវជ្រាវ និងសមត្ថភាពក្នុងការផ្តល់ជំនាញស្រាវជ្រាវដល់និស្សិត។ យោងតាមការស្ទង់មតិរបស់ ESCAP ភាគរយនៃបុគ្គលិកដែលមានសញ្ញាបត្របណ្ឌិតចាប់ពី 0 ភាគរយ នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ដល់ ២៥ភាគរយ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។ លើសពីនេះ បុគ្គលិកសាកលវិទ្យាល័យលើសបន្ទុកក្នុងការបង្រៀន។ ប្រាក់ឈ្នួលត្រូវបានគេចាត់ទុកថាទាបខ្លាំង (ប្រហែល ៣00 ដុល្លារក្នុងមួយខែ

[55] United Nations Educational, Scientific and Cultural Organization. UNESCO Science Report. 2021.

[56] Ministry of Education, Youth and Sport. 2016.

[57] United Nations Educational, Scientific and Cultural Organization. Fact Sheet 60 Women in Science. 2020.

គិតត្រឹមឆ្នាំ ២០១៧)[58] ដែលជំរុញឱ្យបុគ្គលិកទទួលយកតួនាទីបង្រៀនបន្ថែមនៅខាងក្រៅស្ថាប័នរបស់ពួកគេថែមទៀត។ ម៉ោងធ្វើការបន្ថែម ធ្វើឱ្យពួកគេមានពេលតិចតួចសម្រាប់ការស្រាវជ្រាវ ដែលជាហេតុផលចម្បងមួយធ្វើឱ្យលទ្ធផលស្រាវជ្រាវរបស់បុគ្គលិកសាកលវិទ្យាល័យមានកម្រិតទាប។ អ្នកឆ្លើយសំណួរភាគច្រើនបាននិយាយថា ពួកគេចំណាយ 0% ទៅ២០% នៃពេលវេលារបស់ពួកគេលើការស្រាវជ្រាវ។ ទោះជាយ៉ាងណាក៏ដោយ អ្នកឆ្លើយសំណួរមកពីវិទ្យាស្ថានស្រាវជ្រាវ និងធានាគារខួក្បាល(Think Tank) បានរាយការណ៍ថា ការចំណាយពេលក្នុងការស្រាវជ្រាវមានរយៈពេលវែងជាងគេគឺ ៥០ភាគរយ នៅវិទ្យាស្ថានចក្ខុវិស័យអាស៊ី និង ៩០% នៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។

ការសិក្សាឆ្នាំ២០១៦ បានបង្ហាញថា បុគ្គលិកសាកលវិទ្យាល័យសាធារណៈចំណាយពេលវេលាក្នុងការស្រាវជ្រាវ (១២,៤៤ ម៉ោងក្នុងអំឡុងម៉ោងសិក្សា) ច្រើនជាងបុគ្គលិកសាកលវិទ្យាល័យឯកជន (១០,០៥ ម៉ោងក្នុងមួយសប្តាហ៍ក្នុងអំឡុងម៉ោងសិក្សា) ដោយសារតែបុគ្គលិកសាកលវិទ្យាល័យឯកជនចំណាយពេលច្រើនក្នុងការបង្រៀន។ លើសពីនេះ បុគ្គលិកនៅតាមសាកលវិទ្យាល័យសាធារណៈនៅតាមខេត្តចំណាយពេលវេលាស្រាវជ្រាវតិចក្នុងការស្រាវជ្រាវ (៩,៨៥ ម៉ោងក្នុងមួយសប្តាហ៍ក្នុងអំឡុងម៉ោងសិក្សា) ដោយសារពួកគេចំណាយពេលច្រើនលើការងាររដ្ឋបាល[59]។ បុគ្គលិកពេញម៉ោងដែលមានសញ្ញាបត្រចុងក្រោយនៅបរទេស មានការចូលរួមច្រើនជាងនៅក្នុងសកម្មភាពស្រាវជ្រាវ។ ការសិក្សាបានរកឃើញថា ៦៥% នៃអ្នកឆ្លើយតប (សាស្ត្រាចារ្យសាកលវិទ្យាល័យចំនួន ៤៤៤រូប នៅតាមសាកលវិទ្យាល័យចំនួន ១០) មិនបានចូលរួមក្នុងសកម្មភាពស្រាវជ្រាវណាមួយឡើយក្នុងរយៈពេល៥ឆ្នាំ ចុងក្រោយនេះ[60]។

ខណៈពេលដែលការផ្លាស់ប្តូររចនាសម្ព័ន្ធសំខាន់ៗ នឹងត្រូវការជាចាំបាច់ដើម្បីអនុញ្ញាតឱ្យបុគ្គលិកសាកលវិទ្យាល័យមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់ ជាមួយគ្នានោះនិន្នាការវិជ្ជមានឆ្ពោះទៅរកការយកចិត្តទុកដាក់ខ្លាំងលើការស្រាវជ្រាវ ត្រូវបានគេមើលឃើញថាមានខ្លះៗនៅក្នុងសាកលវិទ្យាល័យមួយចំនួន។ ពាក់កណ្តាលនៃអ្នកឆ្លើយការស្ទង់មតិរបស់ ESCAP បាននិយាយថា ពេលវេលាដែលបានចំណាយលើការស្រាវជ្រាវបានកើនឡើងក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ (អ្នកផ្សេងៗក្រៅពីនេះបាននិយាយថា មិនបានផ្លាស់ប្តូរទេ)។ លើសពីនេះ ពាក់កណ្តាលនៃអ្នកឆ្លើយសំណួរបានបង្ហាញថា ពួកគេមានបំណងជ្រើសរើសអ្នកស្រាវជ្រាវបន្ថែមទៀតក្នុងរយៈពេលបីឆ្នាំខាងមុខ។

---

58 As reported in The International Institute for Asian Studies. 2017.
59 Kitamura, Y. et al.. Quality of Education and Research in Cambodian Higher Education Institutions. 2016.
60 Eam, P. Factors Differentiating Research Involvement among Faculty Members: A Perspective from Cambodia.
2015.

### ២.៣.២. និស្សិតថ្នាក់បណ្ឌិត

កត្តាជាច្រើនបានរារាំងដល់ការបណ្តុះបណ្តាលបុគ្គលិកថ្នាក់បណ្ឌិត។ ដូចដែលបានពិភាក្សាក្នុងផ្នែក ១.២ ខ្មែរក្រហមជាអ្នកទទួលខុសត្រូវចំពោះការបាត់បង់បញ្ញវន្ត និងអ្នកស្រាវជ្រាវមួយជំនាន់ ដែលឥឡូវនេះអាចជាអ្នកណែនាំដល់និស្សិតបណ្ឌិតជំនាន់ថ្មីៗបាន។ លើសពីនេះទៀត ដោយសារតែបុគ្គលិកសាកលវិទ្យាល័យដែលមានសញ្ញាបត្របណ្ឌិតមានអត្រាទាប អ្នកស្រាវជ្រាវដែលមានជំនាញក្នុងការអភិវឌ្ឍសមត្ថភាពស្រាវជ្រាវរបស់និស្សិតថ្នាក់បណ្ឌិតមានតិចតួចបំផុត។ យោងតាមទិន្នន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា មាននិស្សិតថ្នាក់បណ្ឌិតត្រឹមតែ ១៣៤៩ នាក់ប៉ុណ្ណោះដែលបានចុះឈ្មោះចូលរៀនក្នុងឆ្នាំសិក្សា ២០១៧-២០១៨ បើទោះបីជាចំនួននេះមានការកើនឡើងពីនិស្សិតបណ្ឌិតចំនួន ១១៨១នាក់ ក្នុងឆ្នាំសិក្សា២០១៣-២០១៤ ក៏ដោយ។ ស្របនឹងបញ្ហានេះដែរ ពាក់កណ្តាលនៃសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវបានឆ្លើយតបទៅនឹងការស្ទង់មតិរបស់ ESCAP ថាពុំមាននិស្សិតថ្នាក់បណ្ឌិតទេ។ សូម្បីតែសាកលវិទ្យាល័យធំជាងគេក្នុងប្រទេស គឺសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលមាននិស្សិតប្រមាណ ២០០០០នាក់ ក៏បានរាយការណ៍ថា មាននិស្សិតបណ្ឌិតតែ ២០នាក់ប៉ុណ្ណោះ[61]។

មានសមាមាត្រខ្ពស់នៃនិស្សិតស្រីនៅកម្រិតបរិញ្ញាបត្រ ដោយតួលេខឆ្នាំ២០១៧-២០១៨ បង្ហាញថា ៤៩,៧% នៃនិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាស្ត្រី ដែលការកើនឡើងនេះគឺអាចពន្យល់បានថា យ៉ាងហោចណាស់មួយចំណែកមកពីក្រសួងអប់រំ យុវជន និងកីឡា  បានផ្តល់អាទិភាពដល់និស្សិតស្រីក្នុងគម្រោងអាហារូបករណ៍។ ទោះជាយ៉ាងណាក៏ដោយ សមាមាត្រនៃនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ស្ត្រីគឺ ២២% ហើយជាមធ្យមនៃនិស្សិតថ្នាក់បណ្ឌិតមានត្រឹមតែ ៥% ប៉ុណ្ណោះ។ ក្នុងឆ្នាំ២០១៧-២០១៨ មានតែនិស្សិតចំនួន ១៥ នាក់ប៉ុណ្ណោះដែលទទួលបានសញ្ញាបត្របណ្ឌិត (ក្នុងនោះពីរនាក់ជាស្ត្រី)[62]។

[61] ESCAP Survey.

[62] Ministry of Education, Youth and Sport. Education Congress 2018-2019. The education, youth and sport performance in the academic year 2017-2018 and goals for the academic year 2018-2019. 2019. pg. 66-69.

## ២.៤. មូលនិធិស្រាវជ្រាវ

### ២.៤.១. មូលនិធិស្រាវជ្រាវសម្រាប់សាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវ

ការស្រាវជ្រាវនៅកម្ពុជាគឺខ្វះថវិកា។ ដូចដែលបានបង្ហាញក្នុងតារាង ២.៥ ការចំណាយក្នុងស្រុកសរុបលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ (GERD) មានត្រឹមតែ ០,១២ ភាគរយ នៃ**ផ.ស.ស** ក្នុងឆ្នាំ២០១៥ ដែលជាកម្រិតទាបបំផុតទីពីរនៅក្នុងតំបន់បន្ទាប់ពីប្រទេសមីយ៉ាន់ម៉ា។

**តារាង ២. ៥៖** ការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ក្នុងស្រុកសរុប ( GERD ) (ឆ្នាំចុងក្រោយនៅក្នុងប្រទេសអាស៊ាន)

| ប្រទេស | ឆ្នាំ | GERD |
|---|---|---|
| ប្រ៊ុយណេ | ២០១៨ | ១,២៨ |
| កម្ពុជា | ២០១៥ | ០,១២ |
| ម៉ាឡេស៊ី | ២០១៦ | ១,៤៤ |
| មីយ៉ាន់ម៉ា | ២០១៧ | ០,០៣ |
| ហ្វីលីពីន | ២០១៥ | ០,១៦ |
| សិង្ហបុរី | ២០១៧ | ១,៩៤ |
| ថៃ | ២០១៧ | ១,០០ |
| វៀតណាម | ២០១៧ | ០,៥៣ |

**ប្រភព៖ របាយការណ៍វិទ្យាសាស្ត្ររបស់យូណេស្កូ**

ទាក់ទងនឹងការគាំទ្រថវិកាសម្រាប់ការស្រាវជ្រាវ រូបភាព ២.៤ បង្ហាញថា ៣៥% នៃមូលនិធិបានមកពីបរទេស (ខ្ពស់បំផុតក្នុងចំណោមប្រទេសអាស៊ាន) ២៥% បានមកពីរាជរដ្ឋាភិបាល (ទាបបំផុតទីពីរក្នុងចំណោមប្រទេសអាស៊ាន) ២២% បានមកពីអង្គការមិនស្វែងរកប្រាក់ចំណេញឯកជន ហើយនៅសល់ ១៩% បានមកពីធុរកិច្ច[63]។

[63] អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ។ របាយការណ៍វិទ្យាសាស្ត្រ ឆ្នាំ២០២១

រូបភាព ២. ៤៖ ការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍តាមប្រភពនៃកម្ពុជា

ភាគរយនៃការចំណាយសរុបលើការស្រាវជ្រាវ និងអភិវឌ្ឍន៍




ប្រភព៖ របាយការណ៍វិទ្យាសាស្រ្តរបស់យូណេស្កូ

ម្ចាស់ជំនួយបរទេស និងធនាគារអភិវឌ្ឍន៍ពហុភាគី ដូចជាធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី គឺជាអ្នកឧបត្ថម្ភដ៏សំខាន់សម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍នៅកម្ពុជា។ អ្នកទទួលកញ្ចប់មូលនិធិចម្បងគឺវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ[64]។ ការស្ទង់មតិរបស់ ESCAP ក៏បានសិក្សាឃើញស្រដៀងគ្នាដែរទាក់ទងនឹងជំនួយនេះ។ ទោះបីជាប្រភពកញ្ចប់មូលនិធិចម្បងបានមកពីប្រភពខុសប្លែកគ្នាក៏ដោយ ប្រភពដែលបានច្រើនបំផុតគឺពីអង្គការអន្តរជាតិ និងមូលនិធិអភិវឌ្ឍន៍ (ប្រភពកញ្ចប់មូលនិធិចម្បងសម្រាប់ស្ថាប័នទាំងបី) ខណៈដែលប្រភពតិចតួចបំផុតគឺបានពីធុរកិច្ច និងអង្គភាពធុរកិច្ច (ប្រភពបន្ទាប់បន្សំសម្រាប់ស្ថាប័នទាំងបី)។ ដោយសារចំនួនកញ្ចប់មូលនិធិច្រើនបានមកពីដៃគូបរទេសនិងអង្គការអន្តរជាតិ ជាហេតុធ្វើឱ្យមានការជះឥទ្ធិពលយ៉ាងខ្លាំងលើប្រធានបទស្រាវជ្រាវ ព្រមទាំងរយៈពេលនៃការស្រាវជ្រាវដែលភាគច្រើនមានរយៈពេលខ្លី[65]។

---

[64] Ibid.

[65] Cambodian Institute for Cooperation and Peace. Doing Research in Cambodia: Making Models that Build Capacity. 2016.

ចំនួនទឹកប្រាក់នៃកញ្ចប់មូលនិធិស្រាវជ្រាវដែលប្រភពទទួលបានពីសាធារណៈ (ពីបណ្ដាក្រសួង) ក្នុងឆ្នាំ ២០២០ មានចាប់ពី ០ រៀល (វិទ្យាស្ថានចក្ខុវិស័យអាស៊ី និងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល) ដល់ ៤,៩ ពាន់លានរៀលនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (តារាងទី ៦)។ ចំណែកឯប្រភពឯកជន សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ទទួលបាន ០ រៀល និងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ទទួលបាន ២០លានរៀលដូចគ្នា សាកលវិទ្យាល័យភូមិន្ទភ្នំពេញទទួលបាន ៤ពាន់លានរៀល (មានចំនួនដូចគ្នាពីប្រភពសាធារណៈ) និងវិទ្យាស្ថានបណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទទួលបាន ៤,៨ពាន់លានរៀល។

**តារាង ២.៦៖** ការផ្ដល់មូលនិធិពីប្រភពសាធារណៈ និងឯកជន នៃអង្គការស្រាវជ្រាវដែលបានពិគ្រោះយោបល់នៅក្នុងការស្ទង់មតិ ESCAP ឆ្នាំ ២០២០ (គិតជា លានរៀល)

| ស្ថាប័ន | ប្រភពសាធារណៈ (ក្រសួង) | ប្រភពឯកជន |
|---|---|---|
| សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ៣៦០ | ០ |
| វិទ្យាស្ថានចក្ខុវិស័យអាស៊ី | ០ | ២០ |
| វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | ៨០ | ២០ |
| សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ៤០០០ | ៤០០០ |
| សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | ០ | ០ |
| វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ៤៩៥០ | ៨០ |
| វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា | ៦០០ | ៤៨០០ |

**ប្រភព៖ ការស្ទង់មតិរបស់ ESCAP**

ប្រទេសកម្ពុជាបានប្រើប្រាស់យន្តការនៃការផ្ដល់កញ្ចប់មូលនិធិជាច្រើនរួមមាន៖ យន្តការផ្ដល់ជំនួយឥតសំណងនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ការស្នើប្រកួតប្រជែងនៅវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងយន្តការរួមបញ្ចូលទាំងពីរនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ ប្រភពកញ្ចប់មូលនិធិផ្សេងទៀត រួមមាន ផែនការថវិកាប្រចាំឆ្នាំ (វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា) គម្រោងកែលម្អការអប់រំឧត្តមសិក្សា (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)[66] និងការផ្ដល់កញ្ចប់មូលនិធិតាមរយៈការប្រមូលទិន្នន័យ ឬការបោះពុម្ពផ្សាយ (សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល)។

[66] គោលដៅរបស់ HEIP គឺដើម្បីបង្កើនគុណភាព និងភាពពាក់ព័ន្ធរវាងការអប់រំនិងការស្រាវជ្រាវកម្រិតឧត្តមសិក្សា ជាចម្បងក្នុងវិស័យ STEM និងកសិកម្មនៅតាមគ្រឹះស្ថានឧត្តមសិក្សាគោលដៅ និងដើម្បីកែលម្អអភិបាលកិច្ចក្នុងវិស័យនេះ។

ក្នុងឆ្នាំ២០១០ រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងវិស័យអប់រំបន្តដោយផែនការមេស្រាវជ្រាវនិងអភិវឌ្ឍន៍វិស័យអប់រំក្នុងឆ្នាំ២០១១។ ទោះជាយ៉ាងណាក៏ដោយ គោលនយោបាយ និងកម្មវិធីទាំងនេះ មិនស្របគ្នានឹងកញ្ចប់មូលនិធិទេ[67]។ លើសពីនេះ ប្រព័ន្ធកញ្ចប់មូលនិធិស្រាវជ្រាវគឺស្មុគស្មាញពេក ហើយអ្នកស្រាវជ្រាវជាទូទៅមិនដឹងពីរបៀបដើម្បីទទួលបានកញ្ចប់មូលនិធិស្រាវជ្រាវដែលមាននោះទេ។ អាស្រ័យហេតុនេះ និស្សិត និងសាស្ត្រាចារ្យតែងតែចំណាយលើការស្រាវជ្រាវផ្ទាល់ខ្លួន សម្រាប់ការស្រាវជ្រាវរបស់ពួកគេ [68]។

យោងតាមការស្ទង់មតិរបស់ ESCAP ផលលំបាកចម្បងដែលអ្នកស្រាវជ្រាវជួបប្រទះនៅពេលលើកសំណើកញ្ចប់មូលនិធិស្រាវជ្រាវសម្រាប់សាកលវិទ្យាល័យ ឬវិទ្យាស្ថានគឺ៖

- កង្វះព័ត៌មានប្រភពកញ្ចប់មូលនិធិ
- កញ្ចប់មូលនិធិមានកំណត់
- ការប្រកួតប្រជែងហួសហេតុ (ជាពិសេសពីវិទ្យាស្ថានស្រាវជ្រាវអន្តរជាតិ)
- កង្វះពេលវេលា (អ្នកស្រាវជ្រាវច្រើនតែទទួលការបង្រៀនបន្ថែមដោយសារប្រាក់ខែតិចធ្វើឱ្យពួកគេពុំមានពេលគ្រប់គ្រាន់ដើម្បីស្នើសុំកញ្ចប់មូលនិធិស្រាវជ្រាវ)។

ដើម្បីលើកម្ពស់កញ្ចប់មូលនិធិស្រាវជ្រាវ អ្នកឆ្លើយសំណួរបានស្នើថារាជរដ្ឋាភិបាលអាច៖

- បង្កើនកញ្ចប់មូលនិធិស្រាវជ្រាវដែលមានទំនាក់ទំនងនឹង ផ.ស.ស.
- បើកប្រភពកញ្ចប់មូលនិធិបន្ថែមទៀតសម្រាប់ស្នើប្រកួតប្រជែង
- បង្កើតគណៈកម្មាធិការកញ្ចប់មូលនិធិស្រាវជ្រាវ
- ប្រកាសជាប្រចាំឆ្នាំស្តីពីប្រធានបទស្រាវជ្រាវ និងការផ្តល់កញ្ចប់មូលនិធិ
- ធានានូវតម្លាភាពក្នុងការគ្រប់គ្រងជំនួយស្រាវជ្រាវ
- ធានាថាអ្នកស្រាវជ្រាវមានពេលវេលាច្រើនក្នុងការសិក្សាស្រាវជ្រាវ
- ជំរុញការផ្តល់កញ្ចប់មូលនិធិស្រាវជ្រាវពីវិស័យឯកជន។

ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការប្រកាសពីការបង្កើតកញ្ចប់មូលនិធិស្រាវជ្រាវគំនិតច្នៃប្រឌិត និង នវានុវត្តន៍(RCI) នៅខែសីហា ឆ្នាំ ២០២០។ កញ្ចប់មូលនិធិ RCI នឹងផ្តល់ហិរញ្ញប្បទានដល់សំណើស្រាវជ្រាវដែលស្វែងរកលទ្ធផលជាក់ស្តែងដែលអាចអនុវត្តបានភ្លាមៗ និងដោះស្រាយបញ្ហាប្រឈមនានា

[67] Un, L. & Sok, S. Reason that this influence from the former Soviet Bloc explains why the Cambodian higher education is more oriented towards teaching and learning than producing research. 2014.
[68] Cambodian Institute for Cooperation and Peace. Doing Research in Cambodia: Making Models that Build Capacity. 2016.

ទាក់ទងនឹងការលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្មរបស់កម្ពុជា។ កញ្ចប់មូលនិធិ RCI នឹងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ប្រធានបទអាទិភាពចំនួនបី៖

- ឌីជីថលូបនីកម្មសម្រាប់បដិវត្តន៍ឧស្សាហកម្ម ៤.០ (ការអប់រំឌីជីថល សេដ្ឋកិច្ចឌីជីថល និងកម្មវិធីឌីជីថល)
- ការស្រាវជ្រាវអនុវត្តន៍ក្នុងវិស័យកសិកម្ម
- ការស្រាវជ្រាវលើវិធីសាស្ត្របង្រៀនសម្រាប់សតវត្សរ៍ទី២១ (ថ្នាក់រៀននិម្មិត, ការឆ្លើយតបផ្នែកអប់រំចំពោះជំងឺកូវីដ-១៩ ជំនួយស្រាវជ្រាវខ្នាតតូចសម្រាប់សិស្ស និងពានរង្វាន់ RCI)។

លើសពីនេះទៀត នៅក្នុងខែកក្កដា ឆ្នាំ២០២១ ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានប្រជុំជាលើកដំបូងដើម្បីកំណត់គោលដៅនៃការចំណាយយ៉ាងហោចណាស់ ១% នៃ**ផ.ស.ស.** លើការស្រាវជ្រាវនៅឆ្នាំ ២០៣០ ដើម្បីបង្កើនសមត្ថភាពស្រាវជ្រាវ និងគុណភាពស្រាវជ្រាវរបស់ប្រទេស។ ក្រុមប្រឹក្សាជាតិក៏រំពឹងផងដែរថាពាក់កណ្តាលនៃការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ បានមកពីមូលនិធិដោយវិស័យឯកជននៅត្រឹមឆ្នាំ ២០៣០[69]។

### ២.៤.២. ការចំណាយពីវិស័យឯកជនលើការស្រាវជ្រាវ និងអភិវឌ្ឍន៍

បច្ចុប្បន្ននេះ ការចំណាយលើវិស័យស្រាវជ្រាវ និងអភិវឌ្ឍន៍ពីវិស័យឯកជនមានកម្រិតទាបណាស់។ តួលេខ GERD របស់កម្ពុជាមានចំនួន ០,១២% នៃ**ផ.ស.ស.** ដែលក្នុងនោះ ១៩% បានមកពីធុរកិច្ច ដែលជាចំនួនទាបបំផុតក្នុងចំណោមប្រទេសអាស៊ាន។ លើសពីនេះ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដោយធុរកិច្ចកម្ពុជាក៏កម្រមាន ដែរ។ ក្នុងចំណោមស្ថាប័នក្នុងវិស័យឯកជនទាំងបួនដែលឆ្លើយតបទៅនឹងការស្ទង់មតិរបស់ ESCAP មានពីរដែល ពុំមានថវិកាការស្រាវជ្រាវ និងអភិវឌ្ឍន៍ទេ ស្ថាប័នមួយបានចំណាយ ៥០,០០០ រៀល លើការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដោយប្រើប្រាស់ធនធានផ្ទាល់ខ្លួនក្នុងឆ្នាំ២០២០ និងមួយទៀតបានចំណាយ ២០០,០០០ រៀល ដោយប្រើប្រាស់ធនធានផ្ទាល់ខ្លួន។ មានតែសហគ្រាសមួយប៉ុណ្ណោះដែលបានទទួលកញ្ចប់មូលនិធិការស្រាវជ្រាវ និងអភិវឌ្ឍន៍ ពីរាជរដ្ឋាភិបាល (តាមរយៈយន្តការផ្តល់ជំនួយឥតសំណង)។ ក្រៅពីនេះ កញ្ចប់មូលនិធិខាងក្រៅលើ ការស្រាវជ្រាវ និងអភិវឌ្ឍន៍បានមកពីម្ចាស់ជំនួយអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល។ ការបង្កើនកញ្ចប់មូលនិធិស្រាវជ្រាវដែលបានពីធុរកិច្ចជាគោលដៅគឺពី ១៩% ទៅ ៥០%។

ទាក់ទងនឹងការលំបាកចម្បងដែលជួបប្រទះក្នុងការលើកស្នើកញ្ចប់មូលនិធិស្រាវជ្រាវ អ្នកឆ្លើយតបការស្ទង់មតិរបស់ ESCAP មកពីវិស័យឯកជន និងសាកលវិទ្យាល័យ/ស្ថាប័នស្រាវជ្រាវបានគូសបញ្ជាក់ថា ពុំមានកញ្ចប់មូលនិធិគ្រប់គ្រាន់ នីតិវិធីស្មុគស្មាញ និងការផ្តល់ការណែនាំមានកំណត់។ ពួកគេបានស្នើឱ្យមានការកំណត់គោលការណ៍ណែនាំច្បាស់លាស់ និងសម្រួលដំណើរការនៃការដាក់ពាក្យស្នើសុំគម្រោងផ្តល់កញ្ចប់មូលនិធិតាមប្រព័ន្ធអនឡាញ។

[69] Government of the Kingdom of Cambodia. (2021). Cambodia's Science, Technology and Innovation Roadmap 2020-2030.

## ២.៥. គុណភាពស្រាវជ្រាវ និងការអនុវត្ត

### ២.៥.១. លទ្ធផលស្រាវជ្រាវ

ក្នុងឆ្នាំ២០១៩ កម្ពុជាមានការបោះពុម្ពផ្សាយការស្រាវជ្រាវបែបវិទ្យាសាស្ត្រចំនួន២៧ ក្នុងចំនួនប្រជាជនមួយលាននាក់ក្នុងកាលិកបត្រដែលទទួលស្គាល់ដោយអន្តរជាតិ[70] ដែលធ្វើឱ្យកម្ពុជាស្ថិតនៅចំណាត់ថ្នាក់ទាបបំផុតទីពីរនៅក្នុងអាស៊ានសម្រាប់ការបោះពុម្ពផ្សាយ ដូចមានបង្ហាញក្នុងតារាងទី ២.៧។

**តារាង ២. ៧៖** ការបោះពុម្ពផ្សាយបែបវិទ្យាសាស្ត្រ នៃប្រទេសអាស៊ាន ឆ្នាំ២០១៩

ចំនួននៃការបោះពុម្ពផ្សាយនៅក្នុងកាលិកបត្រទទួលស្គាល់ជាអន្តរជាតិ ក្នុងចំនួនប្រជាជនមួយលាននាក់

| ប្រទេស | ការបោះពុម្ពផ្សាយវិទ្យាសាស្ត្រក្នុងចំនួនប្រជាជនមួយលាននាក់ |
|---|---|
| ប្រ៊ុយណេ | ១០៤១ |
| កម្ពុជា | ២៧ |
| ឥណ្ឌូនេស៊ី | ១៣៩ |
| សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | ៤២ |
| ម៉ាឡេស៊ី | ៩៤៤ |
| មីយ៉ាន់ម៉ា | ១២ |
| ហ្វីលីពីន | ៣៨ |
| សិង្ហបុរី | ៣៣៤៩ |
| ថៃ | ២៤៧ |
| វៀតណាម | ១១៣ |

**ប្រភព៖ របាយការណ៍វិទ្យាសាស្ត្ររបស់យូណេស្កូ ២០២១**

ឯកសារដែលបានបោះពុម្ពចម្បង រួមមានវិទ្យាសាស្ត្រសុខាភិបាល (៤៣%) វិទ្យាសាស្ត្របរិស្ថាន (១១%) និងបច្ចេកវិទ្យាបែបអនុវត្តជាយុទ្ធសាស្ត្រ (cross-cutting strategic technologies)និងវិស្វកម្ម (ទាំងពីរផ្នែក ចំនួន៨%)[71]។

លទ្ធផលស្រាវជ្រាវក្នុងទម្រង់ជាអត្ថបទវិទ្យាសាស្ត្រក្នុងប្រទេសកម្ពុជាភាគច្រើនបានមកពីសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវសាធារណៈ។ លទ្ធផលនេះមានភាពស្វាហាប់ និងកំពុងកើនឡើង (ទោះបីជាមានមូលដ្ឋានតូចក៏ដោយ) ពីស្ទើរតែគ្មានការបោះពុម្ពមុនឆ្នាំ ២០០០ ដល់មានការបោះពុម្ពជិត ៦០០ ច្បាប់

[70] អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់អង្គការសហប្រជាជាតិ។ របាយការណ៍វិទ្យាសាស្ត្រ ២០២១

[71] Ibid.

ក្នុងមួយឆ្នាំ នៅពេលបច្ចុប្បន្ននេះ (រូបភាព ២.៥)។ គ្រឹះស្ថានដែលសកម្មបំផុតក្នុងការផលិតលទ្ធផលស្រាវជ្រាវមានបង្ហាញក្នុងរូបភាពទី ៦។ ប្រទេសកម្ពុជាការផ្សារភ្ជាប់ខ្ពស់ទៅនឹង (និងពឹងផ្អែកលើ) កិច្ចសហការស្រាវជ្រាវអន្តរជាតិ។ ចន្លោះឆ្នាំ ២០០៨ និង២០១៣ អត្ថបទកម្ពុជា ៩៦% ជាអត្ថបទដែលមានសហអ្នកនិពន្ធអន្តរជាតិយ៉ាងហោចណាស់ម្នាក់ ដែលអាចពន្យល់បានពីកំណើននៃអត្រាអាគតដ្ឋាន។ ប្រជាជនកម្ពុជាមើលឃើញថាទាំងអ្នកវិទ្យាសាស្ត្រអាស៊ី (ថៃ និងជប៉ុន) និងអ្នកវិទ្យាសាស្ត្របស្ចិមប្រទេស (សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងបារាំង) ជាអ្នកសហការជិតស្និទ្ធបំផុតរបស់ខ្លួន។ រូបភាព ២.៧ បង្ហាញពីវិស័យស្រាវជ្រាវដែលមានផលិតភាពបំផុតនៅក្នុងប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ២០០០-២០២០ ដោយការស្រាវជ្រាវក្នុងវិស័យវេជ្ជសាស្ត្រ ទទួលបាននូវលទ្ធផលគួរឱ្យកត់សម្គាល់។

**រូបភាព ២. ៥៖** ការបោះពុម្ពផ្សាយបែបវិទ្យាសាស្ត្រ (អត្ថបទ, ជំពូកសៀវភៅ) របស់អ្នកនិពន្ធ ឬសហអ្នកនិពន្ធដែលមានសម្ព័ន្ធភាពកម្ពុជា ឆ្នាំ ១៩៦២ ដល់បច្ចុប្បន្ន




ប្រភព៖ Scopus

**រូបភាព ២. ៦៖** វិទ្យាស្ថានស្រាវជ្រាវដែលមានផលិតភាពបំផុតទាំង១០ ដែលមានសម្ព័ន្ធភាពនៅកម្ពុជា ឆ្នាំ ២០០០ ដល់ ២០២០




ប្រភព៖ Scopus

**រូបភាព ២. ៧៖** វិស័យស្រាវជ្រាវដែលមានផលិតភាពបំផុតទាំង១០ នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០០០-២០២០




ប្រភព៖ Scopus

### ២.៥.២. គុណភាពស្រាវជ្រាវ

ប្រទេសកម្ពុជាប្រឈមមុខនឹងបញ្ហាជាច្រើនក្នុងការធានាគុណភាពនៃការស្រាវជ្រាវ។ ចំណុចមួយចំនួនត្រូវបានពិភាក្សារួចមកហើយ មានដូចជាកង្វះខាតពេលវេលា និងកញ្ចប់មូលនិធិស្រាវជ្រាវ ហេដ្ឋារចនាសម្ព័ន្ធសមស្រប (រួមទាំងការចូលទៅមើលកាលិកបត្រ និងមូលទិន្នន័យតាមប្រព័ន្ធអនឡាញ) និងការបណ្តុះបណ្តាលនិស្សិតថ្នាក់បណ្ឌិតនៅមានកំណត់។

គុណភាពទិន្នន័យ និងក្រមសីលធម៌ គឺជាកត្តាផ្សេងទៀតដែលរារាំងគុណភាពនៃការស្រាវជ្រាវនៅកម្ពុជា។ ការធានាថាទិន្នន័យស្រាវជ្រាវមានគុណភាពខ្ពស់ និងការប្រមូលទិន្នន័យដែលប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំប្រកបដោយក្រមសីលធម៌ ជាកត្តាសំខាន់សម្រាប់ការបោះពុម្ពផ្សាយនៅក្នុងកាលិកបត្រត្រួតពិនិត្យដោយសហវិនិច្ឆ័យករ (peer-reviewd journals) អន្តរជាតិភាគច្រើន។ ទោះជាយ៉ាងណាក៏ដោយការសិក្សាឆ្នាំ ២០១៦ បានបង្ហាញថា ការយកចិត្តទុកដាក់របស់ស្ថាប័នលើគុណភាពទិន្នន័យមានកម្រិតខ្សោយនៅកម្រិតឧត្តមសិក្សា[72]។ លើសពីនេះ មានតែពាក់កណ្តាលនៃអ្នកឆ្លើយតបទៅនឹងការស្ទង់មតិរបស់ ESCAP ប៉ុណ្ណោះដែលដឹងពីអត្ថិភាពនៃក្រមសីលធម៌ស្រាវជ្រាវជាតិ ហើយមានស្ថាប័នតែមួយ (វិទ្យាស្ថានចក្ខុវិស័យអាស៊ី) ដែលដឹងពីក្រមសីលធម៌កម្រិតស្ថាប័ន។

ឧបសគ្គផ្នែកភាសា ក៏ជាកត្តារារាំងគុណភាពនៃការស្រាវជ្រាវក្នុងប្រទេសកម្ពុជាផងដែរ (ដូចប្រទេសផ្សេងទៀត)។ ខណៈពេលដែលវគ្គសិក្សាភាគច្រើននៅសាកលវិទ្យាល័យកម្ពុជា ត្រូវបានបង្រៀនជាភាសាខ្មែរ អ្នកស្រាវជ្រាវដែលមិនអាចអាន និងសរសេរជាភាសាអង់គ្លេសស្ទាត់ជំនាញ ប្រឈមមុខនឹងការលំបាកក្នុងការចូលប្រើប្រាស់ឯកសារវិទ្យាសាស្ត្រ ការបោះពុម្ពផ្សាយ និងទទួលបានកញ្ចប់មូលនិធិ។ ជាងនេះទៅទៀត បញ្ហាគឺកាន់តែធ្ងន់ធ្ងរឡើងដោយការពឹងផ្អែកខ្លាំងលើម្ចាស់ជំនួយអន្តរជាតិ ដែលជារឿយៗតម្រូវឱ្យស្នើគម្រោង និងការងារដែលបានបោះពុម្ពផ្សាយជាភាសាអង់គ្លេសដើម្បីទទួលបានកញ្ចប់មូលនិធិ[73]។

### ២.៥.៣. ការវាយតម្លៃអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ

ប្រទេសកម្ពុជាហាក់ដូចជាកំពុងដើរតាមនិន្នាការសកលនៃការបង្កើនស្វ័យភាពនៃគ្រឹះស្ថានឧត្តមសិក្សាដែលនឹងការទទួលបាននូវកំណើនគណនេយ្យភាព។ នៅឆ្នាំ២០០៣ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាទទួលស្គាល់គុណភាពអប់រំកម្ពុជា ដែលជាស្ថាប័នជាតិសម្រាប់គុណភាព និងវាយតម្លៃឧត្តមសិក្សា។ កម្ពុជាក៏បានចាប់ផ្តើមផ្តល់ស្វ័យភាពដល់សាកលវិទ្យាល័យបន្ថែមទៀតក្នុងទម្រង់នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងឆ្នាំ ១៩៩៧។

យោងតាមការស្ទង់មតិរបស់ ESCAP លក្ខណៈវិនិច្ឆ័យនៃដំណើរការស្រាវជ្រាវដ៏សំខាន់បំផុតសម្រាប់អ្នកពាក់ព័ន្ធនៅសាកលវិទ្យាល័យ គឺពាក់ព័ន្ធនឹងរបៀបវារៈសំខាន់ៗរបស់ជាតិ។ នៅពេលដែលមានការលើក

[72] Cambodian Institute for Cooperation and Peace. Doing Research in Cambodia: Making Models that Build Capacity. 2016.

[73] Cambodian Institute for Cooperation and Peace. Doing Research in Cambodia: Making Models that Build Capacity. 2016.

ឡើងជាសំណួរថាតើកត្តាអ្វីខ្លះដែលព្យាករពីការរីកចម្រើនក្នុងអាជីពជាអ្នកស្រាវជ្រាវមួយនេះ មានមតិយល់ស្របចំនួនតិចតួចតែប៉ុណ្ណោះលើវិធីសាស្ត្របច្ចុប្បន្នក្នុងការវាយតម្លៃលទ្ធផលស្រាវជ្រាវដែលត្រូវបានចាត់ទុកថាមានភាពត្រឹមត្រូវ និងយុត្តិធម៌ខ្លះដែរ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីកង្វះខាតនៃការគាំទ្រសម្រាប់វិធីសាស្ត្រវាយតម្លៃបច្ចុប្បន្ន។ ដើម្បីកែលម្អវិធីសាស្ត្រទាំងនេះ អ្នកឆ្លើយសំណួរចង់បានភាពច្បាស់លាស់កាន់តែខ្លាំងលើការណែនាំអំពីសូចនាករនៃ ការអនុវត្តគន្លឹះ(KPIs) និងលក្ខណៈវិនិច្ឆ័យទៅលើការវាយតម្លៃ។

នៅក្នុងខែសីហា ឆ្នាំ២០២១ ក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសអំពីការអនុវត្តចំណាត់ថ្នាក់សាស្ត្រាចារ្យនៅតាមគ្រឹះស្ថានឧត្តមសិក្សានានាទូទាំងប្រទេស។ បច្ចុប្បន្ននេះ គ្រូបង្រៀននៅតាមបណ្ដាសាកលវិទ្យាល័យទាំងអស់នៅក្នុងប្រទេសកម្ពុជាត្រូវបានគេហៅថាជាគ្រូបង្រៀនកម្រិតឧត្តម(Lecturers) ដែលក្នុងនោះត្រូវបានចាត់ថ្នាក់ជាពីរទៀតគឺ "គ្រូបង្រៀនកម្រិតឧត្តម(Lecturers)" ឬ "គ្រូបង្រៀនកម្រិតឧត្តមជាន់ខ្ពស់(Senior Lecturer)" អាស្រ័យទៅលើអាយុ និងគុណវុឌ្ឍិ ដោយទទួលបានផ្តល់ប្រាក់ខែគោលប្រហាក់ប្រហែលគ្នា។ ក្រសួងអប់រំ បានស្នើឱ្យចេញជាមុខតំណែងចំនួនបីនៅក្នុងវិស័យអប់រំរួមមាន សាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ(សាស្ត្រាចារ្យមហាបរិញ្ញា) ដែលក្នុងនោះត្រូវបានចាត់ថ្នាក់ទៅតាមចំនួននៃការបោះពុម្ពផ្សាយវិទ្យាសាស្ត្រ។ លក្ខខណ្ឌតម្រូវការនៃការបោះពុម្ពផ្សាយទាំងនេះនឹងជំរុញឱ្យមានប្រាក់លើកទឹកចិត្តដល់បុគ្គលិកអប់រំកម្ពុជាឱ្យធ្វើការស្រាវជ្រាវ និងបោះពុម្ពផ្សាយបន្ថែមទៀត។

## ២.៦. ចល័តភាពរបស់អ្នកស្រាវជ្រាវ និងកិច្ចសហការអន្តរជាតិ

### ២.៦.១. ចល័តភាពរបស់អ្នកស្រាវជ្រាវ និងកិច្ចសហការអន្តរជាតិដែលមានស្រាប់

ដូចដែលបានរៀបរាប់ខាងលើ អ្នកស្រាវជ្រាវកម្ពុជាធ្វើការសហការជាមួយអ្នកនិពន្ធអន្តរជាតិផ្សេងទៀតលើការបោះពុម្ពរបស់ពួកគេ ជាញឹកញាប់មានការសហការជាមួយអ្នកស្រាវជ្រាវមកពីប្រទេសថៃ ជប៉ុន សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងប្រទេសបារាំង។ អាស៊ានក៏មានតួនាទីលើកកម្ពស់កិច្ចសហការស្រាវជ្រាវអន្តរជាតិនៅកម្ពុជាផងដែរ។ ឧទាហរណ៍ ផែនការសកម្មភាពអាស៊ានសម្រាប់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០១៦-២០២៥ ស្នើឱ្យមានកម្មវិធីផ្លាស់ប្តូរនិស្សិត និងកម្មវិធីសិក្សាទ្វេភាគី (Twinning Programmes) នៅសាកលវិទ្យាល័យជាមួយស្ថាប័នអប់រំកំពូលៗក្នុងប្រទេសអាស៊ាន។

តុល្យភាពរវាងការស្រាវជ្រាវក្នុងស្រុក និងអន្តរជាតិ គឺចាំបាច់ដើម្បីធានាឱ្យមានប្រព័ន្ធស្រាវជ្រាវប្រកបដោយនិរន្តរភាព។ ចរាចរណ៍ខួរក្បាល (Brain Circulation) សំដៅលើ "លទ្ធភាពសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការប្រើប្រាស់ជំនាញ ចំណេះធ្វើ និងបទពិសោធន៍គ្រប់ទម្រង់ ដែលទទួលបានដោយការធ្វើចំណាកស្រុករបស់ពួកគេ ពោលគឺថាតើពួកគេបានត្រឡប់ទៅប្រទេសដើមរបស់ពួកគេវិញឬទេ និងរួមទាំងសមាជិកនៃជនចំណាកស្រុករបស់ពួកគេ"[74]។ ចរាចរណ៍ខួរក្បាលជំរុញការបង្កើតថ្មី ដោយសារវាបង្កើនការចូលរួមរបស់ស្ថាប័ននៅក្នុងបណ្តាញចម្រុះ ដែលនាំទៅរកចំណេះដឹង វិធីសាស្ត្រ និងគំនិតថ្មីៗ។ លើសពីនេះ ដោយពិចារណា

---

[74] European Commission. Communication from the Commission to the Council, the European Parliament, the European Economic and Social Committee and the Committee of the Regions - Migration and Development:
Some Concrete Orientations. 2005.

លើកម្វះអ្នកស្រាវជ្រាវដែលមានបទពិសោធន៍ក្នុងប្រទេសកម្ពុជា ការទាក់ទាញអ្នកស្រាវជ្រាវបរទេសនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រព័ន្ធអេកូឡូស៊ីទាំងមូលនៅពេលដែលពួកគេនាំមកនូវជំនាញថ្មីៗ និងអាចដើរតួជាអ្នកណែនាំដល់អ្នកស្រាវជ្រាវវ័យក្មេង[75]។ ដោយសារតែលទ្ធផលនៃការស្រាវជ្រាវត្រូវបានចែករំលែកក្នុងចំណោមសហគមន៍កាន់តែទូលំទូលាយ គុណភាពស្រាវជ្រាវកើនឡើងជាមួយនឹងចល័តភាព ជាលទ្ធផលនាំឱ្យមានការកើនឡើងនៃលទ្ធភាពក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាជាក់លាក់[76]។

### ២.៦.២. ឧបសគ្គចំពោះចល័តភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ

យោងតាមការឆ្លើយតបរបស់មន្ត្រីរដ្ឋាភិបាលចំពោះការស្ទង់មតិ ESCAP បានរកឃើញថាកម្ពុជាមិនមានផែនការជាតិណាមួយដើម្បីគាំទ្រចល័តភាពអ្នកស្រាវជ្រាវអន្តរជាតិរយៈពេលខ្លី និងមធ្យមទេ។ ជាងនេះទៅទៀត វាមានការលំបាកក្នុងការជំរុញអ្នកស្រាវជ្រាវដែលកំពុងធ្វើការស្រាវជ្រាវ ឬសិក្សានៅបរទេសដើម្បី ឱ្យធ្វើមាតុភូមិនិវត្តន៍មកកម្ពុជា[77]។ ឧបសគ្គមួយចំនួនដែលរារាំងអ្នកស្រាវជ្រាវខ្មែរនៅ និងអ្នកស្រាវជ្រាវបរទេសមកកម្ពុជាក្នុងការស្រាវជ្រាវ និងអភិវឌ្ឍន៍នៅកម្ពុជារួមមាន៖[78] [79]

- កង្វះចំណេះដឹងអំពីឱកាសក្នុងចល័តភាព
- ឧបសគ្គភាសាក្នុងជីវិតប្រចាំថ្ងៃ និងការសិក្សា
- ខ្វះការទទួលស្គាល់ និងផ្លូវអាជីពច្បាស់លាស់
- ភាពខុសគ្នានៃប្រាក់បៀវត្ស សុវត្ថិភាពការងារ ពន្ធ និងទិដ្ឋាការពីប្រទេសមួយប្រទេសមួយទៀត
- កង្វះមូលនិធិសម្រាប់កិច្ចសហការអន្តរជាតិ
- ការប្រកួតប្រជែងខ្លាំងក្នុងចំណោមអ្នកស្រាវជ្រាវកម្ពុជានាំឱ្យអ្នកស្រាវជ្រាវមានពេលវេលាតិចក្នុងគម្រោងសហការ
- កង្វះការគាំទ្រផ្នែកគោលនយោបាយដែលធ្វើឱ្យអាជីពជាអ្នកស្រាវជ្រាវមិនសូវមានភាពទាក់ទាញ
- កង្វះទំនុកចិត្តលើអ្នកសហការផ្សេងទៀតដោយសារផ្នត់គំនិតនិងការប្រកាន់យកតាមទម្លាប់ខ្មែរដោយសារឥទ្ធិពលពីសង្គ្រាមស៊ីវិល
- កង្វះពេលវេលាដើម្បីធ្វើដំណើរទៅជួបអ្នកសហការដែលមានសក្តានុពល។

ឧបសគ្គទាំងនេះបានដាក់កម្រិតឱ្យមានចល័តភាព និងការសហការតិចតួច ហើយជះឥទ្ធិពលដល់ការអភិវឌ្ឍប្រព័ន្ធស្រាវជ្រាវ និងគុណភាពនៃការស្រាវជ្រាវនៅកម្ពុជា។

---

[75] Cambodian Institute for Cooperation and Peace. Doing Research in Cambodia: Making Models that Build Capacity. 2016.
[76] Asia-Pacific Economic Cooperation. Researcher Mobility Workshop Report. 2015.
[77] ESCAP survey.
[78] Asia-Pacific Economic Cooperation. Researcher Mobility Workshop Report. 2015.
[79] Cambodian Institute for Cooperation and Peace, Doing Research in Cambodia: Making Models that Build Capacity. 2016.

### ២.៦.៣. ដំណោះស្រាយដែលមានសក្តានុពល

ដើម្បីពង្រីកកិច្ចសហការស្រាវជ្រាវអន្តរជាតិ អ្នកចូលរួមឆ្លើយតបទៅនឹងការស្ទង់មតិរបស់ ESCAP បានផ្តល់មតិដូចខាងក្រោម៖[80]

- លើកកម្ពស់បណ្តាញរវាងសាកលវិទ្យាល័យនិងសាកលវិទ្យាល័យឱ្យមានភាពរឹងមាំតាមរយៈការសហការស្រាវជ្រាវ
- បង្កើតបរិយាកាសអំណោយផលដល់អ្នកស្រាវជ្រាវទស្សនកិច្ច
- សម្រួលបទប្បញ្ញត្តិនិងលិខិតអនុញ្ញាតការងារ
- គាំទ្រឱ្យមានការស្រាវជ្រាវដែលមានគ្រូដឹកនាំ
- បង្កើនកម្មវិធីសម្រាប់ចល័តភាពឬការផ្លាស់ប្តូរមជ្ឈិមអាជីពរបស់អ្នកស្រាវជ្រាវ។

សរុបសេចក្តីមក ការគាំទ្រដល់កិច្ចសហការស្រាវជ្រាវអន្តរជាតិគឺមិនមានច្រើន និងមិនមានព័ត៌មានច្បាស់លាស់។

## ២.៧. កិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម

ការស្រាវជ្រាវ និងនវានុវត្តន៍មានទំនាក់ទំនងនឹងគ្នាយ៉ាងជិតស្និទ្ធ។ ការស្រាវជ្រាវជួយគាំទ្រសកម្មភាពនៃនវានុវត្តន៍ផ្សេងៗ ហើយសកម្មភាពនវានុវត្តន៍ក៏ជួយជំរុញឱ្យមានការប្រើប្រាស់នូវលទ្ធផលស្រាវជ្រាវចេញជារូបរាងផ្សេងៗផងដែរ។ លើសពីនេះ ការធ្វើពាណិជ្ជកម្មដែលចេញពីនវានុវត្តន៍ក៏ផ្តល់ឱកាសក្នុងបង្កើនហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវបន្ថែមទៀតផងដែរ។ នៅក្នុងប្រព័ន្ធមួយដែលមានដំណើរប្រកបដោយប្រសិទ្ធភាព គឺដោយសារមានស្ថាប័នស្រាវជ្រាវ និងអ្នកនវានុវត្តន៍ ធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាដើម្បីបង្កើតចំណេះដឹងពាក់ព័ន្ធ និងបំពេញតម្រូវការថ្មីៗ។ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច ការស្រាវជ្រាវត្រូវការការលើកស្ទួយតាមរយៈកិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម [81]។

ការគាំទ្រសម្រាប់កិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម រួមមានការលើកកម្ពស់មជ្ឈមណ្ឌលភ្ញាស់ មជ្ឈមណ្ឌលពន្លឿនធុរកិច្ចថ្មី បណ្តុំស្ថាប័នដែលមានលក្ខណៈនវានុវត្តន៍ និងថ្នាលបច្ចេកវិទ្យាដែលបើកចំហទៅកាន់ឧស្សាហកម្ម។ លើសពីនេះ កិច្ចសហការក្នុងកម្រិតអប់រំក៏អាចកើតមានឡើងផងដែរតាមរយៈកម្មវិធីជីវេតដែលមានការចូលរួមពីវិស័យឯកជន[82]។

### ២.៧.១. វិសាលភាពនៃកិច្ចសហការ

ទោះបីជាការសិក្សាផ្នែកធុរកិច្ចមានភាពពេញនិយមយ៉ាងខ្លាំងនៅតាមគ្រឹះស្ថានឧត្តមសិក្សានៅប្រទេសកម្ពុជាក្តី គំនិតផ្តួចផ្តើមដាក់ស្តែងទាក់ទងនឹងសហគ្រិនភាពទើបតែបានលេចឡើងនាពេលថ្មីៗនេះប៉ុណ្ណោះ។

---

[80] ESCAP survey.

[81] Asia-Pacific Economic Cooperation. Researcher Mobility Workshop Report. 2015.

[82] United Nations Economic and Social Commission for Asia and the Pacific. The Science, Technology and Innovation Ecosystem of Cambodia. 2021.

ថ្មីៗនេះ ការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យនិងឧស្សាហកម្ម កន្លែងភ្ញាស់សហគ្រិនភាព និងមជ្ឈមណ្ឌលធុរកិច្ចថ្មី ត្រូវបានបង្កើតឡើងនៅតាមសាកលវិទ្យាល័យជាតិមួយចំនួនដូចជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញសាកលវិទ្យាល័យជាតិគ្រប់គ្រង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា។ សាកលវិទ្យាល័យផ្សេងទៀតបានបង្កើតមន្ទីរពិសោធន៍ដើម្បីលើកកម្ពស់សកម្មភាព និងការយល់ដឹងអំពីឱកាសនៃសហគ្រិនភាព។ គំនិតផ្តួចផ្តើមជាក់លាក់ដូចជាការប្រកួតប្រជែងធុរកិច្ច ការបណ្តុះការធ្វើធុរកិច្ចថ្មីរបស់និស្សិត ជំរុំធុរកិច្ចថ្មី និងកន្លែងធ្វើការរួមគ្នា (Coworking Spaces) ត្រូវបានបង្កើតឡើងដោយ សាកលវិទ្យាល័យជាតិគ្រប់គ្រង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យន័រតុន បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា និង សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ។ បន្ថែមពីនេះ គម្រោងផ្សេងទៀតមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវកម្មវិធីស្វែម និងជីវេត ដើម្បីពង្រឹងកិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម [83]។

យោងតាមលទ្ធផលស្ទង់មតិ ការគាំទ្រដល់ការសហការជាមួយនឹងឧស្សាហកម្ម មាននៅតាមសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវភាគច្រើននៅក្នុងប្រទេសកម្ពុជា (ឧទាហរណ៍ ស្ថាប័នទាំងនោះមានអង្គភាពទទួលបន្ទុកសហការជាមួយនឹងឧស្សាហកម្ម) ប៉ុន្តែកិច្ចសហការនោះនៅមានកម្រិតនៅឡើយ។ ជាទូទៅ ការប្រាស្រ័យទាក់ទងជាមួយវិស័យឯកជនគ្រាន់តែជាព្រឹត្តិការណ៍តែមួយលើកៗ (ឧទាហណ៍ ដំណើរទស្សនកិច្ចសិក្សា ពិព័រណ៍ការងារ ការបណ្តុះបណ្តាល) សិក្ខាសាលានិងសន្និសីទ ប្រព័ន្ធផ្សព្វផ្សាយសង្គម អង្គភាពសហការជាមួយនឹងឧស្សាហកម្ម បណ្តាញដែលមានស្រាប់និងអតីតនិស្សិត និងគេហទំព័ររបស់សាកលវិទ្យាល័យ[84]។

### ២.៧.២. ក្របខណ្ឌបច្ចុប្បន្ន

រាជរដ្ឋាភិបាលកំពុងស្វះស្វែងនិងសម្របសម្រួលកិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម ដោយដាក់ចេញនូវគោលនយោបាយ និងការលើកទឹកចិត្តមួយចំនួន។ ការលើកទឹកចិត្តទាំងនោះរួមមាន ការគាំទ្រផ្នែកបច្ចេកទេស ការផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍និងការកសាងសមត្ថភាព និងការលើកលែងពន្ធសម្រាប់គ្រឹះស្ថានឧត្តមសិក្សា។ ទោះជាយ៉ាងណាក៏ដោយ អ្នកឆ្លើយតបការស្ទង់មតិរបស់ ESCAP ដែលមកពី សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ បានរាយការណ៍ថា ទោះបីជាមានសម្ភារៈបរិក្ខារដូចជាការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យនិងឧស្សាហកម្ម និងការខិតខំប្រឹងប្រែងណែនាំលទ្ធផលស្រាវជ្រាវទៅកាន់វិស័យ ឯកជន (តាមរយៈបណ្តាញ និងព្រឹត្តិការណ៍ផ្សេងៗជាដើម) វានៅតែមិនគ្រប់គ្រាន់សម្រាប់ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវក្នុងការសហការជាមួយឧស្សាហកម្មនៅឡើយ។ មានតែក្រសួងមួយចំនួនប៉ុណ្ណោះដូចជា ក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលបានរាយការណ៍ថា បានផ្តល់ការលើកទឹក

[83] Ibid.
[84] ESCAP survey.

ចិត្តសម្រាប់កិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម[85]។ កង្វះការគាំទ្រផ្នែកហិរញ្ញវត្ថុ និងធនធានផ្សេងទៀត បានរារាំងដល់ការបង្កើនការលើកទឹកចិត្តបន្ថែមទៀតសម្រាប់កិច្ចសហការ។

### ២.៧.៣. តម្រូវការការអភិវឌ្ឍបន្ថែមទៀត

ជំហានដំបូងក្នុងការធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម គឺការចូលរួមពីវិស័យឯកជន និងសាកលវិទ្យាល័យក្នុងការរៀបចំរបៀបវារៈស្រាវជ្រាវជាតិ ដើម្បីធានាថាផលប្រយោជន៍របស់ពួកគេត្រូវបានផ្តួង ហើយឱកាសសម្រាប់កិច្ចសហការអាចកើតឡើងបាន[86]។

ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០ បានកំណត់គោលដៅលើកកម្ពស់កិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម។ យោងតាមផែនទីបង្ហាញផ្លូវនេះ ការកំណត់ចំនួនការិយាល័យភ្ជាប់ទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងឧស្សាហកម្ម ការដាក់បញ្ចូលកម្មសិក្សានៅក្នុងកម្មវិធីសិក្សារបស់គ្រឹះស្ថានឧត្តមសិក្សា ការពង្រឹងទំនាក់ទំនងតាមរយៈបណ្តុំនិងសួនបច្ចេកវិទ្យានិងនវានុវត្តន៍ និងការបង្កើតកម្មវិធីអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយវិស័យឯកជន សុទ្ធតែជាគោលដៅទាំងអស់[87]។

អ្នកឆ្លើយតបការស្ទង់មតិមកពីបណ្តាសាកលវិទ្យាល័យ និងវិស្ថានប័នស្រាវជ្រាវ បានផ្តល់អនុសាសន៍ដូចខាងក្រោមសម្រាប់ការលើកទឹកចិត្តដើម្បីធ្វើកិច្ចសហការជាមួយវិស័យឯកជន៖

- បង្កើតគោលនយោបាយ និងគោលការណ៍ណែនាំលើការងារប្រឹក្សាយោបល់សម្រាប់អ្នកស្រាវជ្រាវក្នុងវិស័យសាធារណៈ (បច្ចុប្បន្នមន្ត្រីរាជការមិនត្រូវបានអនុញ្ញាតឱ្យធ្វើការងារប្រឹក្សាយោបល់ទេ)
- វិភាជន៍មូលនិធិទ្រទ្រង់ធុរកិច្ចថ្មី (seed funds) សម្រាប់ការស្រាវជ្រាវសហការជាមួយវិស័យឯកជន
- ទទួលស្គាល់ និងផ្តល់ការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវដែលធ្វើការជាមួយវិស័យឯកជន ដូចជាពានរង្វាន់ ប្រាក់រង្វាន់ និងការកាត់បន្ថយពន្ធ
- ពង្រឹងកម្មសិទ្ធិបញ្ញា
- បង្កើតថ្នាលអនឡាញសម្រាប់អ្នកស្រាវជ្រាវ រដ្ឋាភិបាល និងវិស័យឯកជន ដើម្បីសហការ និងផ្គូផ្គងតម្រូវការជាមួយនឹងជំនាញ
- សម្របសម្រួលការយកលទ្ធផលស្រាវជ្រាវទៅប្រើប្រាស់នៅក្នុងបរិបទឧស្សាហកម្ម។

អ្នកឆ្លើយតបការស្ទង់មតិមកពីបណ្តាស្ថាប័នសាធារណៈបានបង្ហាញថា រាជរដ្ឋាភិបាលគួរតែផ្តោតលើសកម្មភាពដូចខាងក្រោមដើម្បីអភិវឌ្ឍកិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម បន្ថែមទៀត៖

- បង្កើតគោលនយោបាយស្រាវជ្រាវជាក់លាក់ និងប្រព័ន្ធអេកូឡូស៊ីសម្រាប់អ្នកស្រាវជ្រាវកម្ពុជា

---

[85] ESCAP survey.
[86] Government of the Kingdom of Cambodia. Cambodia's Science, Technology and Innovation Roadmap 2020-2030. 2021b.
[87] Ibid.

- បង្កើតក្រមសីលធម៌ស្រាវជ្រាវជាតិសម្រាប់ឯកជនភាពនៃទិន្នន័យ និងការការពារទិន្នន័យ ដោយធានាថាគ្រប់ស្ថាប័នទាំងអស់យកចិត្តទុកដាក់ចំពោះទិន្នន័យឯកជនភាព និងការការពារទិន្នន័យ
- ពង្រឹងគុណភាពនៃស្ថាប័នស្រាវជ្រាវ និងគ្រឹះស្ថានឧត្តមសិក្សា
- លើកទឹកចិត្តវិនិយោគិនមានដូចជា វិនិយោគិនលើធុរកិច្ចថ្មី ឬមូលនិធិមូលធនឯកជនឱ្យវិនិយោគក្នុងកម្មវិធីមូលនិធិទ្រទ្រង់ធុរកិច្ចថ្មីសម្រាប់ការស្រាវជ្រាវ
- អភិវឌ្ឍក្របខណ្ឌសម្រាប់ការជំរុញកិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម
- ជំរុញការសន្ទនាបន្ថែមទៀតរវាងសាកលវិទ្យាល័យ និងវិស័យឯកជន។

សរុបមក កិច្ចសហការរវាងអ្នកស្រាវជ្រាវ និងឧស្សាហកម្មមិនមានច្រើននិងគ្រប់គ្រាន់នៅឡើយទេ។ ទោះបីជាស្ថាប័នស្រាវជ្រាវអាចមានអង្គភាពដើម្បីជួយសម្រួលដល់កិច្ចសហការនេះក៏ដោយ វាក៏នៅមិនទាន់គ្រប់គ្រាន់នៅឡើយក្នុងការធ្វើមានឱ្យមានកិច្ចសហការជាក់ស្តែង។ ការលើកទឹកចិត្តសម្រាប់កិច្ចសហការមានតិចតួច ហើយការលើកទឹកចិត្តដែលមានស្រាប់ ដូចជាកម្មវិធីបណ្តុះបណ្តាលនិស្សិតស្វែមក្នុងភាពជាដៃគូជាមួយវិស័យ  ឯកជន ដែលយន្តការនៃដំណើរកម្មវិធីនេះនៅមានភាពមិនច្បាស់លាស់នៅឡើយ។

## ២.៨. ធាតុចូលពីគ្រឹះស្ថានសិក្សាសម្រាប់គោលនយោបាយស្រាវជ្រាវ

ការចូលរួមចំណែកនៃការស្រាវជ្រាវទៅលើគោលនយោបាយនៅក្នុងប្រទេសកម្ពុជាអាចនឹងត្រូវបានធ្វើឱ្យប្រសើរឡើង។ ការរួមចំណែកដែលមានកម្រិតនេះ ត្រូវបានសន្មតថាអាចបណ្តាលមកពីសមត្ថភាពស្រាវជ្រាវមិនមានគុណភាពគ្រប់គ្រាន់ លទ្ធផលនៃការស្រាវជ្រាវដែលជាតម្រូវការសម្រាប់គោលនយោបាយនៅមានកម្រិតការលើកទឹកចិត្តដល់អ្នកស្រាវជ្រាវក្នុងការបង្កើតការស្រាវជ្រាវពីគោលនយោបាយនៅមានតិចតួច និងការផ្សព្វផ្សាយពីបេកគំហើញនៃការស្រាវជ្រាវមិនមានប្រសិទ្ធភាព។ ជាទូទៅអង្គការមិនមែនរដ្ឋាភិបាលមានភាពជោគជ័យជាងសាកលវិទ្យាល័យ ក្នុងក្នុងការជះឥទ្ធិពលទៅលើគោលនយោបាយ ពីព្រោះពួកគេមានពេលវេលា និងមូលនិធិគ្រប់គ្រាន់ដើម្បីធ្វើការស្រាវជ្រាវ និងផ្សព្វផ្សាយការស្រាវជ្រាវប្រកបដោយគុណភាព។ ម្យ៉ាងទៀត អង្គការមិនមែនរដ្ឋាភិបាលមិនមានការស្ទាក់ស្ទើរច្រើនទៅលើសកម្មភាពស្រាវជ្រាវ  និងការផ្សព្វផ្សាយពីការស្រាវជ្រាវដែលមានភាពរសើបផ្នែកនយោបាយ ដូចសាកលវិទ្យាល័យ និង ធនាគារគំនិត (Think Tanks) ឡើយ[88]។

ក្នុងការស្ទង់មតិរបស់ ESCAP ទៅកាន់មន្ត្រីរាជរដ្ឋាភិបាល ថាតើពួកគេបានចូលរួមជាមួយអ្នកស្រាវជ្រាវដែរឬទេ? ជាទិដ្ឋភាពរួម លទ្ធផលបានបង្ហាញថាកម្រិតនៃការចូលរួមមានភាពខុសប្លែកគ្នាច្រើនរវាងក្រសួងស្ថាប័ននីមួយៗ ប៉ុន្តែសម្រាប់ប្រភេទស្រាវជ្រាវពាក់ព័ន្ធជាមួយភាគីពាក់ព័ន្ធដែលពួកគេប្រឹក្សាយោបល់វិញ ឃើញថាមិនមានភាពខុសគ្នាច្រើនទេ (ដូចជា  ការចូលរួមរបស់ពួកគេជាមួយអ្នកស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ វិស័យឯកជន ឬសង្គមស៊ីវិល)។ ក្រសួងរ៉ែ និងថាមពល ក្រសួងការបរទេស និង

[88] Cambodian Institute for Cooperation and Peace. Doing Research in Cambodia: Making Models that Build Capacity. 2016.

សហប្រតិបត្តិការ អន្តរជាតិ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានឆ្លើយតបថាពួកគេបានពិគ្រោះយោបល់ជាមួយភាគីស្រាវជ្រាវពាក់ព័ន្ធគ្រប់ប្រភេទ។ ទន្ទឹមនឹងនោះ ក្រសួងផ្សេងទៀតមានការពិគ្រោះយោបល់ជាមួយភាគីស្រាវជ្រាវពាក់ព័ន្ធក្នុងកម្រិតតិចតួច ឬមិនមានសោះតែម្តង។ អ្នកឆ្លើយតបការស្ទង់មតិនេះ បានផ្តល់ឧទាហរណ៍អំពីវិធីដែលការស្រាវជ្រាវមានឥទ្ធិពលលើគោលនយោបាយដូចខាងក្រោម (តារាងទី ២.៨) ។

**តារាង ២. ៨៖** ឧទាហរណ៍អំពីជាតុចូលបានពីការស្រាវជ្រាវដែលបញ្ចូលទៅក្នុងគោលនយោបាយប្រទេសកម្ពុជា

| ក្រសួង | ឧទាហរណ៍អំពីផលជះនៃការស្រាវជ្រាវទៅលើគោលនយោបាយ |
|---|---|
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | របកគំហើញពីការសិក្សាទិដ្ឋភាពបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា ធ្វើឡើងពីឆ្នាំ ២០១៩ ដល់ ២០២០ ដោយមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីតេជោ បានបញ្ចុះបញ្ចូលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបង្កើតមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) ដើម្បីជំរុញការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា។ |
| ក្រសួងផែនការ | របាយការណ៍ផែនទីនៃភាពក្រីក្រ ដែលធ្វើឡើងដោយកម្មវិធីស្បៀងអាហារពិភពលោក និងក្រសួងផែនការ បានផ្តល់អនុសាសន៍មួយចំនួនដើម្បីជូនដំណឹងដល់ការបង្កើតគោលនយោបាយ។ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ដើម្បីគាំទ្រសហគ្រិនភាព ដែលជាក្បាលម៉ាស៊ីនសម្រាប់កំណើនប្រកបដោយនិរន្តរភាពរយៈពេលវែង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានវាយតម្លៃប្រព័ន្ធអេកូឡូស៊ីនៃភាពជាសហគ្រិន និងបានផ្តល់មូលនិធិដល់ការស្រាវជ្រាវ ដើម្បីជូនដំណឹងអំពីការកសាងឧបករណ៍គាំទ្រ និងកម្មវិធីជំនួយ។ ជាលទ្ធផល ក្រសួងបានបង្កើតផែនការ និងស្ថាប័នដូចខាងក្រោម៖<br>១- មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីតេជោ<br>២-ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា<br>៣- មូលនិធិអភិវឌ្ឍន៍ជំនាញ<br>៤-មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និងសហគ្រាសខ្មែរ<br>៥-សាជីវកម្មធានាឥណទានកម្ពុជា។ |

**ប្រភព៖ ការស្ទង់មតិ ESCAP**

យោងតាមអ្នកឆ្លើយតបការស្ទង់មតិ ផលលំបាកចម្បងក្នុងបំលែងលទ្ធផលស្រាវជ្រាវទៅជាគោលនយោបាយគឺ៖

- កង្វះគោលការណ៍ណែនាំពីផលជះនៃគោលនយោបាយ
- កង្វះរបៀបវារៈស្រាវជ្រាវជាតិដែលប្រមូលផ្តុំភាគីពាក់ព័ន្ធទាំងអស់
- គោលនយោបាយ និងរបៀបវារៈកំណែទម្រង់កំពុងផ្លាស់ប្តូរឥតឈប់ឈរ
- កង្វះជំនាញបច្ចេកទេសដើម្បីបំលែងលទ្ធផលស្រាវជ្រាវទៅជាគោលនយោបាយ
- កង្វះអ្នកវិទ្យាសាស្ត្រចូលរួមក្នុងដំណើរការបង្កើតគោលនយោបាយ
- កង្វះទំនាក់ទំនងរវាងអ្នកបង្កើតគោលនយោបាយ និងអ្នកស្រាវជ្រាវ។

## ២.៩. គោលនយោបាយស្រាវជ្រាវ និងក្របខណ្ឌច្បាប់

រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយដើម្បីធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌច្បាប់សម្រាប់ការស្រាវជ្រាវក្នុងប្រទេស។ ផែនការប្រតិបត្តិការប្រចាំឆ្នាំ ២០១៨ នៃ សន្និបាតអប់រំ ២០១៨-២០១៩ មានបែងចែកជាផ្នែកតូចៗ លើការស្រាវជ្រាវជាលក្ខណៈវិទ្យាសាស្ត្រ ដោយបង្ហាញពីគោលបំណងមួយចំនួនទាក់ទងនឹងការកែលម្អការធានាគុណភាពនៃកម្មវិធីបណ្តុះបណ្តាលឧត្តមសិក្សា និង ការផ្សព្វផ្សាយការស្រាវជ្រាវនៅថ្នាក់ឧត្តមសិក្សាទាក់ទងនឹងជំនាញស្វែម [89]។

គោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០១១ មានគោលបំណងដើម្បី "ការកសាងសមត្ថភាពធនធានមនុស្សទាំងផ្នែកចំណេះដឹង ជំនាញ ក្រមសីលធម៌ ការច្នៃប្រឌិត នវានុវត្តន៍ និងសហគ្រិនភាព ដើម្បីបង្កើនការអភិវឌ្ឍយូរអង្វែងនៃសង្គម និងសេដ្ឋកិច្ចកម្ពុជានៅក្នុងបរិបទនៃ សកលភាវូបនីយកម្ម"[90]។ គោលនយោបាយនេះបានលើកឡើងប្រធានបទជាយុទ្ធសាស្ត្រចំនួន ៧៖

- សមត្ថភាពស្រាវជ្រាវ
- គុណភាពស្រាវជ្រាវ
- ការស្រាវជ្រាវសហការ
- របាយការណ៍ស្រាវជ្រាវ
- ក្រមសីលធម៌ស្រាវជ្រាវ និងការអនុញ្ញាតសម្រាប់ការស្រាវជ្រាវ
- កិច្ចសហប្រតិបត្តិការអន្តរជាតិ
- ការស្រាវជ្រាវ និងអភិវឌ្ឍន៍ផ្នែកទីផ្សារ។

---

[89] Ministry of Education, Youth and Sport. Education Congress 2018-2019. The education, youth and sport performance in the academic year 2017-2018 and goals for the academic year 2018-2019. 2019.

[90] Ministry of Education, Youth and Sport. Policy on Research Development in the Education Sector. 2010.

គោលនយោបាយនេះត្រូវបានគាំទ្រដោយផែនការមេសម្រាប់ការអភិវឌ្ឍការស្រាវជ្រាវក្នុងវិស័យអប់រំ (២០១១-២០១៥) សំដៅតែទៅលើគ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំនួនប្រាំបួន ដែលគ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា។ ផែនការរយៈពេលប្រាំឆ្នាំនេះ មានសកម្មភាពគាំទ្រដល់ប្រធានបទជាយុទ្ធសាស្ត្រទាំងប្រាំពីរ ហើយសកម្មភាពនីមួយៗមានបញ្ជាក់ពីគោលបំណង ប្រភពមូលនិធិ និងការទទួលខុសត្រូវ។

ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ ២០១៩-២០២៣ មានយុទ្ធសាស្ត្រកំណែទម្រង់ចំនួន ៩ ទាក់ទងនឹងការអប់រំថ្នាក់ឧត្តមសិក្សា។ យុទ្ធសាស្ត្រកំណែទម្រង់មួយក្នុងចំណោមនោះគឺ "លើកកម្ពស់គុណភាពនៃការស្រាវជ្រាវ" ដោយៈ

- ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពយ៉ាងតិចបី នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- ការបង្កើតមូលនិធិជាតិសម្រាប់ការស្រាវជ្រាវក្នុងការអប់រំថ្នាក់ឧត្តមសិក្សា
- បង្កើតយន្តការជំរុញការលើកទឹកចិត្តអ្នកស្រាវជ្រាវឆ្នើម
- បង្កើតភាពជាដៃគូជាមួយសហគ្រាស និងឧស្សាហកម្ម។

ការចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជាក្នុងឆ្នាំ២០០៤ បានជំរុញឱ្យមានការអនុម័តច្បាប់មួយចំនួនដែលគ្រប់គ្រងលើសិទ្ធិកម្មសិទ្ធិបញ្ញា។ នីតិវិធីប្រកបដោយប្រសិទ្ធភាពសម្រាប់ការចុះបញ្ជី និងការអនុវត្តកម្មសិទ្ធិបញ្ញាត្រូវបានរៀបចំ ហើយច្បាប់កម្មសិទ្ធិបញ្ញារបស់កម្ពុជាមានភាពជឿនលឿនបើធៀបនឹងប្រទេសអាស៊ានដទៃទៀត[91]។ ភាពជាដៃគូជាមួយការិយាល័យកម្មសិទ្ធិបញ្ញានៃប្រទេសសិង្ហបុរីអនុញ្ញាតឱ្យម្ចាស់កម្មសិទ្ធិតក្កកម្ម និងអ្នកដាក់ពាក្យសុំនៅក្នុងប្រទេសសិង្ហបុរី អាចចុះឈ្មោះជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ហើយមាននីតិវិធីតាមដានរហ័សក៏ត្រូវបានរៀបចំឱ្យដំណើរការជាមួយការិយាល័យតក្កកម្មជប៉ុនផងដែរ។ កិច្ចព្រមព្រៀងស្រដៀងគ្នានេះ ត្រូវបានចុះហត្ថលេខាជាមួយការិយាល័យតក្កកម្មអឺរ៉ុប និងការិយាល័យកម្មសិទ្ធិបញ្ញារដ្ឋរបស់ប្រទេសចិនក្នុងឆ្នាំ២០១៧។ នៅទីបំផុតកម្ពុជាក៏បានក្លាយជាសមាជិកនៃសន្ធិសញ្ញាសហប្រតិបត្តិការតក្កកម្មនៅក្នុងឆ្នាំ២០១៦។

អ្នកឆ្លើយតបទៅនឹងការស្ទង់មតិរបស់ ESCAP ពួកភាគច្រើនបានដឹងពីគោលនយោបាយថ្នាក់ជាតិ និងក្របខណ្ឌច្បាប់ដែលមានស្រាប់ ដើម្បីគាំទ្រដល់ការស្រាវជ្រាវ និងនវានុវត្តន៍[92]។ យ៉ាងណាមិញ ពួកគេមិនអាចផ្តល់ព័ត៌មានលម្អិតបន្ថែមបានទេអំពីអ្វីដែលជាភាពខ្វះចន្លោះច្បាស់លាស់គោលនយោបាយស្រាវជ្រាវដែលមានស្រាប់។ ជាងនេះទៅទៀត នៅមានការខ្វះខាតកិច្ចព្រមព្រៀងក្នុងចំណោមភាគីពាក់ព័ន្ធលើភាពគ្រប់គ្រាន់នៃច្បាប់កម្មសិទ្ធិបញ្ញា ដើម្បីលើកទឹកចិត្តដល់នវានុវត្តន៍ក្នុងការស្រាវជ្រាវ ខណៈដែលអ្នកពាក់ព័ន្ធភាគច្រើនយល់ថាវាល្អមគ្រប់គ្រាន់ហើយ ប៉ុន្តែមួយចំនួនផ្សេងទៀតមានទស្សនៈអវិជ្ជមាន និងវិជ្ជមានខ្លាំង។ អ្នកស្រាវជ្រាវមួយ

[91] United Nations Economic and Social Commission for Asia and the Pacific. The Science, Technology and Innovation Ecosystem of Cambodia. 2021.
[92] United Nations Economic and Social Commission for Asia and the Pacific. The Science, Technology and Innovation Ecosystem of Cambodia. 2021.

ចំនួនបានគិតថា គួរតែមានការប្រាស្រ័យទាក់ទងគ្នាបន្ថែមទៀតជុំវិញច្បាប់កម្មសិទ្ធិបញ្ញា ដូចជាតាមរយៈសិក្ខាសាលា ការជជែកពិភាក្សា និងសន្និសីទជាដើម។ អ្នកខ្លះទៀតបានបញ្ជាក់ថា ច្បាប់កម្មសិទ្ធិបញ្ញាមិនមែនជាបញ្ហាចោទទេ ប៉ុន្តែសមត្ថភាពរបស់អ្នកស្រាវជ្រាវក្នុងការធ្វើការស្រាវជ្រាវប្រកបដោយនវានុវត្តន៍ទៅវិញទេដែលជាបញ្ហា។

# ជំពូកទី ៣

# ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង ( SWOT )

តារាង ៣. ១៖ SWOT នៃប្រព័ន្ធស្រាវជ្រាវកម្ពុជា ( ២០២១ )

| ភាពខ្លាំង | ភាពខ្សោយ |
|---|---|
| • សមិទ្ធផលពីគ្រឹះស្ថានអប់រំ និងស្ថាប័នសាធារណៈមានភាពល្អប្រសើរ និងកំពុងមានការកើនឡើង (ទោះបីជាមានមូលដ្ឋានតិចក៏ដោយ) – ផ្លាស់ប្តូរពីការបោះពុម្ពតិចតួចឬគ្មានសោះកាលពីមុនឆ្នាំ ២០០០ ទៅជាមានការបោះពុម្ពប្រហែល ៥០០ ច្បាប់ក្នុងមួយឆ្នាំនៅឆ្នាំ ២០១៨ ដែលក្នុងនោះ ៨០ ភាគរយគឺជាអត្ថបទទាក់ទងនឹងវិទ្យាសាស្ត្រ។ មានការបោះពុម្ពផ្សាយផ្នែកវិទ្យាសាស្ត្រជិត ៥,០០០ ច្បាប់(អត្ថបទ ជំពូកសៀវភៅ ។ល។) ដែលមានអ្នកនិពន្ធ ឬសហអ្នកនិពន្ធក្រោម ស្ថាប័នស្រាវជ្រាវនៅកម្ពុជាក្នុងរយៈពេល ២០ ឆ្នាំកន្លងមកនេះ។ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់លេខ ២៣ នៅអាស៊ី ផ្អែកលើឯកសារវិទ្យាសាស្ត្រដែលបានបោះពុម្ពក្នុងឆ្នាំ ២០១៩ (និងទី ១៩ ប្រសិនបើគិតតែលើការបោះពុម្ពផ្សាយទាក់ទងនឹងវេជ្ជសាស្ត្រតែមួយមុខ)។<br>• ប្រទេសកម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ (និងពឹងផ្អែកលើ) កិច្ចសហការស្រាវជ្រាវអន្តរជាតិ។ ចន្លោះឆ្នាំ ២០០៨ និង ២០១៣ អត្ថបទបោះផ្សាយដោយកម្ពុជាចំនួន ៩៦ ភាគរយពាក់ព័ន្ធនឹងសហអ្នកនិពន្ធអន្តរជាតិយ៉ាងហោចណាស់ម្នាក់ ជានិន្នាការដែលបង្ហាញពីអត្រាសន្ទស្សន៍ដកស្រង់ខ្ពស់។ អ្នកវិទ្យាសាស្ត្រកម្ពុជាធ្វើការជាមួយអ្នកវិទ្យាសាស្ត្រអាស៊ី (ថៃ និងជប៉ុន) និងអ្នកវិទ្យាសាស្ត្រមកពីបស្ចិមប្រទេស (សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និង | • ការស្រាវជ្រាវនៅកម្ពុជាត្រូវបានផ្តោតតែនៅក្នុងសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវសាធារណៈប៉ុណ្ណោះ ហើយសកម្មភាពស្រាវជ្រាវរបស់ពួកគេផ្តោតលើការផលិតការបោះពុម្ពផ្សាយបែបវិទ្យាសាស្ត្រ។ មានការស្រាវជ្រាវតិចតួចណាស់ដែលកំពុងធ្វើឡើងនៅក្នុងវិស័យឯកជន។ សរុបមក អ្នកស្រាវជ្រាវប្រឈមនឹងភាពមានកំណត់ធ្ងន់ធ្ងរក្នុងការស្រាវជ្រាវ រួមមានលទ្ធភាពតិចតួចក្នុងការទទួលបានបុគ្គលិកដែលមានជំនាញ និងទទួលបានការ បណ្តុះបណ្តាលឧបករណ៍ប្រើប្រាស់ ការថែទាំឧបករណ៍ និងការផ្គត់ផ្គង់ ហើយការអនុវត្តការការពារកម្មសិទ្ធិបញ្ញាពីស្ថាប័នស្រាវជ្រាវសាធារណៈនៅមានតិចតួច។<br>• ភាពទាក់ទាញនៃអាជីពជាអ្នកស្រាវជ្រាវនៅមានកម្រិត៖ ប្រាក់បៀវត្ស និងវឌ្ឍនភាពការងារមិនមានភាពទាក់ទាញសម្រាប់អ្នកស្រាវជ្រាវអន្តរជាតិជនចំណាកស្រុកដែលវិលត្រឡប់មកវិញ ឬអ្នកស្រាវជ្រាវថ្មីរបស់កម្ពុជា។<br>• កង្វះឧត្តមភាពក្នុងការស្រាវជ្រាវ ដោយសារបុគ្គលិកស្រាវជ្រាវដែលមានសញ្ញាបត្របណ្ឌិតមានភាគរយទាប កង្វះភាពច្បាស់លាស់ក្នុងការវាយតម្លៃ ការអនុវត្តរបស់អ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ និងកង្វះឧបករណ៍ទំនើប។ អ្នកស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យប្រឈមនឹង |

| | |
|---|---|
| បារាំង) ដែលជាអ្នកសហការជិតស្និទ្ធបំផុតរបស់ពួកគេ។<br>• កម្ពុជាមានឯកសារគោលនយោបាយ វ.ប.ន.សំខាន់ៗ រួមមាន៖ គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០ និងផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០។<br>• ប្រជាជនវ័យក្មេងជាច្រើនដែលត្រូវការការអប់រំកំពុងតែកើនឡើង។<br>• ការកើនឡើងនូវចំនួននិស្សិតស្រីក្នុងកម្រិតឧត្តមសិក្សា។ ៤៧ ភាគរយនៃសិស្សនៅក្នុងការអប់រំកម្រិតឧត្តមសិក្សា (កម្រិតបរិញ្ញាបត្រ) គឺជាស្ត្រី។ | ឧបសគ្គពេលវេលាខ្លាំងដើម្បីធ្វើការស្រាវជ្រាវប្រកបដោយគុណភាព ខ្ពស់។ កិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម មិនទាន់ទទួលបានការលើកទឹកចិត្តគ្រប់គ្រាន់នៅឡើយ។<br>• មានការខ្វះខាតភាពស្របគ្នាក្នុងការកំណត់ប្រធានបទស្រាវជ្រាវដែលមានសារៈសំខាន់បំផុតដោយក្រសួង ស្ថាប័នស្រាវជ្រាវ និងវិស័យឯកជន។<br>• វិសមភាពយេនឌ័រនៅក្នុងជួរបុគ្គលិកស្រាវជ្រាវ ខណៈដែលសមភាពយេនឌ័រកំពុងត្រូវបានធ្វើឱ្យប្រសើរឡើង ស្ត្រីមានត្រឹម ២៣,៧ ភាគរយនៃបុគ្គលិកស្រាវជ្រាវប៉ុណ្ណោះ។<br>• នីតិវិធីផ្តល់មូលនិធិមានភាពស្មុគស្មាញ និងចំណាយពេលច្រើន៖ មានការពិបាកសម្រាប់អ្នកស្រាវជ្រាវក្នុងការស្វែងរកព័ត៌មានបានឆាប់រហ័សអំពីគម្រោងផ្តល់មូលនិធិដែលមានស្រាប់។<br>• មូលនិធិស្រាវជ្រាវដែលអាចរកបានគឺមិនទាន់គ្រប់គ្រាន់ទេ។<br>• ការទទួលស្គាល់ពីសង្គមអំពីសារៈសំខាន់នៃការស្រាវជ្រាវ និងអ្នកស្រាវជ្រាវគឺនៅមានកម្រិត។ |
| **ឱកាស** | **ការគំរាមកំហែង** |
| • កម្ពុជាកំពុងមានសន្ទុះល្អក្នុងការជំរុញ និងលើកកម្ពស់សកម្មភាពស្រាវជ្រាវ៖ ការបង្កើនការទទួលស្គាល់ពីសារៈសំខាន់នៃការស្រាវជ្រាវ ហើយស្ថាប័នស្រាវជ្រាវចំនួនពាក់កណ្តាលមានបំណងចង់បង្កើនចំនួនបុគ្គលិកស្រាវជ្រាវរបស់ពួកគេក្នុងរយៈពេលបីឆ្នាំខាងមុខ។<br>• ប្រធានបទស្រាវជ្រាវជាអាទិភាពត្រូវបានកំណត់រួចរាល់បើទោះបីជាត្រូវការការកែលម្អបន្ថែមបន្តទៅទៀតក៏ដោយ ។<br>• អ្នកពាក់ព័ន្ធទាំងអស់ត្រូវបានតម្រង់ទិសឱ្យផ្តោតលើសារៈសំខាន់នៃការប្រែប្រួលអាកាសធាតុ ដែលជា | • ការប្រកួតប្រជែងក្នុងការផ្តល់មូលនិធិជាមួយមន្ទីរពិសោធន៍អន្តរជាតិមានកម្រិតខ្ពស់ ហើយកង្វះឧត្តមភាពក្នុងការស្រាវជ្រាវមានន័យថាកម្ពុជាមិនមានភាពអំណោយផលក្នុងការប្រកួតប្រជែង។<br>• កង្វះឧត្តមភាពក្នុងការស្រាវជ្រាវនេះបានជំរុញឱ្យវិស័យឯកជននៅកម្ពុជា ទៅធ្វើការសហការជាមួយមន្ទីរពិសោធន៍ស្រាវជ្រាវនៅប្រទេសដទៃ។ |

| | |
|---|---|
| បញ្ហាប្រឈមដ៏ចម្បងនាពេលអនាគតសម្រាប់ប្រទេសកម្ពុជា។<br>• កិច្ចសហការជាមួយបណ្តាប្រទេសអាស៊ាន គឺជាមធ្យោបាយដ៏ប្រសើរមួយដើម្បីបង្កើនការស្រាវជ្រាវជាតិ ។<br>• កិច្ចសហការរវាងវិស័យឯកជននិងសាកលវិទ្យាល័យអាចផ្តល់នូវប្រភពចំណូលថ្មីសម្រាប់សាកលវិទ្យាល័យដែលអាចត្រូវបានប្រើប្រាស់ដើម្បីដំឡើងប្រាក់បៀវត្សរបស់អ្នកស្រាវជ្រាវ។ | |

# ជំពូកទី ៤

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សកម្មភាពមួយក្នុងចំណោមសកម្មភាពផ្សេងទៀតនៅក្រោមផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍កម្ពុជា ២០៣០ គឺការបង្កើតរបៀបវារៈស្រាវជ្រាវជាតិ។ ក្នុងន័យនេះ របៀបវារៈនេះគួរតែកំណត់មហិច្ឆតា និងទិសដៅច្បាស់លាស់សម្រាប់ការស្រាវជ្រាវក្នុងប្រទេសកម្ពុជា និងគាំទ្រការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាបន្នស្របតាមអាទិភាពជាតិ និងរបៀបវារៈឆ្នាំ ២០៣០ ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព។

ផ្អែកលើភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែងបច្ចុប្បន្ននៃការស្រាវជ្រាវនៅកម្ពុជាដែលត្រូវបានកំណត់ខាងលើ របៀបវារៈស្រាវជ្រាវជាតិគួរកំណត់អាទិភាពដោយស្របតាមគោលនយោបាយជាតិ ស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០ និងផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍កម្ពុជា ២០៣០ដូចខាងក្រោម ៖

- បន្សុីប្រធានបទស្រាវជ្រាវទៅនឹងតម្រូវការអភិវឌ្ឍជាតិ៖ កំណត់ការស្រាវជ្រាវបែបតម្រង់ទិសតាមបេសកកម្ម ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃការអភិវឌ្ឍរបស់ប្រទេសកម្ពុជា និងធានាថាការស្រាវជ្រាវដែលមានផលជះជាវិជ្ជមានត្រូវបានធ្វើឡើង។
- បង្កើតកញ្ចប់មូលនិធិស្រាវជ្រាវដើម្បីផ្តល់ហិរញ្ញប្បទានដល់របៀបវារៈស្រាវជ្រាវជាតិ៖ កញ្ចប់មូលនិធិស្រាវជ្រាវនេះត្រូវគ្រប់គ្រងដោយគណៈកម្មាធិការមូលនិធិស្រាវជ្រាវ និងផ្តល់នូវនីតិវិធីប្រកបដោយភាពច្បាស់លាស់និងមានភាពងាយស្រួលសម្រាប់អ្នកស្រាវជ្រាវ។
- កំណត់តួនាទី អាណត្តិ មធ្យោបាយ គោលបំណង និងថវិការបស់ស្ថាប័នស្រាវជ្រាវរដ្ឋាភិបាល៖ បង្កើនសមាមាត្រនៃមូលនិធិសម្រាប់ការស្រាវជ្រាវបែបអនុវត្តន៍(៧០% សម្រាប់ការស្រាវជ្រាវបែបអនុវត្តន៍។ ស្ថាប័នស្រាវជ្រាវ និងស្ថាប័នបណ្តុះបណ្តាលដែលទទួលបានមូលនិធិសាធារណៈគួរជួយគាំទ្រដល់ការប្រើប្រាស់លទ្ធផលស្រាវជ្រាវដែលអាចអនុវត្តជាក់ស្តែងបាននៅក្នុងវិស័យឧស្សាហកម្ម ។
- ជ្រើសរើសស្ថាប័នស្រាវជ្រាវ និងបណ្តុះបណ្តាលដែលទទួលបានមូលនិធិសាធារណៈមួយចំនួន ដើម្បីប្រែក្លាយ ជាមជ្ឈមណ្ឌលឧត្តមភាពក្នុងការស្រាវជ្រាវ ដោយផ្តល់មូលនិធិគ្រប់គ្រាន់ដល់ពួកគេ ឧបករណ៍ទំនើប និងជួលក្រុមអ្នកស្រាវជ្រាវដែលមានគុណវុឌ្ឍិ និងមានសមភាពយេនឌ័រ។

- ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធមុខរបរស្រាវជ្រាវដែលទាក់ទាញ និងការលើកទឹកចិត្តសម្រាប់អ្នកស្រាវជ្រាវដូចជា ការផ្តល់មូលនិធិថ្នាក់បណ្ឌិត ជំនួយហិរញ្ញវត្ថុ និងកម្មវិធីផ្តល់រង្វាន់ដើម្បីលើកកម្ពស់គុណតម្លៃអាជីពស្រាវជ្រាវ។
- លើកទឹកចិត្តដល់វិស័យឯកជន ឱ្យធ្វើការស្រាវជ្រាវដោយសហការជាមួយគ្រឹះស្ថានសិក្សា តាមរយៈការលើកកម្ពស់យន្តការការពារកម្មសិទ្ធិបញ្ញា ការផ្តល់គម្រោងជំនួយសម្រាប់ការស្រាវជ្រាវដែលមានកិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងឧស្សាហកម្ម និងបង្កើតថ្នាលអនឡាញសម្រាប់អ្នកស្រាវជ្រាវ មន្ត្រីរាជរដ្ឋាភិបាល និងវិស័យឯកជនដើម្បីសហការ និងផ្គូផ្គងតម្រូវការទៅនឹងជំនាញ។
- បង្កើតបណ្តាញសាកលវិទ្យាល័យអន្តរជាតិដ៏រឹងមាំ និងផ្តល់ភាពអំណោយផលដល់ចល័តភាពរបស់អ្នកស្រាវជ្រាវ ដើម្បីលើកកម្ពស់កិច្ចសហការស្រាវជ្រាវអន្តរជាតិបន្ថែមទៀត។
- បង្កើតបរិយាកាសដើម្បីគាំទ្រអ្នកស្រាវជ្រាវដែលធ្វើដំណើរមកធ្វើការនៅប្រទេសកម្ពុជាតាមរយៈការសម្របសម្រួលលិខិតអនុញ្ញាតការងារ។
- ជូនដំណឹង និងបណ្តុះបណ្តាលអ្នកបង្កើតគោលនយោបាយ ដើម្បីធ្វើសមាហរណកម្មការស្រាវជ្រាវទៅក្នុងការបង្កើតគោលនយោបាយ តាមរយៈការកំណត់តម្រូវការស្រាវជ្រាវសម្រាប់គោលនយោបាយ ការផ្តល់មូលនិធិសម្រាប់ការបកប្រែលទ្ធផលនៃការស្រាវជ្រាវសម្រាប់ការអនុវត្ត ការបង្កើតបណ្តាញទំនាក់ទំនងអចិន្ត្រៃយ៍រវាងអ្នកស្រាវជ្រាវ និងអ្នកបង្កើតគោលនយោបាយ និងការបង្កើតគណៈកម្មាធិការក្រមសីលធម៌ស្រាវជ្រាវ។

# ឧបសម្ព័ន្ធ "ក" ការកំណត់ទិសដៅប្រធានបទនៃគោលនយោបាយជាតិ

តារាង ក. ១ ៖ភាពស៊ីចង្វាក់គ្នារវាងប្រធានស្រាវជ្រាវ និងគោលនយោបាយជាតិ

| គោលដៅអភិវឌ្ឍប្រកបដោយចីរភាព | យុទ្ធសាស្ត្រចតុកោណ[93] | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣[94] | គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ២០២០-២០៣០[95] | គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥ – ២០២៥[96] | ផែនការមេបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានកម្ពុជាឆ្នាំ ២០២០[97] | ផែនការយុទ្ធសាស្ត្រអប់រំ ២០១៩-២០២៣[98] | ការអភិវឌ្ឍផែនការមេផលិតភាពជាតិកម្ពុជាឆ្នាំ ២០២០-២០៣០[99] |
|---|---|---|---|---|---|---|---|
| គោលដៅទី១៖ បញ្ចប់ភាពក្រីក្រ | | ៣. ការអភិវឌ្ឍធនធានមនុស្ស | | | | | |

93 [2_Rectangular Strategy Phase IV.PDF]
94 http://cdc-crdb.gov.kh/en/strategy/documents/nsdp-2019-2023_en.pdf
95 National Policy on Science Technology and Innovation 2020-2030.pdf
96 Cambodia Industrial Development Policy 2015-2025 (official translation).pdf
97 4_Cambodian-ICT-Masterplan-2020 (Koica).pdf
98 Education Strategic Plan 2019-2023.pdf
99 Productivity Master Plan for Cambodia's (3 Nov 19).pdf

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ្រប់ទម្រង់ នៅគ្រប់ទីកន្លែង | | | | | | | |
| គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្ម ប្រកបដោយចីរភាព | ១.៣. ធ្វើឱ្យប្រសើរឡើងនូវការថែទាំ សុខភាពសាធារណៈ និងអាហារូបត្ថម្ភ | ៣.៣. ការលើកកម្ពស់ សុខភាពសាធារណៈ និងអាហារូបត្ថម្ភ | | | | | |
| គោលដៅទី៣៖ ធានាឱ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូប និងគ្រប់វ័យ | ១.៣. ការធ្វើឱ្យប្រសើរឡើងនូវការថែទាំសុខភាពសាធារណៈ និងអាហារូបត្ថម្ភ | ៣.៣. ការលើកកម្ពស់ សុខភាពសាធារណៈ និងអាហារូបត្ថម្ភ | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គោលដៅទី៤៖ ធានាការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប | ១.១. ការធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>១.២. ការបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣.១. ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>៣.២. ការបណ្តុះបណ្តាលបច្ចេកទេស | ៥.១. ការអភិវឌ្ឍ និងពង្រឹងធនធានមនុស្សវិស័យ វ.ប.ន.ឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ គុណភាព និងសមាសភាពប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងមានសមភាពយេនឌ័រ។<br>៥.២. អនុញ្ញាតឱ្យធនធានមនុស្សវិស័យ វ.ប.ន. ដែលមានកេរ្តិ៍ឈ្មោះ បានដឹកនាំអនុវត្តភារកិច្ច និងបង្កើតយន្តការ | ៤. ការសម្របសម្រួលគោលនយោបាយគាំទ្រដូចជា ការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលជំនាញ និងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងឧស្សាហកម្ម ការអនុវត្តផែនការគ្រប់គ្រងដែនដីនគរូបនីយកម្ម និងការប្រើប្រាស់ដីធ្លី ស្របតាមគោលនយោបាយដីធ្លី និងគោលនយោបាយជាតិស្តីពីការរៀបចំ | ១. ការផ្តល់អំណាចដល់មនុស្ស | បង្កើនលទ្ធភាពទទួលបានគុណភាព សមធម៌ និងបញ្ចូលសេវាកម្មអប់រំកុមារតូច (ECE)។<br>គោលនយោបាយ ១៖ ធានាបាននូវការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ចម្រាញ់ និង លើកកម្ពស់ ដើម្បីបង្កើត បរិយាកាស អំណោយផល ដល់ដល់ ធនធានមនុស្ស ក្នុងវិស័យ វ.ប.ន . ជាតិ អាច អនុវត្តការងារ ប្រកបដោយ សក្តានុពល ពេញលេញ របស់ពួកគេ។ | ដែនដី រួម ជាមួយនឹងការ អភិវឌ្ឍហេដ្ឋា រចនាសម្ព័ន្ធ រួម ទាំងប្រព័ន្ធដឹក ជញ្ជូន/ព័ស្តុការ និងការតភ្ជាប់ឌី ជីថល អគ្គិសនី និងការផ្គត់ផ្គង់ ទឹកស្អាត និង សេវាគាំទ្រផ្សេង ទៀតដូចជា សេ វាសាធារណៈ សេវាសង្គម និង សេវាហិរញ្ញវត្ថុ។ | | | |
| គោលដៅទី៥៖ សម្រេចឱ្យបាន សមភាពយេនឌ័រ និងពង្រឹងភាព អង់អាចរបស់ស្ត្រី និងកុមារីគ្រប់រូប។ | ១.៤. ការពង្រឹង សមភាពយេនឌ័រ និងការការពារស ង្គម។ | ៣.៤. ការធ្វើឱ្យ ប្រសើរឡើង នូវ សមភាពយេន ឌ័រ និងការ | ៥.១. ការអភិវឌ្ឍ និងពង្រឹង ធនធានមនុស្សវិ ស័យ វ.ប.ន.ឱ្យ បានគ្រប់គ្រាន់ ទាំងបរិមាណ | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ការពារសង្គម។ | គុណភាព និង សមាសភាព ប្រកបដោយ ក្រមសីលធម៌ វិជ្ជាជីវៈ និងមាន សមភាពយេនឌ័រ។ | | | | |
| គោលដៅទី៦៖ ធានាឱ្យមានទឹកនិងអនាម័យ និងការគ្រប់គ្រងទឹកនិងអនាម័យ ប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប | ១.៣. ការធ្វើឱ្យប្រសើរឡើងនូវការថែទាំ សុខភាពសាធារណៈ និងអាហារូបត្ថម្ភ | ៦.២. ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ ប្រកបដោយនិរន្តរភាព | | ៤. ការសម្របសម្រួលគោលនយោបាយគាំទ្រដូចជា ការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលជំនាញ និងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងឧស្សាហកម្ម ការអនុវត្តផែនការគ្រប់គ្រងដែនដី | | យុទ្ធសាស្ត្រ ១.៥៖ ផ្តល់ការលាងសម្អាតជាប្រចាំ និងអាហារូបត្ថម្ភ និងការលើកកម្ពស់សុខភាពនៅថ្នាក់មត្តេយ្យសិក្សា | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | នគរូបនីយកម្ម និងការប្រើប្រាស់ដីធ្លី ស្របតាមគោលនយោបាយដីធ្លី និងគោលនយោបាយជាតិស្តីពីការរៀបចំដែនដី រួមជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមទាំងប្រព័ន្ធដឹកជញ្ជូន/ព័ស្តុភារ និងការតភ្ជាប់ឌីជីថល អគ្គិសនី និងការផ្គត់ផ្គង់ទឹកស្អាត និងសេវាគាំទ្រផ្សេងទៀតដូចជា សេវាសាធារណៈ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | សេវាសង្គម និង សេវាហិរញ្ញវត្ថុ។ | | | |
| គោលដៅទី៧៖ ធានាឱ្យទទួលបានថាមពលដែលមានលក្ខណៈ បច្ចេកទេសទំនើប ប្រកបដោយចីរភាព អាចជឿជាក់បាន និងមានតម្លៃសមរម្យសម្រាប់ប្រជាជនគ្រប់រូប | ៤.២. ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយនិរន្តរភាព | ៦.២. ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ ប្រកបដោយនិរន្តរភាព | | ៤. ការសម្រប សម្រួលគោលនយោបាយគាំទ្រដូចជា ការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលជំនាញ និងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងឧស្សាហកម្ម ការអនុវត្តផែនការ គ្រប់គ្រងដែនដីនគរូបនីយកម្ម និងការប្រើប្រាស់ដីធ្លី ស្របតាមគោលនយោបាយដីធ្លី | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | និងគោលនយោបាយជាតិស្តីពីការរៀបចំដែនដី រួមជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមទាំងប្រព័ន្ធដឹកជញ្ជូន/ព័ស្តុការ និងការតភ្ជាប់ឌីជីថល អគ្គិសនី និងការផ្គត់ផ្គង់ទឹកស្អាត និងសេវាគាំទ្រផ្សេងទៀតដូចជា សេវាសាធារណៈ សេវាសង្គម និងសេវាហិរញ្ញវត្ថុ។ | | | |
| គោលដៅទី៨៖ ជានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរ | | ៥.១. ការអភិវឌ្ឍទីផ្សារការងារ | | | | អភិវឌ្ឍកម្មវិធីឌីជីថល | ១. លើកស្ទួយសហគ្រាសធុនតូច និងមធ្យម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ភាព និងបរិយាបន្ន មានមុខរបរពេញលេញ និងផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប | | | | | | សហគ្រិនភាព ភាពជាអ្នកដឹកនាំយុវវ័យក្មេង និងកម្មវិធីជំនាញទន់ផ្សេងទៀតសម្រាប់ការអភិវឌ្ឍយុវជន | ២. រៀបចំសហគ្រាសធំៗក្នុងស្រុកប្រកបដោយផលិតភាព និងភាពប្រកួតប្រជែង<br>៣. ផ្សព្វផ្សាយសារ<br>ផលិតភាពដែលមានសារៈសំខាន់ដល់វិស័យនីមួយៗ |
| គោលដៅ៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងបម្រែបម្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយចីរភាព និងបរិយាបន្ន | ៤.៤. ធានានិរន្តរភាពបរិស្ថាន និងការត្រៀមខ្លួនសម្រាប់ការប្រែប្រួលអាកាសធាតុ។<br>៣. ការលើកកម្ពស់ការអភិវឌ្ឍវិ | ៤.១. ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធព័ស្តុភារ និងការលើកកម្ពស់ការដឹកជញ្ជូនថាមពល និង | ៥.៣. បើកដំណើរការស្រាវជ្រាវ និងអភិវឌ្ឍន៍ជាតិប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលដោយផ្តោតលើការបន្សាំបច្ចេក | ៤. ការសម្របសម្រួលគោលនយោបាយគាំទ្រដូចជា ការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលជំនាញ និងការធ្វើឱ្យប្រសើរ | ៣. ការពង្រឹងសមត្ថភាព<br>៣.១. ឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន | បង្កើនជំនាញឌីជីថល និងលើកកម្ពស់ការអនុវត្តចំណេះដឹងលើវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម) សម្រាប់យុវជន | សហគ្រាសដែលមានផលិតភាព<br>អ្នកបើកដំណើរការអាជីវកម្មដែលមានភាពប្រកួតប្រជែង |

| | | | | | | | |
|---|---|---|---|---|---|---|---|
| និងលើកកម្ពស់នវានុវត្តន៍។ | ស័យឯកជន និងការងារ | ការតភ្ជាប់ឌីជីថល<br>៤.២. ការអភិវឌ្ឍគន្លឹះ និងប្រភពកំណើនសំខាន់ថ្មីៗ<br>៤.៣. ការត្រៀមខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងបដិវត្តន៍ឧស្សាហកម្មជំនាន់ទីបួន។<br>៦.៣. ការពង្រឹងនគរូបនីយកម្ម និងការគ្រប់គ្រង។ | វិទ្យាដែលទទួលបានទៅនឹងបរិបទក្នុងស្រុក និងបង្កើនសមត្ថភាពស្រូបយកបច្ចេកវិទ្យាបរទេស។<br>៥.៤. ការអភិវឌ្ឍនិងពង្រឹងប្រព័ន្ធអេកូឡូស៊ីនវានុវត្តន៍ថាមវន្តជាមួយនឹងសមត្ថភាពសំយោគបច្ចេកវិទ្យា និងវិស្វកម្ម ដើម្បីទទួលបានសមិទ្ធផលជាតិជាមួយនវានុវត្តន៍កើនឡើងឥតឈប់ឈរ ដើម្បីជំរុញឧស្សាហកម្ម និងអាជីវ | ឡើងនូវទំនាក់ទំនងឧស្សាហកម្ម ការអនុវត្តផែនការគ្រប់គ្រងដែនដីនគរូបនីយកម្ម និងការប្រើប្រាស់ដីធ្លី ស្របតាមគោលនយោបាយដីធ្លី និងគោលនយោបាយជាតិស្តីពីការរៀបចំដែនដី រួមជាមួយនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមទាំងប្រព័ន្ធដឹកជញ្ជូន/ព័ស្តុភារ និងការតភ្ជាប់ឌីជីថល អគ្គិសនី និងការផ្គត់ផ្គង់ | | ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មជំនាន់ទីបួន | វិស័យដែលមានតម្លៃបន្ថែមខ្ពស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | កម្មជាតិជាអាទិភាព សម្រាប់ការប្រើប្រាស់ក្នុងស្រុក និងការនាំចេញក្នុងគោលបំណងអភិវឌ្ឍផលិតភាពបន្ថែមទៀត។ | ទឹកស្អាត និងសេវាគាំទ្រផ្សេងទៀតដូចជា សេវាសាធារណៈ សេវាសង្គម និងសេវាហិរញ្ញវត្ថុ។ | | | |
| គោលដៅទី១០៖ កាត់បន្ថយវិសមភាពនៅក្នុងប្រទេស និងក្នុងចំណោមបណ្តាប្រទេសនានា | | | | | | | |
| គោលដៅទី១១៖ ធ្វើឱ្យទីក្រុង និងទីកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជនមានលក្ខណៈបរិយាបន្ន សុវត្ថិភាព ធន់នឹងការប្រែប្រួល | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អាកាសធាតុនិងចីរភាព | | | | | | | |
| គោលដៅទី១២៖ ធានាឱ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់ និង ផលិតកម្ម | | ៦.៤. ការធានានូវនិរន្តរភាពបរិស្ថាន និងការឆ្លើយតបជាមុនចំពោះការប្រែប្រួលអាកាសធាតុ។ | ៥.៥. ការបណ្តុះវប្បធម៌ វ.ប.ន. ក្នុងសង្គមក្នុងលក្ខណៈបរិយាបន្ន ដោយមានគោលបំណងធានានូវទំនុកចិត្ត និងការជឿជាក់របស់សាធារណៈជនលើផលិតផល និងសេវាកម្មដែលប្រើប្រាស់បច្ចេកវិទ្យាជាតិ និងធានាថាអ្នកដែលខិតខំប្រឹងប្រែង និងការវិនិយោគក្នុងការអភិវឌ្ឍវិស័យ វ. | | ២.២. ក្របខណ្ឌច្បាប់<br>៤. ការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មអេឡិចត្រូនិក | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ប.ន. មានការពេញចិត្តចំពោះសមិទ្ធផលរបស់ពួកគេ ក៏ដូចជាពេញចិត្តចំពោះលទ្ធផលនៃកំណែទម្រង់អភិបាលកិច្ច រ.ប.ន.។ | | | | |
| គោលដៅទី១៣៖ ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា។ | | ៦.៤. ការធានានូវនិរន្តរភាពបរិស្ថាន និងការឆ្លើយតបជាមុនចំពោះការប្រែប្រួលអាកាសធាតុ។ | ៥.៥. ការបណ្ដុះវប្បធម៌ រ.ប.ន. ក្នុងសង្គមក្នុងលក្ខណៈបរិយាបន្ន ដោយមានគោលបំណងជានានូវទំនុកចិត្ត និងការជឿជាក់របស់សាធារណៈជនលើផលិតផល និងសេវាកម្មដែល | | ២.២. ក្របខណ្ឌច្បាប់<br>៤. ការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មអេឡិចត្រូនិក | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | ប្រើប្រាស់បច្ចេកវិទ្យាជាតិ និងជានាថាអ្នកដែលខិតខំប្រឹងប្រែង និងការវិនិយោគក្នុងការអភិវឌ្ឍវិស័យ វ.ប.ន. មានការពេញចិត្តចំពោះសមិទ្ធផលរបស់ពួកគេ ក៏ដូចជាពេញចិត្តចំពោះលទ្ធផលនៃកំណែទម្រង់អភិបាលកិច្ច វ.ប.ន. ។ | | | | |
| គោលដៅទី១៤៖ អភិរក្ស និងប្រើប្រាស់ប្រកបដោយចីរភាពនូវមហាសមុទ្រ សមុទ្រ និង | | ៦.២. ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍ ប្រកបដោយចីរភាព។ | | ប្រកបដោយ និរន្តរភាព | | | | | |
| គោលដៅទី១៥៖ ការពារ ស្តារ និង ជំរុញការប្រើប្រាស់ ប្រកបដោយចីរភាព នូវប្រព័ន្ធអេកូឡូស៊ី លើដែនគោក គ្រប់គ្រងព្រៃឈើ ប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដី បញ្ឈប់និង បង្វែរទិសនៃការ សឹករិចរឹលគុណភាពដី និងបញ្ឈប់កុំឱ្យបាត់បង់ដីជាតិដី និងជីវៈចម្រុះ។ | | ៦.២. ការគ្រប់គ្រង ធនធានធម្មជាតិ និងវប្បធម៌ ប្រកបដោយ និរន្តរភាព | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គោលដៅទី១៦៖ លើកកម្ពស់សង្គមដែលមានសន្តិភាព ប្រកបដោយបរិយាបន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ននៅគ្រប់កម្រិត។ | | ៣.៤. ការធ្វើឱ្យប្រសើរឡើងនូវ<br>សមភាពយេនឌ័រ និងការការពារសង្គម។ | | | | | |
| គោលដៅទី១៧៖ ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាពរស់រវើកនូវភាពជាដៃគូសកលសម្រាប់ការ | | | | ២. ការអភិវឌ្ឍ និងធ្វើទំនើបកម្មសហគ្រាសធុនតូច និងមធ្យមតាមរយៈវិធីនៃការពង្រីក និង | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អភិវឌ្ឍប្រកបដោយចីរភាព។ | | | | ពង្រឹងមូលដ្ឋាននៃការផលិត ការធ្វើទំនើបកម្ម និងការចុះបញ្ជីសហគ្រាសជាផ្លូវការ ការលើកកម្ពស់ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យា និងការពង្រឹងទំនាក់ទំនងឧស្សាហកម្មរវាងសហគ្រាសក្នុងស្រុក និងបរទេស ជាពិសេសក្នុងវិស័យកសិឧស្សាហកម្ម។ | | | |
| គោលដៅទី១៨៖ បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់ | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ | | | | | | | |

# ឧបសម្ព័ន្ធ "ខ" ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

## ២.១. ការស្ទង់មតិអ្នកពាក់ព័ន្ធ

### សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ និង ធនាគារខ្ចីក្បាល

ការឆ្លើយតបចំនួន៨ ពីគ្រឹះស្ថានអប់រំចំនួន៧ ផ្សេងគ្នា (សាកលវិទ្យាល័យ/វិទ្យាស្ថានស្រាវជ្រាវ/ធនាគារខ្ចីក្បាល) បានផ្តល់ទិន្នន័យនៃការស្ទង់មតិ[100]។ អ្នកឆ្លើយតបមកពី៖

- វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI៖ វិទ្យាស្ថានស្រាវជ្រាវ)
- វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI៖ វិទ្យាស្ថានស្រាវជ្រាវ/ធនាគារខ្ចីក្បាល)
- វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC៖ វិទ្យាស្ថានស្រាវជ្រាវ)
- វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC៖ វិទ្យាស្ថានស្រាវជ្រាវ)
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA៖ សាកលវិទ្យាល័យ)
- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP៖ សាកលវិទ្យាល័យ)
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (UHS៖ សាកលវិទ្យាល័យ)។

### ស្ថាប័នឯកជន

ស្ថាប័នឯកជនចំនួន ៤ ដែលបានទទួលការឆ្លើយតប៖

- ក្រុមហ៊ុន អេមរ៉ុយស៍(ខេមបូឌា)
- សភាពាណិជ្ជកម្មកម្ពុជា
- ក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប
- ធនាគារសហគ្រាសធុនតូច និងមធ្យម នៃកម្ពុជា។

---

[100] មានអ្នកឆ្លើយតបពីរនាក់ពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ អ្នកឆ្លើយសំណួរទាំងពីរនេះត្រូវបានចាត់ទុកជាការឆ្លើយតបរៀងខ្លួន នោះគឺឯកតានៃការឆ្លើយតបជាមតិផ្ទាល់ខ្លួន មិនមែនស្ថាប័នទេ។

### ក្រសួងនានា

ការឆ្លើយតបចំនួន១៣ ពីក្រសួងចំនួន១៦ ដែលបានផ្តល់ទិន្នន័យ[101]។ អ្នកឆ្លើយតបមកពី៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសុខាភិបាល
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងមហាផ្ទៃ
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងផែនការ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងធនធានទឹក និងឧតុនិយម។

## ២.២. ការសម្ភាសអ្នកពាក់ព័ន្ធ

ការសម្ភាសត្រូវបានធ្វើឡើងជាមួយតំណាងក្រសួងចំនួន ៦ រួមមាន៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសុខាភិបាល
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

[101] មានអ្នកឆ្លើយតបចំនួនពីរមកពីក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងឧស្សាហកម្ម វិទ្យាសស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ អ្នកឆ្លើយតបនីមួយៗត្រូវបានចាត់ទុក គឺឯកតានៃការឆ្លើយតបជាមតិផ្ទាល់ខ្លួន មិនមែនក្រសួងទេ។

# ឧបសម្ព័ន្ធ "គ" ការឆ្លើយតបការស្ទង់មតិប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវ

## ៣.១. អន្តរភាពស្រាវជ្រាវ

### *៣.១.១. តើការស្រាវជ្រាវមានសារៈសំខាន់យ៉ាងណាចំពោះបេសកកម្មរបស់សាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវ?*

**សាកលវិទ្យាល័យ/វិទ្យាស្ថានស្រាវជ្រាវ/ធនាគារខួរក្បាល**

ភាគច្រើន (៧ក្នុងចំណោម ៨ ស្ថាប័ន) នៃអ្នកឆ្លើយតបរបស់សាកលវិទ្យាល័យ/វិទ្យាស្ថានស្រាវជ្រាវ បានអះអាងថាការស្រាវជ្រាវគឺ "មានសារៈសំខាន់ណាស់" សម្រាប់ស្ថាប័នរបស់ពួកគេ មានតែវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាប៉ុណ្ណោះ បានបញ្ជាក់ថាការស្រាវជ្រាវមាន "សំខាន់ខ្លះៗ"។ ម្យ៉ាងទៀត ភាគច្រើន (៦ ស្ថាប័ន) ក៏បានលើឡើងថាការស្រាវជ្រាវមានតួនាទីយ៉ាងសំខាន់នៅក្នុងសាកលវិទ្យាល័យរបស់ពួកគេ ប៉ុន្តែវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី បាននិយាយថាវាដើរតួនាទីសំខាន់តិចតួចប៉ុណ្ណោះ។

ស្ថាប័ននីមួយៗអាចមានគោលដៅសំខាន់សម្រាប់ការស្រាវជ្រាវផ្សេងគ្នា។ ជាក់ស្តែង វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និង វិទ្យាស្ថានចក្ខុវិស័យអាស៊ី ធ្វើការស្រាវជ្រាវក្នុងគោលបំណងដើម្បីឱ្យលទ្ធផលនៃការស្រាវជ្រាវមានឥទ្ធិពលលើគោលនយោបាយ។ ផ្ទុយទៅវិញសាកលវិទ្យាល័យភូមិន្ទកសិកម្មមានគោលដៅដើម្បីឱ្យមានឥទ្ធិពលកាន់តែច្រើននៅក្នុងវិស័យឯកជន ដោយបានកំណត់គោលដៅយ៉ាងច្បាស់ថាលទ្ធផលនៃការស្រាវជ្រាវច្រើនជាង៥០ លទ្ធផល ត្រូវបានទទួលយកដោយវិស័យឯកជនក្នុងរយៈពេល ១០ ឆ្នាំខាងមុខ។ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល មានគោលដៅក្នុងការទទួលបាននូវការទទួលស្គាល់ជាលក្ខណៈជាតិ និងអន្តរជាតិថាជាមជ្ឈមណ្ឌលឧត្តមភាពមួយសម្រាប់ការស្រាវជ្រាវ និងនវានុវត្តន៍។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានគោលដៅជាក់លាក់ចំនួន ៣ រួមមាន៖

- គោលដៅទី១៖ បង្កើតប្រព័ន្ធមួយសម្រាប់ការធានាគុណភាពស្រាវជ្រាវ និងការពារកម្មសិទ្ធិបញ្ញា
- គោលដៅទី២៖ កៀរគរធនធានហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវទំនើបសម្រាប់កម្មវិធីក្រោយឧត្តមសិក្សា និងក្រោយបណ្ឌិតនៅក្នុងមហាវិទ្យាល័យនីមួយៗ
- គោលដៅទី៣៖ អនុវត្តមុខតំណែងសម្រាប់តែការស្រាវជ្រាវនៅសាកលវិទ្យាល័យ និងគម្រោងលើកទឹកចិត្តផ្សេងទៀតសម្រាប់មហាវិទ្យាល័យដែលសម្រេចបាននូវសមិទ្ធផលឆ្នើម។

ជារួម ការស្រាវជ្រាវត្រូវបានចាត់ទុកថាមានសារៈសំខាន់ដោយស្ថាប័នភាគច្រើន ប៉ុន្តែអ្វីដែលមានលក្ខណៈខុសគ្នាគឺវិធីសាស្ត្រដែលស្ថាប័នទាំងនេះចង់ឱ្យលទ្ធផលនៃការស្រាវជ្រាវរបស់ពួកគេត្រូវបានប្រើប្រាស់ រួមមានសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន សម្រាប់ឧត្តមភាពក្នុងការស្រាវជ្រាវ (សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ) សម្រាប់ផ្តល់ទិសដៅគោលនយោបាយ ( វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី) ឬសម្រាប់ផ្តល់ផលប្រយោជន៍ដល់វិស័យឯកជន (សាកលវិទ្យាល័យភូមិន្ទកសិកម្ម)។ លើសពីនេះទៅទៀត ស្ថាប័នចំនួនប្រាំក្នុងចំណោមស្ថាប័នទាំងប្រាំបី បានកំណត់យុទ្ធសាស្ត្រស្រាវជ្រាវជាលាយលក្ខណ៍អក្សរផងដែរ (តារាងទី១០)។

**តារាង គ. ១៖ គ្រឹះស្ថានសិក្សានិងយុទ្ធសាស្ត្រស្រាវជ្រាវដែលបានកំណត់ជាលាយលក្ខណ៍អក្សរ**

| ស្ថាប័ន | យុទ្ធសាស្ត្រស្រាវជ្រាវដែលបានកំណត់ជាលាយលក្ខណ៍អក្សរ |
|---|---|
| វិទ្យាស្ថានចក្ខុវិស័យអាស៊ី | យុទ្ធសាស្ត្រស្រាវជ្រាវដែលទទួលយក និងសម្របទៅតាមប្រភេទនៃការស្រាវជ្រាវ |
| សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | គោលនយោបាយស្តីពីការអភិវឌ្ឍការស្រាវជ្រាវ និងនវានុវត្តន៍ |
| សាកលវិទ្យាល័យភូមិន្ទកសិកម្ម | មានក្នុងយុទ្ធសាស្ត្រ ១០ឆ្នាំ របស់សាកលវិទ្យាល័យដែលបានធ្វើបច្ចុប្បន្នភាព[102] |
| វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា | បានបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រ ៥ឆ្នាំរបស់ខ្លួន |
| សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | (មិនមានព័ត៌មានលម្អិត) |

ភាគរយនៃពេលវេលាដែលបុគ្គលិកស្រាវជ្រាវបានចំណាយលើការស្រាវជ្រាវមានចាប់ពី ៥ភាគរយនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ដល់៩០ភាគរយនៅវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។ ប្រហែលពាក់កណ្តាលនៃអ្នកឆ្លើយតប (សាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានចក្ខុវិស័យអាស៊ី និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ) បានបញ្ជាក់ថាភាគរយនេះបានកើនឡើងក្នុងរយៈពេល ៣ឆ្នាំចុងក្រោយនេះ។ ឆ្លើយតបនៅនឹងសំណួរដែលបានសួរថា «តើពួកគេមានបំណងបង្កើនចំនួនបុគ្គលិកស្រាវជ្រាវក្នុងរយៈពេល ៣ឆ្នាំ

[102] អ្នកឆ្លើយតបបានលើកឡើងថា សាកលវិទ្យាល័យភូមិន្ទកសិកម្ម ធ្លាប់មានសេចក្តីព្រាងរបៀបវារៈស្រាវជ្រាវ និងគោលនយោបាយស្រាវជ្រាវ ប៉ុន្តែសេចក្តីព្រាងនេះមិនទាន់ពេញលេញនៅឡើយ និងតម្រូវឱ្យមានការកែលម្អ និងធ្វើបច្ចុប្បន្នភាព។

ខាងមុខដែរឬទេ?" ពាក់កណ្ដាលនៃអ្នកឆ្លើយតប (កលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានចក្ខុវិស័យអាស៊ី សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល) បានឆ្លើយថាពួកគេមានបំណងចង់បង្កើនចំនួនបុគ្គលិកស្រាវជ្រាវ។ សាកលវិទ្យាល័យភូមិន្ទកសិកម្ម បានបញ្ជាក់បន្ថែមទាក់ទងនឹងការបង្កើនចំនួនបុគ្គលិកស្រាវជ្រាវថា ពួកគេចង់បង្កើនសកម្មភាពស្រាវជ្រាវ និងមានគម្រោងរៀបចំផែនការដើម្បីបញ្ជាក់ឱ្យច្បាស់ថាតើការស្រាវជ្រាវ និងការបង្រៀន គួរតែជាតួនាទីដាច់ដោយឡែក ឬរួមបញ្ចូលគ្នា។ ការបញ្ជាក់ពីតួនាទីនេះនឹងផ្ដល់ការលើកទឹកចិត្ត ឬសកម្មភាពមួយចំនួនដើម្បីបង្កើនសកម្មភាពស្រាវជ្រាវ។

### *៣.១.២. តើមានបុគ្គលិកស្រាវជ្រាវ និងនិស្សិតបណ្ឌិតប៉ុន្មាននាក់នៅក្នុងសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវទាំងនេះ?*

បុគ្គលិកស្រាវជ្រាវចំនួនតិចតួចប៉ុណ្ណោះ (៥ ឬ ៦ នាក់) នៅក្នុង វិទ្យាស្ថានចក្ខុវិស័យអាស៊ី និងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ខណៈ បុគ្គលិកស្រាវជ្រាវមានចំនួនមធ្យម នៅក្នុង វិទ្យាស្ថានបណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (៣០ នាក់) និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (៦០ នាក់)។ បុគ្គលិកស្រាវជ្រាវមានច្រើននៅក្នុងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (១០៥ នាក់) សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (១៦១ នាក់) និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម (៣០៥ នាក់)។ សមាមាត្រនៃបុគ្គលិកស្រាវជ្រាវជាស្ត្រីប្រែប្រួលពី ០ ភាគរយនៅ វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា  ទៅ ៥០ ភាគរយនៅ វិទ្យាស្ថានចក្ខុវិស័យអាស៊ី និងវិទ្យាស្ថានបណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។ ភាគរយនៃបុគ្គលិកស្រាវជ្រាវដែលមានសញ្ញាបត្រថ្នាក់បណ្ឌិតមានកម្រិតទាបណាស់គឺចាប់ពី ០ ភាគរយនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា  ដល់ ២៥ ភាគរយនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងវិទ្យាស្ថានបណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។

ចំនួននិស្សិតថ្នាក់បណ្ឌិតក្នុងស្ថាប័នទាំងនេះមានខុសគ្នា។ វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងវិទ្យាស្ថានបណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា មិនមាននិស្សិតថ្នាក់បណ្ឌិតទេ ខណៈ វិទ្យាស្ថានចក្ខុវិស័យអាស៊ី មាននិស្សិតថ្នាក់បណ្ឌិតចំនួន ៨ នាក់ (៥ភាគរយជាស្ត្រី) និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានចំនួន ២០ នាក់ (២០ភាគរយជាស្ត្រី)។ ចំណែកសាកលវិទ្យាល័យភូមិន្ទកសិកម្មមាននិស្សិតថ្នាក់បណ្ឌិតចំនួន ៣១ នាក់ (២០ ភាគរយជាស្ត្រី) និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានចំនួន ៨៩ នាក់ (១០ ភាគរយជាស្ត្រី)។

ស្របតាមការស្រាវជ្រាវដែលមានស្រាប់ គំរូសំណាកនេះបានបង្ហាញថាសមាមាត្រទាំងនិស្សិតថ្នាក់បណ្ឌិត និងបុគ្គលិកជាស្ត្រី គឺមានកម្រិតទាបណាស់។ ម្យ៉ាងទៀត សមាមាត្រនៃបុគ្គលិកដែលមានសញ្ញាបត្របណ្ឌិតក៏មានកម្រិតទាបខ្លាំងផងដែរ។

### ៣.១.៣. តើស្ថានភាពនៃឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវមានលក្ខណៈដូចម្តេច?

សាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវមានការឆ្លើយតបផ្សេងគ្នាចំពោះសំណួរទាក់ទងនឹងស្ថានភាពគ្រប់គ្រាន់នៃហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវចាំបាច់សម្រាប់ស្ថាប័នរបស់ពួកគេ រួមមាន ឧបករណ៍វិទ្យាសាស្ត្រ កម្មវិធីសុសវែរនិងផ្នែករឹងនៃកុំព្យូទ័រ បណ្ណាល័យ និងបណ្ណសារ។ សាកលវិទ្យាល័យភូមិន្ទកសិកម្ម បានលើកឡើងថា សាកលវិទ្យាល័យខ្លួន មិនមានឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវគ្រប់គ្រាន់នោះទេ ចំណែកស្ថាប័នចំនួន ៤ (វិទ្យាស្ថានចក្ខុវិស័យអាស៊ី វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល) បានបញ្ជាក់ថា ស្ថាប័នមានឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវគ្រប់គ្រាន់ចំពោះផ្នែកខ្លះ ផ្ទុយមកវិញ ស្ថាប័ន ចំនួន ២ (វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា) បានអះអាងថាស្ថាប័នរបស់ពួកគេមានឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវគ្រប់គ្រាន់។ ការផ្តល់ចំនួនបុគ្គលិកផ្នែកជំនួយបច្ចេកទេសនៅក្នុងស្ថាប័នទាំងនេះមានលក្ខណៈល្អប្រសើរជាងឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវបន្តិច ដោយសារស្ថាប័នចំនួន ៥ (សាកលវិទ្យាល័យភូមិន្ទកសិកម្ម វិទ្យាស្ថានចក្ខុវិស័យអាស៊ី សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា) បានបញ្ជាក់ថា ស្ថាប័នរបស់ពួកគេមានចំនួនបុគ្គលិកផ្នែកជំនួយបច្ចេកទេសគ្រប់គ្រាន់។ ចំណែក ស្ថាប័នចំនួនពីរ (វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា និងវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា) បានអះអាងថា ស្ថាប័នរបស់ពួកគេមានចំនួនបុគ្គលិកផ្នែកជំនួយបច្ចេកទេសគ្រប់គ្រាន់ពេញលេញ។ ឆ្លើយតបទៅនឹងសំណួរអំពីតម្រូវការក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ស្ថាប័នទាំងនេះបានលើកឡើងពីតម្រូវការកុំព្យូទ័រ កម្មវិធីសុសវែរនិងមូលដ្ឋានទិន្នន័យ ដំណោះស្រាយចំពោះការគ្រប់គ្រងការស្រាវជ្រាវ ធនធានមនុស្ស និងឧបករណ៍វិទ្យាសាស្ត្រឯកទេស។

### ៣.១.៤. តើឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធនេះអាចប្រៀបធៀបទៅនឹងស្ថាប័នដែលធ្វើការស្រាវជ្រាវក្នុងវិស័យឯកជនយ៉ាងដូចម្តេច?

**វិស័យឯកជន**

ក្រុមហ៊ុន អេមរ៉ាយស៍(ខេមបូឌា) និងក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប បានបញ្ជាក់ថា ក្រុមហ៊ុនបានធ្វើការស្រាវជ្រាវមួយចំនួនតិចតួចប៉ុណ្ណោះ។ ការស្រាវជ្រាវរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងទាំងក្នុង និងនៅអង្គភាពស្រាវជ្រាវខាងក្រៅ។ ក្រុមហ៊ុន អេមរ៉ាយស៍(ខេមបូឌា) បានបញ្ជាក់ថា ការស្រាវជ្រាវមានសារៈសំខាន់ណាស់ចំពោះក្រុមហ៊ុន របស់ពួកគេ។ គោលបំណងសំខាន់របស់ការស្រាវជ្រាវ គឺការអភិវឌ្ឍផលិតផល និងការផ្តល់ផលប៉ះពាល់វិជ្ជមានដល់វិស័យសេដ្ឋកិច្ចសង្គមលើខ្សែចង្វាក់ផ្គត់ផ្គង់។ គោលដៅចម្បងរបស់ការស្រាវជ្រាវគឺដើម្បីកំណត់មធ្យោបាយថ្មីដែលមានសក្តានុពលលើការធ្វើពិពិធកម្មផលិតផល។ ក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប ក៏បានបញ្ជាក់ផងដែរថា ការស្រាវជ្រាវមានសារៈសំខាន់ណាស់ចំពោះក្រុមហ៊ុន។ គោលបំណងរបស់ការស្រាវជ្រាវ គឺការអភិវឌ្ឍផលិតផល

ស្របទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់។ គោលដៅចម្បងរបស់ការស្រាវជ្រាវផ្តោតលើការកែលម្អផលិតផលដើម្បីឱ្យការផលិតកាន់តែមានប្រសិទ្ធភាព និងបំពេញតម្រូវការអតិថិជនកាន់តែប្រសើរឡើង។ សហគ្រាសធនតូច និងមធ្យម និងសភាពាណិជ្ជកម្មកម្ពុជា បានអះអាងថា ពួកគេធ្វើការស្រាវជ្រាវបានតិចតួចណាស់។ ស្ថាប័នឯកជនទាំងនេះ មិនមានយុទ្ធសាស្ត្រស្រាវជ្រាវជាលាយលក្ខណ៍អក្សរនោះទេ។

ក្រុមហ៊ុន អេមរ៉ាយស៍(ខេមបូឌា) មានអ្នកស្រាវជ្រាវចំនួន ៣នាក់ ខណៈដែល ក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប មានអ្នកស្រាវជ្រាវចំនួន ៥នាក់ នៃចំនួនបុគ្គលិកសរុបរបស់ក្រុមហ៊ុន។ ម្ចាស់ក្រុមហ៊ុនទាំងពីរបានលើកឡើងថា បុគ្គលិកស្រាវជ្រាវរបស់ពួកគាត់បានចំណាយពេលប្រហែល ២០ភាគរយនៃពេលវេលាការងារក្នុងការធ្វើការស្រាវជ្រាវ។ និន្នាការនេះមិនមានការផ្លាស់ប្តូរទេក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ។ ប៉ុន្តែក្រុមហ៊ុនទាំងពីរនេះមានគោលបំណងក្នុងការបង្កើនចំនួនបុគ្គលិកស្រាវជ្រាវក្នុងរយៈពេលបីឆ្នាំខាងមុខ។ បុគ្គលិកស្រាវជ្រាវជាស្ត្រីរបស់ក្រុមហ៊ុន អេមរ៉ាយស៍(ខេមបូឌា) មាន ២០ភាគរយ និងក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប មាន ១០ ភាគរយ។

ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធនៃការស្រាវជ្រាវ ក្រុមហ៊ុន អេមរ៉ាយស៍(ខេមបូឌា) បានលើកឡើងថា ហេដ្ឋារចនាសម្ព័ន្ធនៃការស្រាវជ្រាវគួរតែមានការកែលម្អ តាមរយៈការបង្កើនធនធានមនុស្សរបស់ក្រុមហ៊ុន ជាពិសេសអ្នកជំនាញផ្នែកអាហារ និងផ្នែកទីផ្សារ។ ក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប បាននិយាយថា ពួកគេមានបំណងចូលប្រើមូលទិន្នន័យអនឡាញនៃទិន្នន័យដែលមានស្រាប់។ ក្រុមហ៊ុន អេមរ៉ាយស៍(ខេមបូឌា) មិនចាប់អារម្មណ៍ក្នុងការចែករំលែកហេដ្ឋារចនាសម្ព័ន្ធជាមួយសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវនោះទេ ប៉ុន្តែ ក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប បានបង្ហាញការចាប់អារម្មណ៍ក្នុងការចែករំលែកហេដ្ឋារចនាសម្ព័ន្ធជាមួយសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវ។

## ៣.២. ប្រធានបទស្រាវជ្រាវ

### *៣.២.១. តើប្រធានបទស្រាវជ្រាវសំខាន់ៗ អ្វីខ្លះគួរត្រូវបានផ្តោតការយកចិត្តទុកដាក់សម្រាប់សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ និងវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រឈមរបស់ពួកគេ?*

### *៣.២.២. តើកម្ពុជានឹងប្រឈមនឹងបញ្ហាអ្វីខ្លះនាពេលអនាគត ហើយតើអ្នកស្រាវជ្រាវរបស់ប្រទេសកម្ពុជាគួរផ្តោតលើប្រធានបទអ្វីខ្លះ ដើម្បីដោះស្រាយបញ្ហាទាំងនោះ?*

#### សាកលវិទ្យាល័យ/វិទ្យាស្ថានស្រាវជ្រាវ និងវិស័យឯកជន

ដើម្បីឆ្លើយតបចំពោះសំណួរទាំងនេះ សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ និងវិស័យឯកជនត្រូវបានធ្វើការវិភាគរួមគ្នា ដោយសារការវិភាគនេះផ្តោតសំខាន់លើការចាប់អារម្មណ៍ជាទូទៅរបស់ស្ថាប័នទាំងនេះ។ ស្ថាប័នទាំងនេះត្រូវបានសួរអំពីប្រធានបទស្រាវជ្រាវសំខាន់ៗចំនួនប្រាំនៅក្នុងស្ថាប័នរបស់ពួកគេ នាពេលបច្ចុប្បន្ន។ ប្រធានបទដែលត្រូវបានរាយការណ៍ច្រើនជាងគេបំផុតនោះគឺ ប្រធានបទកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិស្វកម្មអគ្គិសនី និងវិស្វកម្មមេកានិច (រូបភាពទី គ.១)។ ឆ្លើយតបទៅនឹងសំណួរអំពីប្រធានបទដែលរបៀបវារៈស្រាវជ្រាវ

ជាតិគួរតែផ្តោតលើ រហូតដល់ឆ្នាំ ២០២៥ ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់ប្រទេសកម្ពុជានាពេលអនាគត ពួកគេបានផ្តល់អាទិភាពលើ ប្រធានបទកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានបន្ទាប់ គឺវិស្វកម្ម (មេកានិច និងអគ្គិសនី) ការស្រាវជ្រាវវេជ្ជសាស្ត្រកម្រិតមូលដ្ឋាន និងវិស្វកម្មបរិស្ថាន (រូបភាព គ.១)។

**រូបភាព គ. ១៖** ប្រធានបទស្រាវជ្រាវភាគច្រើននាពេលបច្ចុប្បន្ននៅកម្ពុជា និងប្រធានបទស្រាវជ្រាវដែលគួរតែជាអាទិភាពសម្រាប់របៀបវារៈស្រាវជ្រាវជាតិឆ្នាំ ២០២៥ យោងទៅតាមសាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ និង វិស័យឯកជន




ការឆ្លើយតបមានភាពចម្រុះចំពោះសំណួរទាក់ទងនឹងប្រធានបទស្រាវជ្រាវបច្ចុប្បន្ន ដែលបានដោះស្រាយបញ្ហាប្រឈមរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ អ្នកឆ្លើយតបចំនួន ៥នាក់បាននិយាយថា "ប្រធានបទស្រាវជ្រាវបច្ចុប្បន្ន បានដោះស្រាយបញ្ហាប្រឈមជាច្រើន" ប៉ុន្តែ អ្នកឆ្លើយតបចំនួណ ៤នាក់បានបញ្ជាក់ថា "ប្រធាន

បទស្រាវជ្រាវបច្ចុប្បន្ន បានដោះស្រាយបញ្ហាប្រឈមក្នុងកម្រិតតិចតួច»។ នៅពេលសួរព័ត៌មានលម្អិតបន្ថែម ពួកគេភាគច្រើននិយាយអំពីការស្រាវជ្រាវផ្នែកកសិកម្មដែលបានកំពុងដោះស្រាយបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ ព្រមទាំងជំរុញឱ្យមានការបង្កើនផលិតផល និងការអនុវត្តប្រកបដោយនិរន្តរភាព។ អ្នកឆ្លើយតបក៏បានលើកឡើងអំពីបញ្ហាប្រឈមនាពេលអនាគតដែលប្រទេសកម្ពុជានឹងជួបប្រទះផងដែរ។ បញ្ហាប្រឈមនេះគឺភាគច្រើនទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដែលទាមទារឱ្យមានការស្រាវជ្រាវបន្ថែម ដើម្បីជំរុញការគាំទ្រផលិតផល និងការអនុវត្តប្រកបដោយភាពស្អាត សុវត្ថិភាព និរន្តរភាព និងការប្រកួតប្រជែងជាងមុន។

### ក្រសួងពាក់ព័ន្ធ

មន្ត្រីនៃក្រសួងពាក់ព័ន្ធត្រូវបានសួរអំពីប្រធានបទស្រាវជ្រាវចំនួនប្រាំដែលមានសារៈសំខាន់បំផុតនាបច្ចុប្បន្នសម្រាប់បេសកកម្មសម្រាប់ក្រសួងរបស់ពួកគេ[103]។ បច្ចុប្បន្ននេះ ប្រធានបទដែលត្រូវបានលើកឡើងញឹកញាប់បំផុត គឺ «សេដ្ឋកិច្ច និងអាជីវកម្ម» បន្ទាប់មកគឺ «កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ» "កុំព្យូទ័រ និងព័ត៌មានវិទ្យា" «បច្ចេកវិទ្យាជីវសាស្ត្របរិស្ថាន» និង «វិទ្យាសាស្ត្រអប់រំ» (រូបភាពទី គ.២)។ នៅពេលសួរពីប្រធានបទដែលគួរតែដាក់បញ្ចូលទៅក្នុងរបៀបវារៈស្រាវជ្រាវជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់កម្ពុជានាពេលអនាគត ការឆ្លើយតបមានការផ្លាស់ប្តូរបន្តិច ដោយសារពួកគេបាន ភាគច្រើននិយាយអំពី "កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ" បន្ទាប់មកគឺ "សេដ្ឋកិច្ច និងអាជីវកម្ម" "វិទ្យាសាស្ត្រកុំព្យូទ័រ និងព័ត៌មាន" "វិទ្យាសាស្ត្រអប់រំ" និង "វិស្វកម្មបរិស្ថាន" (រូបភាពទី គ.២)។

[103] N.B., 9 "other" responses non-codable so not included here.

**រូបភាព គ. ២៖** ប្រធានបទស្រាវជ្រាវភាគច្រើននាពេលបច្ចុប្បន្ននៅកម្ពុជា និងប្រធានបទស្រាវជ្រាវដែលគួរតែជាអាទិភាពនៃរបៀបវារៈស្រាវជ្រាវជាតិ ២០២៥ យោងតាមក្រសួងនានា




ការឆ្លើយតបមានលក្ខណៈផ្សេងគ្នាចំពោះសំណួរអំពីស្ថាប័នស្រាវជ្រាវស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ពួកគេដែលកំពុងអនុវត្តនាបច្ចុប្បន្នត្រូវបានលើកឡើងនៅក្នុងប្រធានបទស្រាវជ្រាវដែលបានដាក់ក្នុងតារាងបញ្ជីប្រធានបទ។ អ្នកឆ្លើយតបចំនួន៩នាក់ ក្នុងចំណោម ១៥ នាក់ បាននិយាយថា "មានតិចតួច" ខណៈអ្នកឆ្លើយតបចំនួន ៤នាក់បាននិយាយថា "មិនមានក្នុងបញ្ជី" ហើយមានតែអ្នកឆ្លើយតបចំនួន២នាក់ប៉ុណ្ណោះដែលនិយាយថា "មានទាំងអស់"។ ជាការពិតណាស់ ប្រធានបទស្រាវជ្រាវសំខាន់ៗបំផុតសម្រាប់ក្រសួង មិនមានភាពស៊ីគ្នាទៅនឹងប្រធានបទស្រាវជ្រាវដែលសាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ និងវិស័យឯកជនកំពុងធ្វើការស្រាវជ្រាវនាពេលបច្ចុប្បន្ននោះទេ។ ទោះជាយ៉ាងណាក៏ដោយ អ្នកឆ្លើយតបបានផ្តល់នូវការយល់ឃើញផ្សេងគ្នាចំពោះសំណួរអំពីវិសាលភាពនៃប្រធានបទស្រាវជ្រាវទាំងនេះដែលបានចូលរួមដោះស្រាយនូវតម្រូវការនៃការអភិវឌ្ឍ សេដ្ឋកិច្ច សង្គម និងបរិស្ថាននាពេលបច្ចុប្បន្នរបស់កម្ពុជា។ អ្នកឆ្លើយតបចំនួន ១១នាក់ ក្នុងចំណោម ១៤នាក់បានឆ្លើយថា ប្រធានបទស្រាវជ្រាវទាំងនេះបានចូលរួមដោះស្រាយនូវតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន ក្នុងកម្រិត "ច្រើនណាស់" ពីរនាក់បាននិយាយថា "តិចតួច" និង មួយនាក់បានឆ្លើយថា "មិនអាចដោះស្រាយទេ"។ តាមរយៈការ

ឆ្លើយតបរបស់ពួកគេ ពេលអនាគតប្រទេសកម្ពុជានឹងជួបបញ្ហាប្រឈមផ្សេងៗ រួមមាន ការប្រែប្រួលអាកាសធាតុ និងការស្តារសេដ្ឋកិច្ចឡើងវិញពីជំងឺកូវីដ-១៩។ គួរឱ្យចាប់អារម្មណ៍ផងដែរ អ្នកពាក់ព័ន្ធទាំងអស់ហាក់យល់ស្រប ដូចគ្នាថា វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងក្លាយជាប្រធានបទស្រាវជ្រាវសំខាន់បំផុតក្នុងការដោះស្រាយ នូវតម្រូវការនាពេលអនាគតរបស់ប្រទេសកម្ពុជា (ទោះបីជាពួកគេមិនជឿថាវិស័យនេះជាប្រធានបទសំខាន់បំផុត នាពេលបច្ចុប្បន្នក៏ដោយ)។ ការណ៍នេះអាចជាករណីដែលការប្រែប្រួលអាកាសធាតុត្រូវបានគេព្យាករណ៍ថាជាកត្តា ជំរុញឱ្យមានការព្យាករណ៍អំពីធ្លាក់ចុះដំណាំ និងការអត់ឃ្លាន។

## ៣.៣. មូលនិធិស្រាវជ្រាវ

### *៣.៣.១. តើការស្រាវជ្រាវត្រូវបានផ្តល់មូលនិធិយ៉ាងដូចម្តេច?*

#### សាកលវិទ្យាល័យ / វិទ្យាស្ថានស្រាវជ្រាវ

តារាងទី គ.២ បង្ហាញពីចំនួនមូលនិធិដែលទទួលបានពីប្រភពមូលនិធិសាធារណៈ និងឯកជនក្នុងឆ្នាំ ២០២០ ដោយស្ថាប័ន (ក្នុងករណីនេះ ឯកតានៃការវិភាគគឺជាស្ថាប័ន មិនមែនអ្នកឆ្លើយតបទេ)។ ដូចនេះ តារាង នេះបង្ហាញពីកម្រិតផ្សេងគ្នានៃមូលនិធិដែលស្ថាប័នទទួលបានពីប្រភពផ្សេងៗ រួមមាន «មិនមានមូលនិធិ» «ប្រភព មូលនិធិបន្ទាប់បន្សំ» និង «ប្រភពមូលនិធិចម្បង»។ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល គឺជាសាកលវិទ្យាល័យ តែមួយបណ្តោះក្នុងចំណោមសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវផ្សេងទៀតដែលបញ្ជាក់ថាមូលនិធិស្រាវជ្រាវ ត្រូវបានសរសេរនៅក្នុងយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យជាផ្លូវការ។

ទាក់ទងនឹងការផ្តល់មូលនិធិស្រាវជ្រាវ សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានភាពលេចធ្លោក្នុងការទាក់ទាញ នូវការផ្តល់មូលនិធិស្រាវជ្រាវខ្ពស់បំផុត បន្ទាប់មកគឺវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ ស្ថាប័នចំនួនបី (សាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា) បាន លើកឡើងថាប្រភពមូលនិធិស្រាវជ្រាវចម្បងរបស់ពួកគេ គឺស្ថាប័នអន្តរជាតិ និងមូលនិធិអភិវឌ្ឍន៍។ ម្យ៉ាងទៀត ស្ថាប័នអាជីវកម្ម និងអង្គភាពពាណិជ្ជកម្ម ក៏ជាប្រភពមូលនិធិស្រាវជ្រាវបន្ទាប់បន្សំសម្រាប់ស្ថាប័នចំនួនបី (វិទ្យាស្ថានចក្ខុវិស័យអាស៊ី វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ កម្ពុជា)។ ទោះយ៉ាងណាក៏ដោយ ស្ថាប័នទាំងនេះមានភាពខុសប្លែកគ្នាខ្លះចំពោះប្រភពមូលនិធិរៀងគ្នា។ ការផ្តល់ មូលនិធិរបស់រដ្ឋាភិបាលត្រូវបានបញ្ជូនទៅតាមស្ថាប័នតាមវិធីផ្សេងៗគ្នា រួមមាន យន្តការផ្តល់ជំនួយ(សាកលវិទ្យា ល័យភូមិន្ទកសិកម្ម) យន្តការតាមរយៈកាប្រកួតប្រជែង (វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍ កម្ពុជា) ការរួមបញ្ចូលគ្នានៃយន្តការទាំងពីរ (វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា)។ ចំណែកស្ថាប័នបីផ្សេងទៀតបាន បញ្ជាក់ថាពួកគេប្រើប្រាស់យន្តការផ្សេងទៀត ដូចជា តាមរយៈផែនការថវិកាប្រចាំឆ្នាំ (វិទ្យាស្ថានជាតិ ពហុបច្ចេកទេសកម្ពុជា) តាមរយៈគម្រោង HEIP (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ) និងតាមរយៈការផ្តល់មូលនិធិ

សម្រាប់ការប្រមូលទិន្នន័យ ឬការបោះពុម្ពផ្សាយ (សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល)។ វិទ្យាស្ថានចក្ខុវិស័យអាស៊ី និងវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា មានបទពិសោធន៍ជាច្រើនក្នុងការប្រកួតប្រជែងសម្រាប់គម្រោងស្រាវជ្រាវ ខណៈស្ថាប័នផ្សេងទៀតមានបទពិសោធន៍មធ្យម។

នៅពេលសួរអំពីបញ្ហាប្រឈមដែលពួកគេជួបប្រទះក្នុងការកៀគរមូលនិធិសម្រាប់ការស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យ ឬវិទ្យាស្ថានស្រាវជ្រាវ ពួកគេ បានលើកឡើងថា៖

- កង្វះព័ត៌មានអំពីប្រភពមូលនិធិ
- ភាពមានកម្រិតនៃកញ្ចប់មូលនិធិ
- ការប្រកួតប្រជែងខ្លាំងពេក (ជាពិសេសពីវិទ្យាស្ថានស្រាវជ្រាវអន្តរជាតិ)
- កង្វះពេលវេលា - ប្រាក់បៀវត្សមានកម្រិតទាប ដូច្នេះអ្នកស្រាវជ្រាវភាគច្រើនតែងតែធ្វើការបង្រៀនបន្ថែម ជាហេតុធ្វើឱ្យពួកគេមិនមានពេលគ្រប់គ្រាន់ក្នុងការរៀបចំសំណើរសុំកញ្ចប់មូលនិធិស្រាវជ្រាវ។

អ្នកឆ្លើយតបក៏បានផ្តល់យោបល់អំពីតម្រូវការដែលរដ្ឋាភិបាលគួរអនុវត្តដើម្បីកែលម្អការផ្តល់មូលនិធិស្រាវជ្រាវរួមមាន៖

- បង្កើនបរិមាណកញ្ចប់មូលនិធិស្រាវជ្រាវធៀបនឹង ផ.ស.ស.
- បើកប្រភពមូលនិធិបន្ថែមទៀតសម្រាប់ការប្រកួតប្រជែង
- បង្កើតគណៈកម្មាធិការមូលនិធិស្រាវជ្រាវ
- រៀបចំសេចក្តីប្រកាសប្រចាំឆ្នាំនៃប្រធានបទស្រាវជ្រាវ និងមូលនិធិ
- បង្កើតគោលនយោបាយ របៀបវារៈ ផែនទីបង្ហាញផ្លូវ និងគោលការណ៍ណែនាំប្រកបដោយភាពច្បាស់លាស់សម្រាប់ការស្រាវជ្រាវ
- ធានានូវតម្លាភាពក្នុងការគ្រប់គ្រងជំនួយស្រាវជ្រាវ
- ធានាថាអ្នកស្រាវជ្រាវមានពេលច្រើនក្នុងការស្រាវជ្រាវ
- ជំរុញឱ្យវិស័យឯកជនផ្តល់មូលនិធិដល់ការស្រាវជ្រាវ។

### តារាង គ. ២៖ ចំនួនមូលនិធិដែលទទួលបានពីស្ថាប័នមូលនិធិសាធារណៈ និងឯកជនក្នុងឆ្នាំ ២០២០

| ស្ថាប័ន | ថវិកាសរុបពីប្រភពសាធារណៈ (ឧ. ក្រសួង) (លានរៀល) | ថវិកាសរុបពីប្រភពឯកជន (លានរៀល) | ជំនួយរបស់រដ្ឋាភិបាល | អង្គភាពអន្តរជាតិ / មូលនិធិអភិវឌ្ឍន៍ | មូលនិធិមិនរកប្រាក់ចំណេញ អង្គការសប្បុរសធម៌ ឬអង្គការមិនមែនរដ្ឋាភិបាល | អាជីវកម្ម និងអង្គភាពពាណិជ្ជកម្ម |
|---|---|---|---|---|---|---|
| សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ៣៦០ | ០ | បន្ទាប់បន្សំ | ចម្បង | គ្មាន | គ្មាន |
| វិទ្យាស្ថានចក្ខុវិស័យអាស៊ី | ០ | ២០ | គ្មាន | បន្ទាប់បន្សំ | បន្ទាប់បន្សំ | បន្ទាប់បន្សំ |
| វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | ៨០ | ២០ | ចម្បង | គ្មាន | គ្មាន | បន្ទាប់បន្សំ |
| សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ៤០០០ | ៤០០០ | បន្ទាប់បន្សំ | បន្ទាប់បន្សំ | បន្ទាប់បន្សំ | គ្មាន |
| សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | ០ | ០ | បន្ទាប់បន្សំ | បន្ទាប់បន្សំ | ចម្បង | គ្មាន |
| វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ៤៩៥០ | ៨០ | ចម្បង | ចម្បង | បន្ទាប់បន្សំ | គ្មាន |
| វិទ្យាស្ថានបណ្ដុះបណ្ដាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា | ៦០០ | ៤៨០០ | បន្ទាប់បន្សំ | ចម្បង | បន្ទាប់បន្សំ | បន្ទាប់បន្សំ |

**វិស័យឯកជន**

**តារាងទី គ.៣** ខាងក្រោមបង្ហាញពីចំនួនមូលនិធិដែលទទួលបានពីធនធានឯកជន និងសាធារណៈ និង ប្រភពមូនិធិដែលទទួលបានពីប្រភពផ្សេងៗទៀត (មិនមានមូនិធិ មានប្រភពមូនិធិតិចតួច និង មានប្រភពមូនិធិច្រើន តាមក្រសួង-ស្ថាប័ន ក្នុងឆ្នាំ ២០២០)។

**តារាង គ. ៣៖** មូនិធិទទួលបានពីប្រភពសាធារណៈ និងឯកជន និងប្រភពមូនិធិពាក់ព័ន្ធដែលទទួលបានពីស្ថាប័នរបស់វិស័យឯកជន ក្នុងឆ្នាំ២០២០

| ស្ថាប័ន | ចំនួនមូនិធិសរុប មាន ប្រភពពីសាធារណៈ (ឧ. ក្រសួង) (លានរៀល) | ចំនួនមូនិធិសរុប ដែលទទួលបានពីថវិកាផ្ទាល់ខ្លួន (លានរៀល) | ជំនួយរបស់រដ្ឋាភិបាល | មូនិធិស្ថាប័នអន្តរជាតិ/អភិវឌ្ឍន៍ | ស្ថានប័នមិនយកប្រាក់ចំណូល សប្បុរសធម៌ ឬ អង្គការក្រៅរដ្ឋាភិបាល |
|---|---|---|---|---|---|
| សហគ្រាសធនតូច និងមធ្យម | 0 | 0 | គ្មាន | គ្មាន | គ្មាន |
| ក្រុមហ៊ុនអេមរ៉ាយស៍(ខេមបូឌា) | 0 | ៥0 | គ្មាន | តិចតួច | គ្មាន |
| សភាពាណិជ្ជកម្មកម្ពុជា | 0 | 0 | ច្រើន | តិចតួច | តិចតួច |
| ក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប | 0 | ២00 | គ្មាន | គ្មាន | តិចតួច |

គ្មានស្ថានប័នណាមួយបានរាយការណ៍ថាពួកគេបានទទួលថវិកាពីប្រភពសាធារណៈ (ឧ. ក្រសួង) ផ្ទុយទៅវិញ សភាពាណិជ្ជកម្មកម្ពុជា បានរាយការណ៍ថាបានទទួលអត្ថប្រយោជន៍ពីការលើទឹកចិត្តពីសាធារណៈ តាមរយៈយន្តការមូនិធិជាកញ្ចប់(Block grant)។

ទាក់ទងនឹងផលលំបាកចម្បងៗក្នុងការកៀគរមូនិធិស្រាវជ្រាវ អ្នកចូលរួមឆ្លើយតបភាគច្រើនបានលើកឡើងអំពីដំណើរការដែលទាក់ទងនឹងការទទួលបានមូលនិធិ និងបានផ្តល់អនុសាសន៍ថាគួរតែមានគោលការណ៍ច្បាស់លាស់មួយ ព្រមទាំងការផ្តល់លទ្ធភាពក្នុងដាក់ពាក្យស្នើសុំតាមប្រព័ន្ធអនឡាញ។ ការអនុគ្រោះទាំងនេះនឹងធ្វើ

ឱ្យដំណើរការក្នុងការកៀរគមូលនិធិមានភាពងាយស្រួលសម្រាប់ពួកគេ។ ក្រុមហ៊ុនអេមរ៉ាយស៍(ខេមបូឌា) និង ក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប បានរាយការណ៍ថា ពួកគេមានបទពិសោធន៍ជាមួយនឹងការអញ្ជើញឱ្យចូលរួមក្នុងការប្រកួតប្រជែង ប៉ុន្តែសហគ្រាសធនតូចនិងមធ្យម និងសភាពាណិជ្ជកម្មកម្ពុជាបានរាយការណ៍ថាមិនមានបទពិសោធន៍ក្នុងការអញ្ជើញឱ្យចូលរួមក្នុងការប្រកួតប្រជែងដើម្បីទទួលបានមូលនិធិស្រាវជ្រាវណាមួយនោះទេ។ គួរឱ្យកត់សម្គាល់ផងដែរថា ស្ថាប័នឯកជនទាំងនេះមិនមានយុទ្ធសាស្ត្រមូលនិធិស្រាវជ្រាវដែលបានសរសេរជាលាយលក្ខណ៍អក្សរផ្លូវការនោះទេ។

### ក្រសួងពាក់ព័ន្ធ

អ្នកចូលរួមឆ្លើយតបមកពីក្រសួងនីមួយៗបានបង្ហាញពីលក្ខខណ្ឌវិនិច្ឆ័យរបស់ពួកគេដើម្បីសម្រេចថាតើគម្រោងស្រាវជ្រាវណាខ្លះគួរទទួលបានមូលនិធិ។ រូបភាពទី គ.៣ បង្ហាញលទ្ធផល៖

**រូបភាព គ. ៣៖** លក្ខខណ្ឌវិនិច្ឆ័យរបស់ក្រសួងដែលត្រូវបានប្រើប្រាស់ដើម្បីសម្រេចថាគម្រោងមួយណាគួរទទួលបានមូលនិធិ



អ្នកឆ្លើយតបបានផ្តល់អាទិភាពខ្ពស់បំផុតចំពោះលក្ខខណ្ឌវិនិច្ឆ័យគុណវុឌ្ឍិនៃក្រុមស្រាវជ្រាវ បន្ទាប់មក គឺសក្តានុពលនៃការស្រាវជ្រាវដែលមានផលជះលើសេដ្ឋកិច្ច សក្តានុពលក្នុងការផ្សព្វផ្សាយពីគោលនយោបាយ និងគុណតម្លៃនៃថវិកា។

អ្នកឆ្លើយតបបានផ្តល់មតិយោបល់ផ្សេងៗជាច្រើនទាក់ទងនឹងមធ្យោបាយដែលរបៀបវារៈស្រាវជ្រាវជាតិអាចជួយលើកកម្ពស់មូលនិធិស្រាវជ្រាវ។ ពួកគេគិតថា របៀបវារៈស្រាវជ្រាវជាតិគួរតែផ្តល់អាទិភាពដល់ប្រធានបទស្រាវជ្រាវណាដែលគាំទ្រខ្លាំងដល់ការរីកចម្រើនសេដ្ឋកិច្ចរបស់កម្ពុជា។ ប្រធានបទទាំងនេះ នឹងជួយរដ្ឋាភិបាលនិងអ្នកផ្តល់មូលនិធិផ្សេងៗក្នុងការធ្វើវិភាជន៍មូលនិធិស្រាវជ្រាវប្រកបដោយប្រសិទ្ធភាព។ អ្នកឆ្លើយតបមួយចំនួន ចង់ឱ្យរបៀបវារៈស្រាវជ្រាវជាតិ បង្កើតស្ថាប័នក្រុមប្រឹក្សាភិបាលត្រួតពិនិត្យមួយ ដើម្បីធានាថាការស្រាវជ្រាវទាំងអស់ត្រូវបានធ្វើឡើង អនុលោមទៅតាមក្រមសីលធម៌។ អនុសាសន៍ផ្សេងទៀត រួមមានដូចខាងក្រោម៖

- ការផ្តល់មូលនិធិគួរផ្តោតលើការលើកទឹកចិត្តសម្រាប់អ្នកស្រាវជ្រាវ
- កែលម្អនីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុ នៅក្នុងសកម្មភាពរដ្ឋបាលសម្រាប់ការស្រាវជ្រាវ
- ផ្តល់មូលនិធិសម្រាប់ការកសាងសមត្ថភាព និងការសហការអន្តរជាតិ
- គួរបង្កើតយន្តការនៃការផ្តល់មូលនិធិនៅក្នុងរបៀបវារៈស្រាវជ្រាវជាតិ
- ធ្វើការគ្រប់គ្រងការផ្តល់មូលនិធិជាកញ្ចប់(block grant) ដោយផ្ទាល់ចំពោះក្រុមស្រាវជ្រាវតាមរយៈយន្តការត្រួតពិនិត្យ និងវាយតម្លៃដែលរឹងមាំ
- ពង្រឹងក្រុមគាំទ្រលើផ្នែកការស្រាវជ្រាវ។

## ៣.៤. ការបំពេញភារកិច្ច និងគុណភាពនៃការស្រាវជ្រាវ

### *៣.៤.១. តើអ្វីជាលទ្ធផលនៃការស្រាវជ្រាវរបស់សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា?*

#### សាកលវិទ្យាល័យ/វិទ្យាស្ថានស្រាវជ្រាវ

រូបភាពទី គ.៤ បង្ហាញពីចំនួនអត្ថបទស្រាវជ្រាវដែលមានឈ្មោះអ្នកនិពន្ធជាបុគ្គលិក/និស្សិតនៅតាមគ្រឹះស្ថាននីមួយៗ ដែលបានបោះពុម្ពផ្សាយនៅក្នុងកាលិកបត្រអន្តរជាតិត្រួតពិនិត្យដោយសហវិនិច្ឆ័យករក្នុងឆ្នាំ ២០២០។

រូបភាព គ. ៤៖ អត្ថបទស្រាវជ្រាវដែលមានឈ្មោះអ្នកនិពន្ធជាបុគ្គលិក/និស្សិតនៅតាមគ្រឹះស្ថាននីមួយៗ ដែលបានបោះពុម្ពផ្សាយនៅក្នុងកាលិកបត្រអន្តរជាតិត្រួតពិនិត្យដោយសហវិនិច្ឆ័យករក្នុងឆ្នាំ២០២០




### *៣.៤.២. តើអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវត្រូវបានវាយតម្លៃ និងកែលម្អយ៉ាងដូចម្តេច?*

#### សាកលវិទ្យាល័យ/ស្ថាប័នស្រាវជ្រាវ

តារាងទី គ.៤ ខាងក្រោមបង្ហាញពីលក្ខខណ្ឌវិនិច្ឆ័យសម្រាប់វាយតម្លៃការបំពេញការតព្វកិច្ច ដែលមានសារៈសំខាន់បំផុតសម្រាប់អ្នកឆ្លើយតបរបស់សាកលវិទ្យាល័យ/វិទ្យាស្ថានស្រាវជ្រាវ បន្ថែមលើការវាយតម្លៃផ្ទាល់របស់ពួកគេពីកម្រិតនៃប្រសិទ្ធភាព និងភាពត្រឹមត្រូវនៃវិធីសាស្ត្រវាយតម្លៃ។

**តារាង គ. ៤៖** លក្ខខណ្ឌវិនិច្ឆ័យសំខាន់ៗសម្រាប់វាយតម្លៃការបំពេញកាតព្វកិច្ចរបស់អ្នកស្រាវជ្រាវដោយស្ថាប័ន និងការវាយតម្លៃពីប្រសិទ្ធភាព និងភាពត្រឹមត្រូវរបស់ស្ថាប័ន

| ស្ថាប័ន | លក្ខខណ្ឌវិនិច្ឆ័យដែលសំខាន់បំផុតសម្រាប់វាយតម្លៃការបំពេញកាតព្វកិច្ច | តើវិធីសាស្ត្រវាយតម្លៃមានប្រសិទ្ធភាពឬទេ? | តើវិធីសាស្ត្រវាយតម្លៃមានភាពត្រឹមត្រូវដែរឬទេ? |
|---|---|---|---|
| សាកលវិទ្យាល័យភូមិន្ទកសិកម្ម | កម្រិតនវានុវត្តន៍ | តិចតួច | តិចតួច |
| វិទ្យាស្ថានចក្ខុវិស័យអាស៊ី | ពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗរបស់ជាតិ | តិចតួច | តិចតួច |
| វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | ពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗរបស់ជាតិ | គ្មាន | គ្មាន |
| សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ចំនួននៃការសហការជាមួយវិស័យឧស្សាហកម្ម | គ្មាន | គ្មាន |
| សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | ចំនួនអត្ថបទស្រាវជ្រាវដែលបានបោះពុម្ពផ្សាយ | តិចតួច | ច្រើន |
| វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ចំនួននិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ដែលបានទាក់ទាញ | តិចតួច | តិចតួច |
| វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា | ពាក់ព័ន្ធនឹងបញ្ហាសំខាន់ៗរបស់ជាតិ | តិចតួច | តិចតួច |

ជាទូទៅ វិធីសាស្ត្រវាយតម្លៃមិនត្រូវបានគេយល់ថាមានប្រសិទ្ធភាពខ្លាំង ឬមានភាពត្រឹមត្រូវនោះទេ។ អ្នកឆ្លើយតបបានស្នើឱ្យមានភាពច្បាស់លាស់បន្ថែមទៀតនៅក្នុងគោលការណ៍ណែនាំ សូចនាករសមិទ្ធគន្លឹះ និងកែលម្អលក្ខខណ្ឌវិនិច្ឆ័យដើម្បីលើកកម្ពស់វិធីសាស្ត្រទាំងនេះ។ ពួកគេក៏បានផ្តល់អនុសាសន៍សម្រាប់ការធ្វើសិក្ខាសាលាដើម្បីទទួលបានមតិកែលម្អផងដែរ ដើម្បីជំរុញការកសាងសមត្ថភាព និងកែលម្អវិធីសាស្ត្រវាយតម្លៃ។

អ្នកឆ្លើយតចំនួន ២នាក់ក្នុងចំណោម ៧នាក់ បានយល់ស្របយ៉ាងខ្លាំងថា វឌ្ឍនភាពអាជីពនាពេលបច្ចុប្បន្នអាស្រ័យលើការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ អ្នកឆ្លើយតបផ្សេងទៀតបាននិយាយថា វឌ្ឍនភាពអាជីពអាស្រ័យមានភាពទាក់ទងតិចតួចជាមួយនឹងការបោះពុម្ពផ្សាយ។ អ្នកឆ្លើយចំនួន ៣នាក់ក្នុងចំណោម ៧នាក់បានយល់ស្របយ៉ាងខ្លាំងវឌ្ឍនភាពអាជីពអាស្រ័យលើការសហការគម្រោងអន្តរជាតិ។ អ្នកឆ្លើយតបក៏បានលើកឡើងអំពីកត្តាដែលជះឥទ្ធិពលដល់វឌ្ឍនភាពអាជីព ដែលរួមមាននវានុវត្តន៍ ការរួមចំណែកដល់គោលនយោបាយ និងការស្រាវជ្រាវ តម្រូវការរបស់និស្សិត និងសកម្មភាពផ្សព្វផ្សាយ។

អ្នកឆ្លើយតបជាច្រើនបានរាយការណ៍អំពីបញ្ហាក្នុងការទាក់ទាញ និងបណ្តុះបណ្តាលអ្នកស្រាវជ្រាវវ័យក្មេង។ មូលហេតុមួយដែលបណ្តាលឱ្យមានបញ្ហានេះគឺជាទូទៅបណ្តាលមកពីប្រាក់បៀវត្សរ៍តិចតួច។ អ្នកឆ្លើយតបបានណែនាំឱ្យដំឡើងប្រាក់បៀវត្សរ៍ប្រចាំខែដើម្បីទាក់ទាញអ្នកស្រាវជ្រាវវ័យក្មេងបន្ថែមទៀត។ ទទឹមនឹងនេះក៏មានទម្រង់នៃការគាំទ្រផ្សេងទៀតផងដែរដើម្បីទាក់ទាញពួកគេ ដូចជាលទ្ធភាពក្នុងការចូលទៅប្រើទិន្នន័យ ឱកាសទទួលបានមូលនិធិ ការកំណត់ផ្លូវអាជីពច្បាស់លាស់ (ការកំណត់កម្រិតតួនាទីច្បាស់លាស់) និងបុគ្គលិកជំនួយបច្ចេកទេសផ្នែកស្រាវជ្រាវផ្សេងៗ។

អ្នកឆ្លើយតបពាក់កណ្តាលគិតថា មានបញ្ហាមួយចំនួនចំពោះអ្នកស្រាវជ្រាវជាស្ត្រីក្នុងការឈានទៅមុខក្នុងអាជីពរបស់ពួកគេ ដោយសារការកើតឡើងនៃសម្ពាធក្នុងការថែទាំកុមារ ឬកូនៗរបស់ពួកគេ និងការប្រកាន់ភ្ជាប់នូវវប្បធម៌បុរេវិច្ឆ័យ។ ដើម្បីដោះស្រាយបញ្ហានេះ អ្នកឆ្លើយតបបានផ្តល់មតិថា របៀបវារៈស្រាវជ្រាវជាតិ គួរតែស្នើឱ្យមានចំនួនកូតាសម្រាប់បុគ្គលិកស្រាវជ្រាវជាស្ត្រី ចំនួនអាហារូបករណ៍ ឬជំនួយសម្រាប់ស្ត្រី និងការជំរុញការផ្តល់ជំនួយថែទាំកុមារឱ្យកាន់តែប្រសើរឡើង។

អ្នកឆ្លើយតបច្រើនជាងពាក់កណ្តាលបាននិយាយថា ស្ថាប័នរបស់ពួកគេ មានប្រព័ន្ធនៃការលើកទឹកចិត្តនៅក្នុងស្ថាប័នដើម្បីជំរុញការបំពេញកាតព្វកិច្ចបានល្អ។ ការបំពេញកាតព្វកិច្ចបានល្អនេះត្រូវបានកំណត់ដោយការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ សំណើគម្រោងស្រាវជ្រាវ និងសូចនាករផ្សេងៗ។ ការលើកទឹកចិត្តភាគច្រើនមានទម្រង់ជាការទទួលស្គាល់ផ្នែកវិជ្ជាជីវៈ រង្វាន់ហិរញ្ញវត្ថុ និងការដំណើងតំណែង ជាដើម។

អ្នកឆ្លើយសំណួរចំនួន ៣នាក់ក្នុងចំណោម ៧នាក់បានដឹងពីក្រមសីលធម៌ជាតិ (សម្រាប់ការស្រាវជ្រាវផ្នែកសុខាភិបាលរបស់ក្រសួងសុខាភិបាល) ហើយបានរាយការណ៍ថាក្រមសីលធម៌ជាតិមានអត្ថប្រយោជន៍សម្រាប់ពួកគេ។ មានតែអ្នកឆ្លើយតបម្នាក់ប៉ុណ្ណោះដែលដឹងពីក្រមសីលធម៌ស្ថាប័ន (វិទ្យាស្ថានចក្ខុវិស័យអាស៊ី)។ ឆ្លើយតបចំពោះបញ្ហាចម្បងដែលអ្នកឆ្លើយតបជួបប្រទះក្នុងការធ្វើការស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រនៅក្នុងប្រទេសកម្ពុជាពួកគេបានលើកឡើងពីចំនុចខ្វះខាត ដូចជា៖

- មូលនិធិស្រាវជ្រាវ
- សមត្ថភាព

- ហេដ្ឋារចនាសម្ព័ន្ធ
- គោលការណ៍ណែនាំច្បាស់លាស់ (ជាទម្រង់គោលនយោបាយ ផែនទីបង្ហាញផ្លូវ និងរបៀបវារៈ)
- បទប្បញ្ញត្តិគាំទ្រ
- លទ្ធភាពចូលទៅប្រើទិន្នន័យ

### *៣.៤.៣. តើអ្នកស្រាវជ្រាវក្នុងវិស័យឯកជនត្រូវបានវាយតម្លៃដោយរបៀបណា ហើយតើការវាយតម្លៃនេះអាចធ្វើឱ្យប្រសើរឡើងយ៉ាងដូចម្តេច?*

#### វិស័យឯកជន

អ្នកឆ្លើយតបចំនួនពីរនាក់បានឆ្លើយថា ពួកគេមានបញ្ហាចម្បងក្នុងការទាក់ទាញ និងបណ្តុះបណ្តាលអ្នកស្រាវជ្រាវវ័យក្មេង ខណៈអ្នកឆ្លើយតបចំនួនពីរនាក់ផ្សេងទៀតបាននិយាយថា បញ្ហាក្នុងការទាក់ទាញ និងបណ្តុះបណ្តាលអ្នកស្រាវជ្រាវវ័យក្មេង មានកម្រិតមធ្យមប៉ុណ្ណោះសម្រាប់ស្ថាប័នរបស់ពួកគេ។ អ្នកឆ្លើយតបម្នាក់ (ក្រុមហ៊ុនអេមរុាយស៍ ខេមូឌា) គិតថា បញ្ហានេះបណ្តាលមកពីកង្វះជំនួយ និងថវិកាសម្រាប់អ្នកស្រាវជ្រាវវ័យក្មេង។ ក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប គិតថា របៀបវារៈស្រាវជ្រាវជាតិគួរតែផ្តល់អាទិភាពខ្ពស់ក្នុងការទាក់ទាញអ្នកស្រាវជ្រាវវ័យក្មេង និងការជំរុញឱ្យមានការធ្វើវិភាជជំនួយបន្ថែមទៀតសម្រាប់គោលដៅនេះ។ អ្នកឆ្លើយតបនៃស្ថាប័នឯកជនទាំងអស់មិនមានអារម្មណ៍ថា ស្ត្រីប្រឈមមុខនឹងបញ្ហាក្នុងការពង្រឹងអាជីពស្រាវជ្រាវរបស់ពួកគេនោះទេ។

អ្នកឆ្លើយតបនៃស្ថាប័នឯកជនទាំងអស់មិនបានដឹងអំពីក្រមសីលធម៌ជាតិ ឬក្របសីលធម៌ស្ថាប័ននោះទេ។ ដើម្បីឆ្លើយតបនឹងការលំបាកដែលអ្នកស្រាវជ្រាវបានជួបប្រទះក្នុងការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រប្រកបដោយភាពប្រាកដប្រជាមួយក្នុងប្រទេសកម្ពុជា ក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប បានឆ្លើយតបថា បញ្ហាចម្បងបណ្តាលមកពីកង្វះលទ្ធភាពចូលទៅប្រើប្រាស់លទ្ធផលការស្រាវជ្រាវ និងសុក្រិតភាពនិងភាពគ្រប់គ្រាន់ក្នុងការទំនាក់ទំនងផ្នែកស្រាវជ្រាវ។

### *៣.៤.៤. តើក្រសួងវាយតម្លៃអ្នកស្រាវជ្រាវដោយរបៀបណា ហើយតើការវាយតម្លៃនេះអាចធ្វើឱ្យប្រសើរឡើងយ៉ាងដូចម្តេច?*

#### ក្រសួងពាក់ព័ន្ធ

អ្នកឆ្លើយតប ប្រាំមួយនាក់ក្នុងចំណោម ១៣នាក់ បានវិនិច្ឆ័យថា ភាពពាក់ព័ន្ធនៃការស្រាវជ្រាវទៅនឹងបញ្ហានៃផលប្រយោជន៍ជាតិគឺជាកត្តាសំខាន់បំផុតក្នុងការពិចារណាលើសមិទ្ធផលនៃការស្រាវជ្រាវ ខណៈអ្នកឆ្លើយតបចំនួន ៤នាក់គិតថា កម្រិតនៃនវានុវត្តន៍គឺជាកត្តាសំខាន់បំផុតក្នុងការពិចារណាលើសមិទ្ធផលនៃការស្រាវជ្រាវ។ ម្យ៉ាងវិញទៀត អ្នកឆ្លើយតបចំនួន ៣នាក់ បានគិតថាចំនួននៃកិច្ចសហការជាមួយឧស្សាហកម្មគឺជាកត្តាសំខាន់បំផុតក្នុងការពិចារណាលើសមិទ្ធផលនៃការស្រាវជ្រាវ។

ក្រៅពីអ្នកឆ្លើយតបមកពីក្រសួងអប់រំ យុវជន និងកីឡា អ្នកឆ្លើយតបទាំងអស់មិនបានដឹងអំពីក្រមសីលធម៌ស្រាវជ្រាវជាតិដែលបានផ្តោតទៅលើក្រមសីលធម៌សម្រាប់ការស្រាវជ្រាវសុខភាព (នីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់គណៈកម្មាធិការសីលធម៌ជាតិសម្រាប់ការស្រាវជ្រាវសុខាភិបាលនៅកម្ពុជា) នោះទេ។ ទោះជាយ៉ាងណាក៏ដោយ អ្នកឆ្លើយតបទាំងនេះមានអារម្មណ៍ថា ក្រមសីលធម៌សម្រាប់ការស្រាវជ្រាវសុខាភិបាលគួរតែត្រូវធ្វើបច្ចុប្បន្នភាព ដោយសារក្រមសីលធម៌នេះត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០០៨ ។

អ្នកឆ្លើយតបបានបញ្ជាក់ថា បញ្ហាសំខាន់ៗក្នុងការអនុវត្តលម្អិតនូវវិធីសាស្ត្រប្រកបដោយលក្ខណៈវិទ្យាសាស្ត្រនៅកម្ពុជាមានភាពខ្វះខាត ដូចជា៖

- និរន្តរភាពនៃមូលនិធិស្រាវជ្រាវ
- ការធ្វើផែនការ និងការគ្រប់គ្រងហិរញ្ញវត្ថុ (រួមទាំងការលំបាកក្នុងការទទួលបានហិរញ្ញប្បទាន ព្រមទាំងការប្រើប្រាស់មូលនិធិឬហិរញ្ញប្បទានដែលទទួលបាននោះឱ្យមានប្រសិទ្ធភាពផងដែរ)
- ធនធានមនុស្ស (សាស្ត្រាចារ្យដែលមានសមត្ថភាព និងមានការប្តេជ្ញាចិត្តក្នុងការបណ្តុះបណ្តាលអ្នកជំនាន់ក្រោយ និងការលើកទឹកចិត្តនៅមានកម្រិតទាបទាក់ទងនឹងឋានៈ តួនាទីក្នុងនាមជាអ្នកស្រាវជ្រាវ)
- សមត្ថភាពអ្នកស្រាវជ្រាវ (ជារឿយៗត្រូវបង្ខំចិត្តធ្វើការងារបន្ថែម ដោយសារប្រាក់ខែទាប)
- ការលើកទឹកចិត្តសម្រាប់អ្នកស្រាវជ្រាវ
- កិច្ចសហការជាតិ និងអន្តរជាតិ
- ក្រមសីលធម៌ស្រាវជ្រាវ
- ឧបករណ៍
- ការប្តេជ្ញាចិត្តផ្នែកគោលនយោបាយ

នៅពេលត្រូវបានសួរថាតើ របៀបវារៈស្រាវជ្រាវជាតិគួររួមបញ្ចូលអ្វីខ្លះដើម្បីបង្កើនគុណភាពនៃការស្រាវជ្រាវដែលធ្វើឡើងនៅក្នុងប្រទេសកម្ពុជា អ្នកឆ្លើយតបបានលើកឡើងថា៖

- យន្តការដើម្បីបង្កើតការលើកទឹកចិត្ត ដូចជា ប្រាក់ចំណូលបន្ថែមសម្រាប់អ្នកស្រាវជ្រាវ
- ការវិនិយោគបន្ថែមលើធនធានមនុស្ស (និងការគ្រប់គ្រងថវិកាប្រកបដោយប្រសិទ្ធភាព)
- ការអនុវត្តគោលការណ៍ណែនាំក្រមសីលធម៌ស្រាវជ្រាវ
- យន្តការបង្កើនតម្លៃនៃការយល់ឃើញទៅលើការស្រាវជ្រាវ និងអ្នកស្រាវជ្រាវ
- យន្តការបង្កើនកិច្ចសហការជាតិ និងអន្តរជាតិ
- ឧបករណ៍តាមដាន និងវាយតម្លៃការស្រាវជ្រាវ
- គំនិតផ្តួចផ្តើមបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវឯកទេសក្នុងសាកលវិទ្យាល័យ
- ការកំណត់ទិសដៅលើប្រធានបទស្រាវជ្រាវអាទិភាព
- សកម្មភាពលើកកម្ពស់ការយល់ដឹងអំពីរបៀបវារៈស្រាវជ្រាវជាតិ។

## ៣.៥. ចល័តភាពអ្នកស្រាវជ្រាវ និងកិច្ចសហការអន្តរជាតិ

### *៣.៥.១. តើចល័តភាពអ្នកស្រាវជ្រាវ និងកិច្ចសហការអន្តរជាតិនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្នស្ថិតក្នុងកម្រិតណា?*

***សាកលវិទ្យាល័យ ស្ថាប័នស្រាវជ្រាវ និងក្រសួង***

ក្រសួងជាច្រើនមិនបានដឹងពីគម្រោងណាមួយដែលគាំទ្រដល់ចល័តភាពអ្នកស្រាវជ្រាវអន្តរជាតិសម្រាប់ការឈប់សម្រាកដើម្បីទៅធ្វើការស្រាវជ្រាវរយៈពេលខ្លី ឬមធ្យមនោះទេ។ វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជាបានរាយការណ៍ពីការផ្តល់ ៥០ ភាគរយនៃប្រាក់បៀវត្សរ៍មូលដ្ឋានដល់អ្នកស្រាវជ្រាវនៅពេលឈប់សម្រាក។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ  បាននិយាយថា បទប្បញ្ញត្តិរបស់រដ្ឋាភិបាលរាំងការផ្តល់នេះចំពោះគ្រូបង្រៀន។ វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាបាននិយាយថា មានការផ្តល់ជូនសម្រាប់ការផ្លាស់ប្តូរបទពិសោធន៍ផ្នែកស្រាវជ្រាវអន្តរជាតិ។

ពាក់កណ្តាលនៃអ្នកឆ្លើយតបមកពីបណ្តាក្រសួងបាននិយាយថា ការទាក់ទាញអ្នកស្រាវជ្រាវឱ្យត្រឡប់មកកម្ពុជាវិញនៅពេលដែលពួកគេបានទៅស្រាវជ្រាវ ឬសិក្សានៅបរទេស អាចមានភាពលំបាកខ្លាំង។ អ្នកឆ្លើយតបមកពីសាកលវិទ្យាល័យ ឬស្ថាប័នស្រាវជ្រាវភាគច្រើនក៏បានគាំទ្រចំពោះការលើកឡើងរបស់អ្នកឆ្លើយតបពីបណ្តាក្រសួងផងដែរ។ អ្នកឆ្លើយតបមកពីបណ្តាក្រសួង និងសាកលវិទ្យាល័យ ឬស្ថាប័នស្រាវជ្រាវយល់ឃើញថា កត្តានេះបណ្តាលមកពី   កង្វះថវិកា ទស្សនៈនៃការយល់ឃើញ សន្តិសុខការងារ និងការលើកទឹកចិត្តផ្សេងទៀតសម្រាប់អ្នកស្រាវជ្រាវនៅកម្ពុជា។ បន្ថែមលើនេះ ពួកគេក៏បានលើកឡើងពីកង្វះការគាំទ្រផ្នែកគោលនយោបាយ និងប្រព័ន្ធនវានុវត្តន៍ជាតិដែលមិនទាន់មានការអភិវឌ្ឍ។

អ្នកឆ្លើយតបក៏បានផ្តល់អនុសាសន៍ដល់របៀបវារៈស្រាវជ្រាវជាតិ ក្នុងការបង្កើនកិច្ចសហការស្រាវជ្រាវអន្តរជាតិ ដូចខាងក្រោម៖

- ផ្សព្វផ្សាយបណ្តាញសាកលវិទ្យាល័យជាមួយនឹងកិច្ចសហការស្រាវជ្រាវដែលរឹងមាំ
- បង្កើតបរិយាកាសអំណោយផលមួយដើម្បីជួយគាំទ្រអ្នកស្រាវជ្រាវបរទេស រួមមាន ការផ្តល់នូវលំនៅដ្ឋានគ្រប់គ្រាន់ បរិស្ថានការការពារ ការអប់រំដែលមានគុណភាពខ្ពស់សម្រាប់កូនៗរបស់ពួកគេ សម្ភារៈបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដើម្បីជួយទ្រទ្រង់ការរស់នៅរបស់អ្នកស្រាវជ្រាវ។
- ផ្តល់ការលើកទឹកចិត្តជារូបិយវត្ថុដល់អ្នកស្រាវជ្រាវ
- សម្របសម្រួលបទប្បញ្ញត្តិក្នុងការផ្តល់អាជ្ញាបណ្ណការងារ
- ពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិ
- គាំទ្រការណែនាំផ្នែកស្រាវជ្រាវ
- បង្កើនគ្រោងការណ៍ចលភាពអ្នកស្រាវជ្រាវ និងការផ្លាស់ប្តូរពាក់កណ្តាលអាជីព។

សរុបជារួម ការគាំទ្រចំពោះកិច្ចសហការស្រាវជ្រាវអន្តរជាតិមិនទាន់គ្រប់គ្រាន់នៅឡើយទេ ព្រមទាំងមានកង្វះខាតភាពច្បាស់លាស់ចំពោះការផ្តល់មុខងារតួនាទីជាអ្នកស្រាវជ្រាវ។

## ៣.៦. កិច្ចសហការរវាងគ្រឹះស្ថានសិក្សាស្រាវជ្រាវ និងវិស័យឧស្សាហកម្ម

### *៣.៦.១. ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន តើស្ថាប័នស្រាវជ្រាវ និងវិស័យឯកជនមានកិច្ចសហការគ្នាក្នុងកម្រិតណា?*

**សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ**

តារាងទី គ.៥ បង្ហាញពីកម្រិតកិច្ចសហការរវាងសាកលវិទ្យាល័យនិងវិទ្យាស្ថានស្រាវជ្រាវជាមួយវិស័យឯកជន និងការិយាល័យសហប្រតិបត្តិការដាក់លាក់ដើម្បីបង្កើតកិច្ចសន្យាស្រាវជ្រាវជាមួយវិស័យឯកជន ឬដើម្បីដាក់ចូលទីផ្សារនូវលទ្ធផលស្រាវជ្រាវ។

**តារាង គ. ៥៖** កិច្ចសហការជាមួយវិស័យឯកជន ដោយគ្រឹះស្ថានសិក្សា

| ស្ថាប័ន | កម្រិតកិច្ចសហការជាមួយវិស័យឯកជន | ការិយាល័យសហការដាក់លាក់ | ព័ត៌មានលម្អិត |
|---|---|---|---|
| សាកលវិទ្យាល័យភូមិន្ទកសិកម្ម | មានមួយចំនួន | មាន | ការិយាល័យផ្ទេរបច្ចេកវិទ្យា និងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចផ្នែកកសិកម្ម និងអាហារ |
| វិទ្យាស្ថានចក្ខុវិស័យអាស៊ី | មានមួយចំនួន | មាន | អង្គភាពតូចមួយដើម្បីស្វែងរកកិច្ចសហការ និងការកសាងភាពជាដៃគូក្នុងការស្រាវជ្រាវ |
| វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | មានមួយចំនួន | មាន | ការិយាល័យទំនាក់ទំនងអន្តរជាតិ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ការស្រាវជ្រាវ និងបច្ចេកវិទ្យា |
| សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | មានមួយចំនួន | មាន | ការិយាល័យភ្ជាប់ទំនាក់ទំនងជាមួយវិស័យឧស្សាហកម្ម និងការិយាល័យស្រាវជ្រាវ |

| | | | |
|---|---|---|---|
| សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | គ្មាន | គ្មាន | |
| វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | គ្មាន | មាន | ការិយាល័យភ្ជាប់ទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងវិស័យឧស្សាហកម្ម |
| វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា | មានមួយចំនួន | គ្មាន | - |

ប្រភព៖ ការស្ទង់មតិ

បរិក្ខារគាំទ្រហាក់មានក្នុងស្ថាប័នភាគច្រើនដើម្បីអនុញ្ញាតឱ្យមានការសហការជាមួយវិស័យឧស្សាហកម្មកាន់តែច្រើន ប៉ុន្តែចំនួនកិច្ចសហការតិចតួចណាស់ត្រូវបានរាយការណ៍។

ឆ្លើយតបទៅនឹងសំណួរទាក់ទងនឹងវិធីសាស្ត្រដែលស្ថាប័នរបស់ពួកគេបានប្រើប្រាស់ដើម្បីទំនាក់ទំនង ឬផ្ទេរលទ្ធផលស្រាវជ្រាវរបស់ខ្លួនដល់វិស័យឯកជន អ្នកឆ្លើយតបបានលើកឡើងនូវវិធីសាស្ត្រ ដូចជា៖

- ព្រឹត្តិការណ៍កើតតែមួយដង៖ ដំណើរទស្សនកិច្ច ទិវាការងារ វគ្គបណ្តុះបណ្តាល
- សិក្ខាសាលា និងសន្និសីទ
- ប្រព័ន្ធផ្សព្វផ្សាយសង្គម
- អង្គភាពសហការជាក់លាក់
- តាមរយៈបណ្តាញដែលមានស្រាប់ និងបណ្តាញអតីតនិស្សិត
- តាមរយៈគេហទំព័ររបស់សាកលវិទ្យាល័យ។

វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ជាស្ថាប័នតែមួយប៉ុណ្ណោះ ដែលមានបន្ទប់ពិសោធន៍រួមគ្នា ឬបន្ទប់ពិសោធន៍បើកចំហរ ដែលអ្នកជំនាញក្នុងវិស័យឯកជនអាចប្រើប្រាស់បាន។ នៅពេលយើងសួរថា តើស្ថាប័នរបស់ពួកគេមានការលើកទឹកចិត្តឱ្យបុគ្គលិកស្រាវជ្រាវរបស់ពួកគេសហការជាមួយវិស័យឯកជនដែរឬទេ? ស្ថាប័នចំនួនបួនបាននិយាយថាបុគ្គលិកស្រាវជ្រាវរបស់ពួកគេ «ត្រូវបានលើកទឹកចិត្តខ្លះ» ជាមួយនឹងការងារប្រឹក្សាយោបល់ដែលទទួលកម្រៃ និងការងារគម្រោងបន្ថែម។ ស្ថាប័នចំនួនបីទៀតបាននិយាយថា ស្ថាប័នរបស់ពួកគេមិនទាន់មានការលើកទឹកចិត្តក្នុងរូបភាពណាមួយសម្រាប់បុគ្គលិកស្រាវជ្រាវរបស់ពួកគេនៅឡើយ ដោយអ្នកឆ្លើយតបបានបញ្ជាក់ថា បុគ្គលិកស្រាវជ្រាវត្រូវបានជំរុញឱ្យមានកិច្ចសហការជាមួយវិស័យឯកជន ប៉ុន្តែពួកគេមិនបានទទួលការលើកទឹកចិត្ត

ជាកម្រៃបន្ថែមនោះទេ។ នៅពេលសួរថា តើពួកគេគិតថារដ្ឋាភិបាលអាចផ្តល់ការលើកទឹកចិត្តចំពោះកិច្ចសហការរវាងវិស័យឯកជនបន្ថែមទៀតដោយរបៀបណា? ពួកគេបានចែករំលែកការយល់ឃើញ ដូចខាងក្រោម៖

- អភិវឌ្ឍគោលនយោបាយ និងគោលការណ៍ណែនាំលើការងារប្រឹក្សាយោបល់សម្រាប់អ្នកស្រាវជ្រាវ (បច្ចុប្បន្នមន្ត្រីរាជការមិនត្រូវបានអនុញ្ញាតឱ្យធ្វើការងារប្រឹក្សាយោបល់ឡើយ)
- វិភាជមូលនិធិសម្រាប់ការស្រាវជ្រាវរួមគ្នាជាមួយវិស័យឯកជន
- ផ្តល់យន្តការជំរុញលើកទឹកចិត្តដល់អ្នកស្រាវជ្រាវដែលសហការដោយជោគជ័យជាមួយវិស័យឯកជន ដូចជា ការផ្តល់រង្វាន់ និងការផ្តល់ការអនុគ្រោះពន្ធ
- ធានាកម្មសិទ្ធិបញ្ញា
- អភិវឌ្ឍថ្នាលបច្ចេកវិទ្យាអនឡាញសម្រាប់អ្នកស្រាវជ្រាវ មន្ត្រីរដ្ឋាភិបាល និងវិស័យឯកជន អាចសហការ និងបំពេញតម្រូវការជាមួយនឹងជំនាញ
- សម្របសម្រួលការប្រើប្រាស់របកគំហើញពីការស្រាវជ្រាវអនុលោមទៅនឹងបរិការណ៍ឧស្សាហកម្ម។

### វិស័យឯកជន

ស្ថាប័ន/អង្គភាពក្នុងវិស័យឯកជនត្រូវបានសាកសួរដើម្បីឱ្យឆ្លើយតបទៅនឹងសំណួរ តើបច្ចុប្បន្នពួកគេបានសហការជាមួយសាកលវិទ្យាល័យនិងស្ថាប័នស្រាវជ្រាវឬទេ? ក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប បានរាយការណ៍ថា "កំពុងសហការមួយចំនួន" ប៉ុន្តែស្ថាប័នដទៃទៀតមិនទាន់មានកិច្ចសហការនៅឡើយ។ ក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប រាយការណ៍ថាក្រុមហ៊ុនខ្លួនបានសហការជាមួយ Invivo lab (វៀតណាម និងបារាំង) និងសាកលវិទ្យាល័យជុឡាឡុងកន (ប្រទេសថៃ)។ នៅពេលសាកសួរថា តើការស្រាវជ្រាវណាខ្លះដែលបានពីសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវបានរួមចំណែកបំពេញតម្រូវការរបស់អង្គភាពពួកគេ? ស្ថាប័នឆ្លើយតបចំនួនបី (សហគ្រាសធុនតូចនិងមធ្យម ក្រុមហ៊ុនអេមរុាយស៍ ខាមបូឌា និងក្រុមហ៊ុន ម៉ុងឫទ្ធី គ្រុប) បាននិយាយថា ការស្រាវជ្រាវពីសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវបានចូលរួមចំណែកបំពេញតម្រូវការមួយចំនួនរបស់ស្ថាប័ន។ ផ្ទុយមកវិញ សភាពាណិជ្ជកម្មកម្ពុជាបានរាយការណ៍ថាមិនមានឡើយ។ នៅពេលសួរថា តើរបៀបវារៈស្រាវជ្រាវជាតិ គួររួមបញ្ចូលសកម្មភាពអ្វីខ្លះដើម្បីធ្វើឱ្យប្រសើឡើងនូវកិច្ចសហការរវាងគ្រឹះស្ថានសិក្សានិងវិស័យឯកជន? អ្នកឆ្លើយតបបានស្នើឱ្យមានការរៀបចំបង្កើតឱ្យមានអង្គភាពបង្គោល និងយន្តការក្នុងការសម្របសម្រួលភាពជាដៃគូរវាងវិស័យផ្សេងគ្នា។

### ក្រសួងពាក់ព័ន្ធ

ឆ្លើយតបទៅនឹងសំណួរ តើបច្ចុប្បន្នក្រសួងរបស់ពួកគេបាននិងកំពុងលើកទឹកចិត្តដល់កិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងវិស័យឧស្សាហកម្មដែរឬទេ? មានក្រសួងចំនួន ៤ ប៉ុណ្ណោះក្នុងចំណោមក្រសួងទាំង ១១ ដែលបានឆ្លើយថាក្រសួងរបស់ពួកគេមានការទឹកចិត្តដល់កិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងវិស័យឧស្សាហកម្ម រួមមាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍ និង

ទូរគមនាគមន៍, និងក្រសួងពាណិជ្ជកម្ម។ ឆ្លើយតបទៅនឹងសំណួរ តើការលើកទឹកចិត្តសម្រាប់សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវមានលក្ខណៈបែបណា? អ្នកឆ្លើយតបមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឆ្លើយថា ក្រសួងបានលើកទឹកចិត្តតាមរយៈការគាំទ្រផ្នែកបច្ចេកទេស។ បន្ថែមលើនេះ អ្នកឆ្លើយតបម្នាក់ទៀតមកពីក្រសួងដដែលបាននិយាយថា "ដើម្បីជួយឱ្យសហគ្រាសធុនតូច និងមធ្យមមានលទ្ធភាពក្នុងការចាប់យកបច្ចេកវិទ្យាទៅក្នុងផលិតកម្មរបស់ពួកគេ រាជរដ្ឋាភិបាលបានផ្តល់ការលើកទឹកចិត្តតាមរយៈយន្តការអនុគ្រោះពន្ធដែលមានចែងក្នុងអនុក្រឹត្យលេខ ១២៤ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨ ស្តីពី ការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យអាទិភាព។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលក៏បានផ្តល់ការលើកលែងពន្ធសម្រាប់គ្រឹះស្ថានឧត្តមសិក្សាផងដែរ"។ ជាមួយគ្នានេះ ក្រសួងពាណិជ្ជកម្មបានបញ្ជាក់ពីការលើកទឹកចិត្តសម្រាប់ការកសាងសមត្ថភាពរបស់មន្ត្រីរាជការ។ ម្យ៉ាងទៀត ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក៏បានរាយការណ៍ពីមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងអភិវឌ្ឍន៍របស់ខ្លួនផងដែរ។

ទាក់ទងនឹងការលើកទឹកចិត្តសម្រាប់វិស័យឯកជន យើងទទួលបានចម្លើយស្រដៀងគ្នាផងដែរ ដូចជាការគាំទ្រផ្នែកបច្ចេកទេស ការកាត់បន្ថយពន្ធលើប្រាក់ចំណូល ការលើកទឹកចិត្តការចំណាយដែលអាចកាត់កងបាន និងការលើកទឹកចិត្តមិនមែនហិរញ្ញវត្ថុ។ អ្នកដែលបានឆ្លើយតបថា មិនមានការលើកទឹកចិត្តសម្រាប់កិច្ចសហការនាពេលបច្ចុប្បន្ន បានសន្មតថាអវត្តមាននៃការលើកទឹកចិត្តបណ្តាលមកពីកង្វះហិរញ្ញវត្ថុ ឬធនធានដទៃទៀត។

ឆ្លើយតបទៅនឹងសំណួរ តើរបៀបវារៈស្រាវជ្រាវជាតិគួរតែផ្តោតជាចម្បងលើអ្វីខ្លះ ដើម្បីអភិវឌ្ឍកិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងវិស័យឧស្សាហកម្មបន្ថែម? អ្នកឆ្លើយតបបានផ្តល់អនុសាសន៍ដូចខាងក្រោម៖

- កសាងគោលនយោបាយស្រាវជ្រាវ និងប្រព័ន្ធអេកូឡូស៊ីដ៏រឹងមាំសម្រាប់អ្នកស្រាវជ្រាវកម្ពុជា
- ធានាការការពារទិន្នន័យ៖ ហេតុផលមួយនៃការពិបាកក្នុងការសម្រេចចិត្តសម្រាប់ការបង្កើតកិច្ចសហការគឺបញ្ហានៃការជឿទុកចិត្ត និងការមិនទាន់យល់ស្របគ្នាចំពោះការអនុវត្តក្រមសីលធម៌ស្រាវជ្រាវ។ និយតកម្មក្រមសីលធម៌ស្រាវជ្រាវ និងការការពារទិន្នន័យ នឹងធានាបានថាគ្រប់ស្ថាប័ននឹងយកចិត្តទុកដាក់យ៉ាងស្មើភាពគ្នាអំពីឯកជនភាពនៃទិន្នន័យ
- លើកទឹកចិត្តដល់ការបង្កើតអនុស្សរណៈនៃការយោគយល់គ្នា និងយន្តការសហការផ្សេងៗទៀត
- ពង្រឹងគុណភាពនៃស្ថាប័នស្រាវជ្រាវ និងគ្រឹះស្ថានឧត្តមសិក្សា
- លើកទឹកចិត្តវិនិយោគិន ដូចជា ទេវៈវិនិយោគិន ឬមូលនិធិមូលធនឯកជន ដើម្បីវិនិយោគក្នុងកម្មវិធីផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវ
- ដាក់បញ្ចូលក្របខណ្ឌស្តីពីវិធីលើកទឹកចិត្តកិច្ចសហការរវាងគ្រឹះស្ថានសិក្សា និងធុរកិច្ច ក្នុងរបៀបវារៈស្រាវជ្រាវជាតិ
- បង្កើនការសម្របសម្រួល និងកម្មវិធីផ្លាស់ប្តូរគ្នារវាងអ្នកស្រាវជ្រាវផ្សេងៗ ចំពោះជំនាញដែលត្រូវការ
- គាំទ្រកិច្ចសន្ទនារវាងគ្រឹះស្ថានសិក្សា និងវិស័យឯកជនបន្ថែមទៀត។

សរុបមក កិច្ចសហការដែលកំពុងធ្វើឡើងរវាងអ្នកស្រាវជ្រាវ និងឧស្សាហកម្ម មិនទាន់មានភាពគ្រប់គ្រាន់ទេ។ ទោះបីជាស្ថាប័នជាច្រើនបានបង្កើត  អង្គភាពដើម្បីជួយសម្រួលដល់ការតភ្ជាប់ទំនាក់ទំនងនេះក៏ដោយ ក៏ការបង្កើតអង្គភាពនេះមិនបានបង្ហាញឱ្យឃើញជាកិច្ចសហការជាក់ស្តែងបានគ្រប់គ្រាន់នោះទេ។ បន្ថែមលើបញ្ហានៃការលើកទឹកចិត្តមិនទាន់មានភាពគ្រប់គ្រាន់ ការលើកទឹកចិត្តបច្ចុប្បន្នមួយចំនួនក៏កំពុងជួបប្រទះបញ្ហានៃភាពមិនច្បាស់លាស់អំពីរបៀបដំណើរការទៀតផង។

## ៣.៧. ធាតុចូលរបស់គ្រឹះស្ថានសិក្សាសម្រាប់ការធ្វើគោលនយោបាយ

### *៣.៧.១. តើការស្រាវជ្រាវសិក្សា ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការធ្វើគោលនយោបាយក្នុងកម្រិតណា?*

**ក្រសួងពាក់ព័ន្ធ**

អ្នកឆ្លើយតបមកពីក្រសួងពាក់ព័ន្ធត្រូវបានសួរអំពីវិសាលភាពដែលក្រសួងអនុញ្ញាតឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងៗ ក្នុងការបង្កើតគោលនយោបាយ។ លទ្ធផលត្រូវបានបង្ហាញក្នុងតារាងទី ១៥។

តារាង គ. 6៖ ឥទ្ធិពលនៃគ្រឹះស្ថានសិក្សាស្រាវជ្រាវជាមូលដ្ឋានសម្រាប់ការបង្កើតគោលនយោបាយ

| ក្រសួង/ស្ថាប័ន | សាកលវិទ្យាល័យ | ស្ថាប័នស្រាវជ្រាវ | វិស័យឯកជន | សង្គមស៊ីវិល |
|---|---|---|---|---|
| ក្រសួងរ៉ែ និងថាមពល | ខ្លាំងណាស់ | ខ្លាំងណាស់ | ខ្លាំងណាស់ | ខ្លាំងណាស់ |
| ក្រសួងមហាផ្ទៃ | បង្គួរ | បង្គួរ | បង្គួរ | បង្គួរ |
| ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ខ្លាំងណាស់ | ខ្លាំងណាស់ | ខ្លាំងណាស់ | ខ្លាំងណាស់ |
| ក្រសួងធនធានទឹក និងឧតុនិយម | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | បង្គួរ | បង្គួរ | បង្គួរ / ខ្លាំងណាស់ | បង្គួរ |
| ក្រសួងពាណិជ្ជកម្ម | គ្មាន | បង្គួរ / គ្មាន | គ្មាន | គ្មាន |
| ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ខ្លាំងណាស់ | ខ្លាំងណាស់ | ខ្លាំងណាស់ | បង្គួរ |

| | | | | |
|---|---|---|---|---|
| ក្រសួងផែនការ | គ្មាន | បង្គួរ | គ្មាន | គ្មាន |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | បង្គួរ | បង្គួរ | បង្គួរ | បង្គួរ |
| ក្រសួងអប់រំ យុវជន និងកីឡា | ខ្លាំងណាស់ | បង្គួរ | បង្គួរ | បង្គួរ |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | បង្គួរ | បង្គួរ | ខ្លាំងណាស់ | បង្គួរ |

កម្រិតនៃការពិគ្រោះយោបល់របស់អ្នកពាក់ព័ន្ធសម្រាប់ការបង្កើតគោលនយោបាយមានភាពខុសគ្នាយ៉ាងខ្លាំងក្នុងចំណោមបណ្តាក្រសួងពាក់ព័ន្ធ។ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងរ៉ែ និងថាមពល និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពឹងផ្អែកយ៉ាងខ្លាំងលើការពិគ្រោះយោបល់ជាមួយបញ្ញវន្ត។ ចំណែកឯក្រសួងផ្សេងទៀតអនុវត្តតិចតួច ឬគ្មានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។ ឆ្លើយតបទៅនឹងសំណួរ តើការបកប្រែការស្រាវជ្រាវទៅជាគោលនយោបាយប្រឈមនឹងការលំបាកចម្បងអ្វីខ្លះ? អ្នកឆ្លើយតបបានផ្តោតសំខាន់លើ៖

- កង្វះយន្តការដែលមានឥទ្ធិពលចំពោះការធ្វើគោលនយោបាយ
- កង្វះរបៀបវារៈស្រាវជ្រាវជាតិដែលប្រមូលផ្តុំភាគីពាក់ព័ន្ធទាំងអស់
- គោលនយោបាយ និងរបៀបវារៈមានការផ្លាស់ប្តូរឥតឈប់ឈរ
- កង្វះជំនាញបច្ចេកទេសដើម្បីបកប្រែការស្រាវជ្រាវទៅជាគោលនយោបាយ
- កង្វះអ្នកវិទ្យាសាស្ត្រក្នុងការបង្កើតគោលនយោបាយ
- កង្វះការប្រាស្រ័យទាក់ទងរវាងអ្នកបង្កើតគោលនយោបាយ និងអ្នកស្រាវជ្រាវ

អនុសាសន៍ណែនាំស្តីពីវិធីសាស្ត្រដែលរបៀបវារៈស្រាវជ្រាវជាតិ គួរដោះស្រាយចំពោះបញ្ហានៃការបកប្រែការស្រាវជ្រាវទៅជាគោលនយោបាយ មានដូចខាងក្រោម៖

- កសាងសមត្ថភាពរបស់អ្នកស្រាវជ្រាវ
- ផ្តល់រូបភាពច្បាស់លាស់នៃវិស័យអាទិភាពដើម្បីចង្អុលបង្ហាញការស្រាវជ្រាវ
- ធានាឱ្យបានថាការធ្វើគោលនយោបាយគឺផ្អែកលើភស្តុតាង
- ផ្តល់គោលដៅសមស្រប និងការយល់ដឹងរួមគ្នាសម្រាប់អ្នកស្រាវជ្រាវ អ្នកបង្កើតគោលនយោបាយ និងអ្នកពាក់ព័ន្ធផ្សេងទៀត
- បង្កើតក្រុមទំនាក់ទំនង និងបង្កើតវេទិកាទំនាក់ទំនង

## ៣.៨. ក្របខណ្ឌបទប្បញ្ញត្តិ និងគោលនយោបាយការស្រាវជ្រាវ នាគីពាក់ព័ន្ធទាំងអស់

### *៣.៨.១. តើក្របខណ្ឌបទប្បញ្ញត្តិ និងគោលនយោបាយការស្រាវជ្រាវមានអ្វីខ្លះ? តើក្របខណ្ឌបទប្បញ្ញត្តិ និងគោលនយោបាយការស្រាវជ្រាវអាចត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើងដោយវិធីណា?*

អ្នកឆ្លើយតបមកពីសាកលវិទ្យាល័យចំនួន ៤ ក្នុងចំណោម៧, ក្រសួងចំនួន៨ ក្នុងចំណោម១១, និងវិស័យឯកជនចំនួន២ ក្នុងចំណោម ៣ បានដឹងអំពីគោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិកម្រិតជាតិដែលមានស្រាប់ដើម្បីគាំទ្រការស្រាវជ្រាវ និងនវានុវត្តន៍ ប៉ុន្តែពួកគេមិនបានផ្តល់ព័ត៌មានលម្អិតអំពីគោលនយោបាយ និងក្របខណ្ឌបទប្បញ្ញត្តិទាំងនោះទេ។ អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលក្នុងការគាំទ្រ និងលើកកម្ពស់សកម្មភាពស្រាវជ្រាវរួមមាន៖

- បង្កើនថវិកា
- ផ្តល់អាទិភាពដល់អ្នកស្រាវជ្រាវកម្ពុជាច្រើនជាងអ្នកស្រាវជ្រាវអន្តរជាតិ
- លើកកម្ពស់តួនាទីអ្នកស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ
- ជំរុញការស្រាវជ្រាវដែលអាចរកចំណូលបាន
- បង្កើតសាកលវិទ្យាល័យស្រាវជ្រាវ
- មានស្ថាប័នរាជរដ្ឋាភិបាល ឬស្ថាប័នដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃការស្រាវជ្រាវ
- ការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍
- ច្បាប់ស្តីពីការការពារកម្មសិទ្ធិបញ្ញា
- សម្របសម្រួលទំនាក់ទំនងសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធនៃការស្រាវជ្រាវផ្សេងៗគ្នា
- ធ្វើឱ្យមានការអនុវត្តនីតិវិធីនិងការគ្រប់គ្រងហិរញ្ញវត្ថុកាន់តែមានភាពបត់បែន ដើម្បីគាំទ្រដល់សកម្មភាពស្រាវជ្រាវឱ្យកាន់តែប្រសើរ
- វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ និងធនធានមនុស្ស
- បណ្តុះបណ្តាលអ្នកស្រាវជ្រាវបន្ថែមទៀត
- ផ្តល់លទ្ធភាពចូលទៅប្រើប្រាស់ឯកសារ និងទិន្នន័យ។

ការយល់ឃើញពីច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាបច្ចុប្បន្នមានភាពខុសគ្នាក្នុងចំណោមអ្នកឆ្លើយតបមកពីសាកលវិទ្យាល័យដែលចូលរួមឆ្លើយសំណួរទាំងអស់។ សាកលវិទ្យាល័យចំនួន៣ គិតថាច្បាប់ស្តីបីកម្មសិទ្ធិបញ្ញាបច្ចុប្បន្នគឺ «គ្រប់គ្រាន់ណាស់» ដើម្បីលើកទឹកចិត្តឱ្យមាននវានុវត្តន៍ក្នុងការស្រាវជ្រាវ ខណៈសាកលវិទ្យាល័យចំនួន ៣ ទៀតគិតថាគ្រាន់តែ «គ្រប់គ្រាន់ខ្លះ» និង សាកលវិទ្យាល័យចំនួន១ គិតថា «មិនគ្រប់គ្រាន់» នៅឡើយទេ។ ដើម្បីកែលម្អការអនុវត្តច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា អ្នកឆ្លើយតបគិតថា គួរតែមានការរៀបចំព្រឹត្តិការណ៍ឱ្យបានច្រើនបន្ថែម

ទៀតដើម្បីលើកទឹកចិត្តអ្នកស្រាវជ្រាវឱ្យចូលរួមជាមួយប្រធានបទនេះ។ អ្នកឆ្លើយតបម្នាក់គិតថា បញ្ហានៃការអនុវត្តច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា គឺហាក់ដូចជាពាក់ព័ន្ធទៅនឹងក្រុមហ៊ុនធំៗជាជាងអ្នកស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ។

អ្នកឆ្លើយតបម្នាក់ក្នុងចំណោមអ្នកឆ្លើយតបក្នុងវិស័យឯកជនទាំងអស់គិតថាការអនុវត្តច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាគឺ «មិនគ្រប់គ្រាន់ទេ» ក្នុងការលើកទឹកចិត្តដល់នវានុវត្តន៍នៃការស្រាវជ្រាវនោះទេ។ អ្នកឆ្លើយតបចំនួន ២នាក់គិតថា «គ្រប់គ្រាន់ខ្លះ» ខណៈអ្នកឆ្លើយតបម្នាក់គិតថា «គ្រប់គ្រាន់ណាស់»។ អ្នកឆ្លើយតបចំនួន ២នាក់ បានផ្តល់ជាអនុសាសន៍ក្នុងការអនុវត្តច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាឱ្យកាន់តែប្រសើរឡើងដើម្បីកែលម្អស្ថានភាព។

អ្នកឆ្លើយតបមកពីក្រសួងចំនួន ៩នាក់ ក្នុងចំណោមអ្នកឆ្លើយតបទាំងអស់គិតថាច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាគឺ «គ្រប់គ្រាន់ខ្លះ» និងអ្នកឆ្លើយតបចំនួន ២នាក់ផ្សេងទៀតគិតថា «គ្រប់គ្រាន់ណាស់»។ អ្នកឆ្លើយតបបានផ្តល់អនុសាសន៍ផ្សេងៗគ្នា រួមមាន៖

- ផ្តល់អាទិភាពដល់ការទទួលបានតក្កកម្មដែលផ្តល់ផលប្រយោជន៍ដល់សាធារណៈ
- ទាក់ទាញអ្នកជំនាញកម្មសិទ្ធិបញ្ញាបន្ថែមទៀតដើម្បីអនុវត្តច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា
- បង្កើនការផ្សព្វផ្សាយច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាដល់វិស័យសាធារណៈ និងឯកជន
- គាំទ្រដល់វិស័យឯកជនក្នុងការទទួលបានតក្កកម្ម
- គាំទ្រវិស័យឯកជនលើសកម្មភាពរុករកបច្ចេកវិទ្យា និងផ្ទេរបច្ចេកវិទ្យា
- គាំទ្រធុរកិច្ចថ្មី និងសហគ្រាសធុនតូច និងមធ្យមលើការចុះបញ្ជីកម្មសិទ្ធិបញ្ញា
- បង្កើនការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងប្រព័ន្ធកម្មសិទ្ធិបញ្ញា
- បង្កើតអង្គភាពកម្មសិទ្ធិបញ្ញានៅក្នុងសាកលវិទ្យាល័យ
- ផ្តល់ជូនការចុះបញ្ជីតក្កកម្មដោយឥតគិតថ្លៃដល់បេក្ខជនជាបញ្ញវន្ត
- បង្កើនល្បឿននៃដំណើរការវាយតម្លៃតក្កកម្ម
- ការកសាងសមត្ថភាពនៃអង្គភាពកម្មសិទ្ធិបញ្ញាក្នុងការអនុវត្តការវាយតម្លៃតក្កកម្មក្លែងក្លាយ
- ធ្វើបច្ចុប្បន្នភាពច្បាប់កម្មសិទ្ធិបញ្ញាជាតិ និងអនុលោមទៅនឹងច្បាប់កម្មសិទ្ធិបញ្ញាអន្តរជាតិ។

